ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ

# សារណា

# ឥរិយាបថរបស់សិស្សចំពោះមុខវិជ្ជាភាសាអង់គ្លេស
# នៅមធ្យមសិក្សាបឋមភូមិ
# ករណីសិក្សា៖ ខេត្តកំពង់ចាម

Student’s Attitudes towards English Subject at Lower Secondary School

Case Study: Kampong Cham Province

ដោយ / By

សែម ម៉ាក់

SEM Mak

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៥

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០១៦-២០១៨

ឧបត្ថម្ភដោយ មូលនិធិគាំទ្រការអប់រំអន្តរជាតិនៅកម្ពុជា

Supported by Cambodia International Education Support Foundation (CIESF)

# សារណា

# ឥរិយាបថរបស់សិស្សចំពោះមុខវិជ្ជាភាសាអង់គ្លេស

# នៅមធ្យមសិក្សាបឋមភូមិ

# ករណីសិក្សា៖ ខេត្តកំពង់ចាម

Student’s Attitudes towards English Subject at Lower Secondary School

Case Study: Kampong Cham Province


ដោយ / By

**សែម ម៉ាក់**

SEM Mak


**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់**

**ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៥**

**ឯកទេស៖ គ្រប់គ្រងអប់រំ**

**ឆ្នាំសិក្សា ២០១៦-២០១៨**

សាស្ត្រាចារ្យណែនាំ៖

**បណ្ឌិត ខួន សុខចេង**

សាស្ត្រាចារ្យជំនួយ៖

**លោក លន លីណា**


**វិទ្យាស្ថានជាតិអប់រំ ភ្នំពេញ កម្ពុជា**

National Institute of Education (NIE)

Phnom Penh, Kingdom of Cambodia

**គណៈកម្មការវាយតម្លៃនៃការការពារសារណា**
**សម្រាប់កម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ**

**វិទ្យាស្ថានជាតិអប់រំ**

# សារណា

# ឥរិយាបថរបស់សិស្សចំពោះមុខវិជ្ជាភាសាអង់គ្លេស

# នៅមធ្យមសិក្សាបឋមភូមិ

# ករណីសិក្សា៖ ខេត្តកំពង់ចាម

Student’s Attitudes towards English Subject at Lower Secondary School
Case Study: Kampong Cham Province

**សារណានេះត្រូវបានឯកភាពដោយ**

(១) សាស្ត្រាចារ្យណែនាំ៖

**បណ្ឌិត ឌួន សុខចេង**

(២) តំណាងវិទ្យាស្ថានជាតិអប់រំ៖

**ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា**

(៣) តំណាងគណៈកម្មការវាយតម្លៃ៖

**ឯកឧត្តមបណ្ឌិត ជ័យ សារិន**

## សេចក្តីប្រកាសអះអាងរបស់បេក្ខជន

ខ្ញុំបាទសូមបញ្ជាក់ថាសារណាស្រាវជ្រាវដែលមានចំណងជើងថា "**ឥរិយាបថរបស់សិស្សចំពោះមុខវិជ្ជាភាសាអង់គ្លេសនៅមធ្យមសិក្សាបឋមភូមិ**" សម្រាប់បំពេញលក្ខខណ្ឌសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ជាស្នាដៃរបស់ខ្ញុំបាទទាំងស្រុងពិតប្រាកដមែន ។ ស្នាដៃនេះ ពុំទាន់បានប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់ទទួលសញ្ញាបត្រនៅវិទ្យាស្ថាននេះ ឬសាកលវិទ្យាល័យណា ឬវិទ្យាស្ថានថ្នាក់ស្មើណាមួយនៅឡើយទេ ។ ពុំមានសេចក្តីដកស្រង់ ឬខ្លឹមសារអ្វីមួយត្រូវបានប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះ ដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះបញ្ជីឯកសារយោងឡើយ ។ សារណាស្រាវជ្រាវខាងលើនេះ ជាការសិក្សាស្រាវជ្រាវចងក្រងដោយខ្ញុំបាទផ្ទាល់ពិតប្រាកដមែន ។

ថ្ងៃ ខែ ឆ្នាំច សំរឹទ្ធិស័ក ពុទ្ធសករាជ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៨

**ហត្ថលេខាបេក្ខជន**

## ការបញ្ជាក់ពីសាស្ត្រាចារ្យណែនាំ

ក្នុងនាមជាសាស្ត្រាចារ្យណែនាំការសរសេរសារណាស្រាវជ្រាវនេះ សូមបញ្ជាក់ថា បេក្ខជន **សែម ម៉ាក់** ពិតជាបានសរសេរសារណាស្រាវជ្រាវខាងលើពិតប្រាកដមែន ។

ថ្ងៃ ខែ ឆ្នាំច សំរឹទ្ធិស័ក ពុទ្ធសករាជ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៨

**ហត្ថលេខា**

**សាស្ត្រាចារ្យបណ្ឌិត ខួន សុខចេង**

# សេចក្តីថ្លែងអំណរគុណ

ជាបឋម ខ្ញុំបាទសូមថ្លែងអំណរគុណដល់វិទ្យាស្ថានជាតិអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា និងអង្គការមូលនិធិគាំទ្រការអប់រំអន្តរជាតិកម្ពុជា Cambodia International Education Support Foundation (CIESF) ដែលបានរៀបចំ និងផ្តល់នូវអាហារូបករណ៍ ក៏ដូចជាផ្តល់ឱកាសដល់រូបខ្ញុំបាទបានសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំនាពេលកន្លងមក ។

ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនចំពោះគណៈកម្មការគ្រប់គ្រងការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ នៃវិទ្យាស្ថានជាតិអប់រំ ព្រមទាំងលោកសាស្ត្រាចារ្យទាំងអស់ ដែលបានខិតខំចំណាយពេលវេលាដ៏មមាញឹក និងមានតម្លៃបំផុតមកបង្ហាត់បង្រៀន និងពន្យល់គ្រប់មេរៀនដល់យើងខ្ញុំទាំងអស់គ្នា ដោយមិនគិតពីការលំបាក និងពេលវេលាដ៏មានតម្លៃឡើយ ។ ជាពិសេសខ្ញុំបាទសូមថ្លែងអំណរគុណចំពោះលោកស្រីបណ្ឌិត **ខួន សុខចេង** ដែលតែងតែចំណាយពេលវេលាដ៏មានតម្លៃដើម្បីពន្យល់ណែនាំដល់រូបខ្ញុំគ្រប់ជំហាន ទើបធ្វើឱ្យការសិក្សាស្រាវជ្រាវរបស់ខ្ញុំនាពេលនេះទទួលបានជោគជ័យ និងបញ្ចប់ទៅដោយភាពរលូន ។ ខ្ញុំបាទក៏សូមថ្លែងអំណរគុណដល់លោកសាស្ត្រាចារ្យជំនួយ **លន លីណា** ដែលបានផ្តល់នូវកម្លាំងចិត្ត ចំណេះដឹង និងចែករំលែកនូវបទពិសោធន៍ដល់រូបខ្ញុំ ទាំងការសិក្សាស្រាវជ្រាវ ទាំងក្នុងអំឡុងពេលសិក្សា ។ ជាមួយគ្នានេះផងដែរ ខ្ញុំសូមថ្លែងអំណរគុណដល់លោក ឪពុក អ្នកម្តាយ ភរិយា និងក្រុមគ្រួសាររបស់ខ្ញុំទាំងមូលដែលតែងតែផ្តល់នូវកម្លាំងចិត្ត ផ្តល់នូវភាពកក់ក្តៅដល់រូបខ្ញុំគ្រប់ពេលវេលា ហើយក៏សូមថ្លែងអំណរគុណដល់មិត្តរួមថ្នាក់ រួមជំនាន់ទី៥ទាំងអស់របស់ខ្ញុំផងដែរ ដែលតែងតែចែករំលែកចំណេះដឹងបទពិសោធន៍ និងព័ត៌មានទាំងឡាយដែលធ្វើឱ្យរូបខ្ញុំមានមោទនភាពយ៉ាងខ្លាំងដែលខ្ញុំមានមិត្តភក្តិល្អៗបែបនេះ ។

ខ្ញុំបាទសូមថ្លែងអំណរគុណដល់មន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ចាម គណៈគ្រប់គ្រងសាលា លោកគ្រូ/អ្នកគ្រូ និងសិស្សានុសិស្សនៅតាមសាលាគោលដៅទាំង ១៥ ដែលបានអនុញ្ញាត និងចូលរួមសហការណ៍ក្នុងអំឡុងពេលដំណើរការប្រមូលទិន្នន័យ ដែលធ្វើឱ្យការសិក្សាស្រាវជ្រាវនេះទទួលបានជោគជ័យ ។

ទីបញ្ចប់ ខ្ញុំបាទសូមប្រសិទ្ធពរជ័យជូនចំពោះអ្នកទាំងអស់គ្នា សូមឱ្យមានសុខភាពល្អបរិបូណ៌ កម្លាំងពលំមាំមួន ប្រកបការងារទទួលបានជោគជ័យគ្រប់ភារកិច្ច ព្រមទាំងទទួលបាននូវពុទ្ធពរទាំង ៤ ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លាងឃ្លៀតឡើយ ។

សូមអរគុណ !

# មូលន័យសង្ខេប

ភាសាអង់គ្លេស គឺជាភាសាសម្រាប់ពិភពលោកទាំងមូលអស់រយៈពេលជាងមួយសតវត្សមក ហើយៗវាត្រូវបានគេទទួលស្គាល់នៅក្នុងបណ្តាប្រទេសជាច្រើននៅជុំវិញពិភពលោក ។ មិនតែប៉ុណ្ណោះ ប្រទេសជាង ៥០ ក្នុងពិភពលោកបាន និងកំពុងប្រើប្រាស់ភាសាអង់គ្លេសជាភាសាផ្លូវការរបស់ខ្លួនផងដែរ ។ ក្នុងបរិបទកម្ពុជា ភាសាអង់គ្លេសត្រូវបានដាក់បញ្ចូលក្នុងកម្មវិធីសិក្សានៅកម្រិតមធ្យមសិក្សាតាំងពីឆ្នាំ1989 និងនៅកម្រិតបឋមសិក្សានៅឆ្នាំ2004 ក្នុងកម្មវិធីបំណិនជីវិតមូលដ្ឋាន ។ ការសិក្សានេះមានបំណងសិក្សាស្វែងយល់ពីឥរិយាបថ[១]របស់សិស្សចំពោះមុខវិជ្ជាភាសាអង់គ្លេស នៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ចាម ថាតើចាប់តាំងពីការដាក់ឱ្យសិក្សាជាផ្លូវការមក សិស្សមានទស្សនៈបែបណាចំពោះភាសានេះ ។ ការសិក្សានេះ ក៏បានពិនិត្យរកភាពខុសគ្នារវាងឥរិយាបថរបស់សិស្ស ចំពោះមុខវិជ្ជាភាសាអង់គ្លេសដោយផ្អែកលើភេទ កម្រិតថ្នាក់ និងតំបន់ផងដែរ ។ ម៉្យាងទៀត ការសិក្សានេះក៏មានបំណងរកឱ្យឃើញនូវបញ្ហាប្រឈមនានាដែលគ្រូ និងសិស្សកំពុងជួបប្រទះក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនៅមធ្យមសិក្សាបឋមភូមិកក្នុងខេត្តកំពង់ចាមផងដែរ ។

ផ្អែកតាមលទ្ធផលនៃការសិក្សាស្រាវជ្រាវបានបង្ហាញថា ជាទូទៅសិស្សមានឥរិយាបថវិជ្ជមានកម្រិតខ្ពស់ (M = 3.7; SD = 0.37) ចំពោះមុខវិជ្ជាភាសាអង់គ្លេស ។ សិស្សមានអារម្មណ៍សប្បាយរីករាយ យល់ច្បាស់ពីតម្រូវការ និងភាពចាំបាច់នៃភាសាអង់គ្លេស និងមានការឱ្យតម្លៃខ្ពស់ទៅលើការសិក្សាភាសាអង់គ្លេស ។ ជាងនេះទៅទៀត សិស្សរៀនភាសាអង់គ្លេស ដោយការពេញចិត្ត មិនមែនរៀនដើម្បីឱ្យតែប្រឡងជាប់ ឬដោយសារតែសាលាតម្រូវឱ្យរៀននោះទេ ។ ម៉្យាងទៀតពួកគេក៏មិនសូវមានការបារម្ភ ឬការខ្មាសអៀនច្រើនដែរក្នុងការនិយាយភាសាអង់គ្លេស ។ លទ្ធផលនៃការសិក្សាក៏បានបង្ហាញផងដែរថា រវាងសិស្សប្រុស និងសិស្សស្រីនៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ចាមមិនមានឥរិយាបថខុសគ្នានោះទេចំពោះមុខវិជ្ជាភាសាអង់គ្លេស ដោយមាន p-value = 0.81 > 0.05 ។ ចំណែកឯតាមកម្រិតថ្នាក់វិញ ឥរិយាបថរបស់សិស្សចំពោះមុខវិជ្ជាភាសាអង់គ្លេសក៏មិនមានភាពខុសគ្នាដែរ រវាងសិស្សថ្នាក់ទី៧ ទី៨ និងទី៩ ដោយមាន p-value = 0.89 > 0.05 ។ ដោយឡែក បើគិតតាមតំបន់វិញ លទ្ធផលនៃការស្រាវជ្រាវក៏បានបង្ហាញដែរថា ឥរិយាបថរបស់សិស្សដែលនៅតំបន់ទីប្រជុំជន តំបន់ចន្លោះទីប្រជុំជន និងទីជនបទ និងតំបន់ជនបទ មិនមានភាពខុសគ្នានោះទេ ដោយមាន p-value = 0.37 > 0.05 ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយក៏ដំណើរការនៃការបង្រៀន និងរៀនភាសាអង់គ្លេសនៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ចាម នៅមិនទាន់ប្រព្រឹត្តទៅដោយរលូននៅឡើយទេ ។ លទ្ធផលនៃការសិក្សាស្រាវជ្រាវបានបង្ហាញឱ្យឃើញថា អ្នកចូលរួមភាគច្រើន (84.64%) យល់ឃើញថា ការខ្វះសៀវភៅសិក្សាគោលជាបញ្ហាចម្បងមួយក្នុងដំណើរបង្រៀន និងរៀនភាសាអង់គ្លេស ។ រីឯការប្រើប្រាស់គ្រូបង្រៀនមិនមែនឯកទេសភាសាអង់គ្លេស (59.42%) ឱ្យបង្រៀនភាសាអង់គ្លេសក៏នៅមានច្រើន ដែលប្រការនេះអាចជះឥទ្ធិពលដល់ការផ្ទេរចំណេះដឹងពីគ្រូទៅសិស្សផងដែរ ព្រោះថាចំណេះដឹង

[១] ឥរិយាបថចែកចេញជា ៣ គឺ ឥរិយាបថអារម្មណ៍ (ចូលចិត្ត ឬមិនចូលចិត្តអ្វីមួយ) ឥរិយាបថយល់ដឹង (ការជឿជាក់ គំនិត ឬទស្សនៈអំពីអ្វីមួយ) និង ឥរិយាបថបែបអាកប្បកិរិយា (សកម្មភាព ឬប្រតិកម្មតបចំពោះអ្វីមួយទៅតាមស្ថានភាពជាក់ស្តែង) (Wenden, 1991)

និងវិធីសាស្ត្របង្រៀនរបស់ពួកគាត់លើមុខវិជ្ជានេះនៅមិនទាន់បានល្អនៅឡើយ ។ បន្ថែមពីលើនេះទៀត តាមរយៈលទ្ធផលនៃការសិក្សាស្រាវជ្រាវនេះក៏បានបង្ហាញផងដែរថា អ្នកចូលរួមច្រើនជាង 70% យល់ឃើញថា កង្វះសម្ភារឧបទេស (78.66%) និងកង្វះឯកសារស្រាវជ្រាវ (72.26%) ដើម្បីពង្រឹងសមត្ថភាពទាំងគ្រូ និងសិស្សក៏បានចូលរួមចំណែកមួយផ្នែកក្នុងការធ្វើឱ្យសិស្សមិនទាន់អាចទទួលបាននូវចំណេះដឹងភាសាអង់គ្លេសពេញលេញផងដែរ ។

សរុបមក យើងសង្កេតឃើញថាឥរិយាបថរបស់សិស្សចំពោះមុខវិជ្ជាភាសាអង់គ្លេសនៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ចាម មានលក្ខណៈល្អប្រសើរ ប៉ុន្តែត្រឹមតែមានឥរិយាបថល្អប្រសើរ នៅមិនទាន់គ្រប់គ្រាន់នៅឡើយទេ ។ បញ្ហាប្រឈមមួយចំនួនដូចរៀបរាប់ខាងលើ ជាកត្តារាំងស្ទះដល់ការអភិវឌ្ឍសមត្ថភាពផ្នែកភាសាអង់គ្លេសរបស់ពួកគេ ។ អាស្រ័យហេតុនេះ ក្រសួងអប់រំ យុវជន និងកីឡា និងអ្នកពាក់ព័ន្ធនានា គួរធ្វើយ៉ាងណាដោះស្រាយបញ្ហាទាំងអស់នេះឱ្យបាន នោះទើបសមត្ថភាពភាសាអង់គ្លេសរបស់សិស្សឈានដល់កម្រិតមួយតាមការចង់បាន ។

# ABSTRACT

English is a global language for more than a century and it has been recognized in many countries all over the world. In addition, over 50 countries have been using English as their official language. In Cambodian context, English was officially integrated into Secondary School's curriculum since 1989 and into Primary School in basic life skills program in 2014. This study aimed to investigate the student's attitudes [(1)] towards English subject at Lower-Secondary School in Kampong Cham province and what their viewpoints about it would be. This study also examined the significance between student's attitudes towards English subject based on gender, grade levels and regions. On the other hand, this study also aimed to find out the major challenging issues which both teachers and students are facing in teaching and learning English.

According to the research findings, in overal it obviously shows that students have highly positive attitudes (Mean=3.7; Std. Deviation=0.37) towards English subject. This means they are happy to learn the language; they understand the need and necessity of the language; and they also highly evaluate studying it. Moreover, they study the language with their satisfaction, not just to pass the exams or because of school's requirement. In addition, they are not so worried or very shy in speaking out the language. The result also reveals that it is not stastically significant between male and female student's attitudes towards English subject at Lower Secondary School in Kampong Cham province with p-value = 0.81 > 0.05. As for in term of grade level, there is also no statistical significance between grade 7, 8 and 9 student's attitudes towards English subject with its p-value = 0.89 > 0.05. Furthermore, in term of regions, the findings reveal that the student's attitudes towards English in the three region groups (town, between town and countryside, and countryside) do not differ because its p-value is 0.37 > 0.05. However, the process of teaching and learning English at Lower Secondary School in Kampong Cham province has not been in the smooth way yet. The research findings indicate that most participants think that the inadequacy of student's textbooks (84.64%) is the most dominant problem found in the process of teaching and learning English. Also there are still more teachers whose specializations are not English (59.42%) teaching English, which may impact on transferring knowledge from teachers to students because their knowledge and teaching methodology is not very good indeed. In addition to this, the results also represent that more than 70% of the participants think that the shortage of research documents (72.26%) and teaching and learning materials (78.66%) for both teachers and students partly contributes to make students unable to get full English language knowledge.

In sum, we see that student's attitudes toward English subject at Lower Secondary School in Kampong Cham province are good, but only having good attitudes is not enough yet. The challenging problems as mentioned above are obstacles in upgrading their English language capacity. Therefore, the Ministry of Education, Youth and Sport and other involved stakeholders should cope with these to enrich student's English knowledge at the expected target.


[(1)] Attitude is divided into 3 components, namely: Emotional Attitude ( like or dislike something ); Cognitive Attitude ( beliefs or ideas about something ) and Behavioral Attitude (actions or reactions to something in a particular situation) (Wenden, 1991)

# តារាងមាតិកា

សេចក្តីប្រកាសអះអាងរបស់បេក្ខជន ........ i
សេចក្តីថ្លែងអំណរគុណ ........ ii
មូលន័យសង្ខេប ........ iii
Abstract........ v
មាតិកា ........ vi
បញ្ជីចំណងជើងតារាង និងក្រាហ្វិក ........ ix
បញ្ជីពាក្យកាត់ ........ x

## ជំពូកទី១
## សេចក្តីផ្តើម

១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ........ 1
១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ........ 2
១.៣ គោលបំណងនៃការស្រាវជ្រាវ ........ 3
១.៤ សំណួរស្រាវជ្រាវ ........ 3
១.៥ សារៈសំខាន់នៃការស្រាវជ្រាវ........ 4
១.៦ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ........ 4
១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ........ 5

## ជំពូកទី២
## រំឭកទ្រឹស្តី

២.១ និយមន័យនៃឥរិយាបថ........ 6
២.២ លក្ខណៈទូទៅនៃឥរិយាបថ ........ 7
២.២.១ ទិដ្ឋភាពនៃឥរិយាបថ ........ 7
២.២.១.១ ទិដ្ឋភាពនៃឥរិយាបថអារម្មណ៍ ........ 7
២.២.១.២ ទិដ្ឋភាពនៃឥរិយាបថយល់ដឹង ........ 8
២.២.១.៣ ទិដ្ឋភាពនៃឥរិយាបថបែបអាកប្បកិរិយា........ 8
២.២.២ របកគំហើញនៃការសិក្សាអំពីឥរិយាបថ ........ 8

## ជំពូកទី៣
## វិធីសាស្ត្រស្រាវជ្រាវ

៣.១ ព័ត៌មានទូទៅស្តីពីការស្រាវជ្រាវ........ 14

៣.២ ទីកន្លែងសិក្សាស្រាវជ្រាវ ........ 14
៣.៣ ក្រុមគោលដៅ ........ 14
៣.៤ ទំហំសំណាក ........ 15
៣.៥ ឧបករណ៍សិក្សាស្រាវជ្រាវ ........ 16
៣.៦ វិធីសាស្ត្រប្រមូលទិន្នន័យ ........ 18
៣.៧ ដំណើរការក្នុងការប្រមូលទិន្នន័យ ........ 18
៣.៨ ការវិភាគទិន្នន័យ ........ 19
៣.៩ ក្រមសីលធម៌នៃការសិក្សាស្រាវជ្រាវ ........ 20
៣.១០ ព្រំដែននៃការសិក្សាស្រាវជ្រាវ ........ 20

## ជំពូកទី៤
## លទ្ធផលស្រាវជ្រាវ និងការពិភាក្សា

៤.១ ការវិភាគទិន្នន័យលើកម្រងសំណួរ ........ 21
៤.១.១ កម្រងសំណួរផ្នែកទី១៖ ព័ត៌មានទូទៅ ........ 21
៤.១.២ កម្រងសំណួរផ្នែកទី២ ........ 22
៤.១.២.១ កម្រងសំណួរអំពីឥរិយាបថរបស់សិស្សចំពោះមុខវិជ្ជាភាសាអង់គ្លេស ........ 22
៤.១.២.២ កម្រងសំណួរអំពីបញ្ហាប្រឈមនានាក្នុងការបង្រៀន និងរៀនភាសាអង់គ្លេស ........ 31
៤.១.២.២.១ ម៉ោងបង្រៀន និងរៀនភាសាអង់គ្លេស ........ 31
៤.១.២.២.១.១ ចំនួនម៉ោងបង្រៀន និងរៀនភាសាអង់គ្លេស ........ 31
៤.១.២.២.១.២ ភាពគ្រប់គ្រាន់នៃចំនួនម៉ោងមុខវិជ្ជាភាសាអង់គ្លេស ........ 32
៤.១.២.២.២ សៀវភៅសិក្សាគោលសម្រាប់សិស្ស ........ 33
៤.១.២.២.២.១ ប្រភេទនៃសៀវភៅសិក្សាគោលសម្រាប់សិស្ស ........ 33
៤.១.២.២.២.២ ការចូលចិត្តសៀវភៅសិក្សាគោលសម្រាប់សិស្ស ........ 34
៤.១.២.២.២.៣ កម្រិតសមស្រេបនៃសៀវភៅសិក្សាគោលសម្រាប់សិស្ស ........ 35
៤.១.២.២.២.៤ ភាពគ្រប់គ្រាន់នៃសៀវភៅសិក្សាគោលសម្រាប់សិស្ស ........ 36
៤.១.២.២.៣ គ្រូបង្រៀនភាសាអង់គ្លេស ........ 37
៤.១.២.២.៣.១ ឯកទេសគ្រូបង្រៀនភាសាអង់គ្លេស ........ 37
៤.១.២.២.៣.២ ចំណេះដឹងគ្រូបង្រៀនភាសាអង់គ្លេស ........ 38
៤.១.២.២.៣.៣ វិធីសាស្ត្របង្រៀនរបស់គ្រូបង្រៀនភាសាអង់គ្លេស ........ 39
៤.១.២.២.៣.៤ អវត្តមានរបស់គ្រូបង្រៀនភាសាអង់គ្លេស ........ 40
៤.១.២.២.៣.៥ ការគោរពម៉ោងចេញចូលរបស់គ្រូបង្រៀនភាសាអង់គ្លេស ........ 41
៤.១.២.២.៣.៦ ការប្រើប្រាស់សម្ភារឧបទេសរបស់គ្រូបង្រៀនភាសាអង់គ្លេស ........ 41

៤.១.២.២.៤ បណ្ណាល័យ ឯកសារស្រាវជ្រាវ និងសម្ភារឧបទេស ................................42
៤.១.២.២.៤.១ បណ្ណាល័យ........................................................................42
៤.១.២.២.៤.២ ឯកសារស្រាវជ្រាវ...............................................................42
៤.១.២.២.៤.៣ សម្ភារឧបទេស ....................................................................43
៤.១.២.២.៥ ការគ្រប់គ្រងបុគ្គលិក ..............................................................44
៤.១.២.២.៥.១ ការពិនិត្យតាមដាន និងវាយតម្លៃគ្រូបង្រៀនភាសាអង់គ្លេស ...............44

## ជំពូកទី៥
## សេចក្តីសន្និដ្ឋាន និងសំណូមពរ

៥.១ សន្និដ្ឋាន ......................................................................................... 46
៥.២ សំណូមពរ......................................................................................... 47
**ឯកសារយោង**.........................................................................................
**ឧបសម្ព័ន្ធ**..............................................................................................

# បញ្ជីចំណងជើងតារាង និងក្រាហ្វិក

| ល.រ | ចំណងជើងតារាង | ទំព័រ |
|---|---|---|


តារាងទី១ ក្រុមគោលដៅ និងអ្នកចូលរួម ..... 15
តារាងទី២ ចំនួននាយក គ្រូ និងសិស្សតាមសាលាគោលដៅ ..... 15
តារាងទី៣ សង្ខេបព័ត៌មានទូទៅ..... 21
តារាងទី៤ ចំនួនអ្នកឆ្លើយសំណួរតាមកម្រិត ..... 22
តារាងទី៥ តម្លៃមធ្យម គម្លាតស្តង់ដារ កម្រិត និងចំណាត់ថ្នាក់នៃឥរិយាបថ ..... 24
តារាងទី៦ កម្រិតនៃធាតុទាំងបីនៃឥរិយាបថ ..... 25
តារាងទី៧ សង្ខេបកម្រិតនៃធាតុទាំងបីនៃឥរិយាបថ..... 26
តារាងទី៨ ពិនិត្យភាពខុសគ្នានៃតម្លៃមធ្យមតាមក្រុមភេទនៃឥរិយាបថ..... 28
តារាងទី៩ ពិនិត្យភាពខុសគ្នានៃតម្លៃមធ្យមតាមក្រុមថ្នាក់នៃឥរិយាបថ..... 29
តារាងទី១០ ពិនិត្យភាពខុសគ្នានៃតម្លៃមធ្យមតាមក្រុមតំបន់នៃឥរិយាបថ ..... 30


## ចំណងជើងក្រាហ្វិក


ក្រាហ្វិកទី១ ចំនួនម៉ោងបង្រៀន និងរៀនភាសាអង់គ្លេស.....31
ក្រាហ្វិកទី២ ភាពគ្រប់គ្រាន់នៃចំនួនម៉ោងមុខវិជ្ជាភាសាអង់គ្លេស.....32
ក្រាហ្វិកទី៣ សៀវភៅសិក្សាគោលសម្រាប់សិស្ស .....33
ក្រាហ្វិកទី៤ ការចូលចិត្តសៀវភៅសិក្សាគោលសម្រាប់សិស្ស.....34
ក្រាហ្វិកទី៥ កម្រិតសមស្របនៃសៀវភៅសិក្សាគោលសម្រាប់សិស្ស.....35
ក្រាហ្វិកទី៦ ភាពគ្រប់គ្រាន់នៃសៀវភៅសិក្សាគោលសម្រាប់សិស្ស .....36
ក្រាហ្វិកទី៧ ឯកទេសគ្រូបង្រៀនភាសាអង់គ្លេស .....37
ក្រាហ្វិកទី៨ ចំណេះដឹងគ្រូបង្រៀនភាសាអង់គ្លេស.....38
ក្រាហ្វិកទី៩ វិធីសាស្ត្របង្រៀនរបស់គ្រូបង្រៀនភាសាអង់គ្លេស .....39
ក្រាហ្វិកទី១០ អវត្តមានគ្រូបង្រៀនភាសាអង់គ្លេស .....40
ក្រាហ្វិកទី១១ ការគោរពម៉ោងចេញចូលរបស់គ្រូបង្រៀនភាសាអង់គ្លេស .....41
ក្រាហ្វិកទី១២ ការប្រើប្រាស់សម្ភារឧបទេសរបស់គ្រូបង្រៀនភាសាអង់គ្លេស.....41
ក្រាហ្វិកទី១៣ ឯកសារស្រាវជ្រាវដើម្បីពង្រឹងសមត្ថភាពភាសាអង់គ្លេស.....42
ក្រាហ្វិកទី១៤ សម្ភារឧបទេសបម្រើឱ្យការបង្រៀន និងរៀនភាសាអង់គ្លេស .....43
ក្រាហ្វិកទី១៥ ការពិនិត្យតាមដាន និងវាយតម្លៃគ្រូបង្រៀនភាសាអង់គ្លេស .....45

# បញ្ជីពាក្យកាត់

| | | |
|---|---|---|
| ASEAN | : | Association of South-East Asian Nations |
| CAMSET | : | Cambodian Secondary English Teaching Project |
| CfBT Education Services | : | Centre for British Teachers Education Services |
| DFID | : | Department for International Development |
| EFA | : | Education for All |
| EFC | : | English for Cambodia |
| GPA | : | Grade Point Average |
| MoEYS | : | Ministry of Education, Youth and Sport |
| UNTAC | : | United Nations Transitonal Authority in Cambodia |

# ជំពូកទី១
# សេចក្ដីផ្ដើម

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

ភាសាអង់គ្លេស គឺជាភាសាសម្រាប់ពិភពលោកទាំងមូលអស់រយៈពេលជាងមួយសតវត្សមក ហើយៗវាត្រូវបានគេទទួលស្គាល់នៅក្នុងបណ្តាប្រទេសជាច្រើននៅជុំវិញពិភពលោក ។ វាក៏នឹងនៅតែបន្តតួនាទីឈានមុខគេដដែលនៅថ្ងៃអនាគត ។ មានអ្នកនិយាយភាសាអង់គ្លេសជនជាតិដើមប្រហែល ៣៣០ លាននាក់ និងអ្នកមិនមែនជនជាតិដើមប្រហែល ៤៣០ លាននាក់ (Crystal, 2003) ។ មនុស្សជាងពាក់កណ្តាលពិភពលោកជាអ្នកដែលចេះនិយាយពីរ ឬច្រើនភាសា (Grosjean, 2010) ។ វាពិតជាមិនអាចទៅរួចទេ ដែលគេធ្វើមិនដឹងមិនឮចំពោះឥទ្ធិពលរបស់វានៅគ្រប់ច្រកល្ហកនៃពិភពលោកនេះ ហើយវាតំណាងឱ្យការចម្រើនទៅមុខនៃសាកលភាវូបនីយកម្ម ។ វាបានជះឥទ្ធិពលដល់ប្រជាពលរដ្ឋនៅតាមបណ្តាប្រទេសផ្សេងៗជាច្រើនឱ្យរៀនភាសានេះ ដើម្បីជាភ្នាក់ងារផ្តល់ការប្រាស្រ័យទាក់ទងយ៉ាងទូលំទូលាយ ។ វាជាភាសាមួយដែលត្រូវបានគេរៀន និងនិយាយជាអន្តរជាតិសម្រាប់ការផ្លាស់ប្តូរវប្បធម៌នៅទូទាំងពិភពលោក ។ ឬអាចនិយាយបានថាភាសាអង់គ្លេសគឺជាយានដ៏សំខាន់មួយសម្រាប់ការផ្លាស់ប្តូរព័ត៌មាន និងទំនាក់ទំនងនៅក្នុងយុគសម័យសាកលភាវូបនីយកម្មនាពេលបច្ចុប្បន្ននេះ ព្រោះភាសាអង់គ្លេសគឺជាភាសាដែលគេប្រើច្រើនជាងគេនៅទូទាំងពិភពលោក (Crystal, 1997) ។ ទោះជាយ៉ាងណាក៏ដោយ Naisbitt និង Aburdence (1990) បានសង្កត់ធ្ងន់ទៅលើតួនាទីរបស់ភាសាអង់គ្លេសទាក់ទងនឹងភាសាក្នុងស្រុកថា: ភាសាអង់គ្លេសគឺមិនមែនកំពុងតែជំនួសភាសាក្នុងស្រុកនោះទេ ។ Hasman (2005) ក៏បាននិយាយដូចគ្នាដែរថា "វាអាចបន្ថែម ឬរួមគ្នាជាមួយភាសាក្នុងស្រុកដោយអនុញ្ញាតឱ្យជនចម្លែកៗ អាចធ្វើការប្រាស្រ័យទាក់ទងគ្នាពីប្រទេសមួយទៅប្រទេសមួយទៀតបាន ហើយនឹងបើកទ្វារចំហដល់ពិភពលោកដើម្បីចាប់យកឱកាស ព្រមទាំងពង្រីកផ្នត់គំនិតទទួលយកគំនិតថ្មី ។ សព្វថ្ងៃនេះ ភាសាអង់គ្លេសគឺជាភាសាបរទេសពេញនិយមបំផុតដែលត្រូវបានគេប្រើមិនត្រឹមតែនៅក្នុងផ្នែកនយោបាយប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងនៅក្នុងវិស័យអប់រំ និងពាណិជ្ជកម្មអន្តរជាតិផងដែរ (Igawa, 2008) ។ ដោយឡែក ភាសាអង់គ្លេសគឺជាភាសាការងារផ្លូវការតែមួយគត់នៃសមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ ដែលផ្តល់នូវការលើកទឹកចិត្តយ៉ាងខ្លាំងដល់ប្រទេសកម្ពុជាដើម្បីអភិវឌ្ឍន៍ទុនភាសាអង់គ្លេស (Clayton, 2007) ។

ក្នុងបរិបទកម្ពុជាវិញ ភាសាអង់គ្លេសត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សាមធ្យមសិក្សាក្នុងឆ្នាំ1989 (Vira, 2002) ។ មុនពេលនោះ ភាសាបារាំងគឺជាភាសាបរទេសដែលលេចធ្លោ ។ គួរកត់សម្គាល់ផងដែរថា នៅក្នុងប្រទេសកម្ពុជា ភាសាអង់គ្លេមិនត្រឹមតែត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សាសាលាសាធារណៈតែប៉ុណ្ណោះទេ ប៉ុន្តែវាក៏ត្រូវបានគេប្រើប្រាស់សម្រាប់មុខវិជ្ជាជាក់លាក់ជាច្រើននៅតាមសាកលវិទ្យាល័យនានាក៏ដូចជាសម្រាប់ទីផ្សារការងារផងដែរ ។

ដោយមើលឃើញច្បាស់ពីសារៈសំខាន់ និងភាពចំបាច់នៃភាសាអង់គ្លេសនេះហើយ ទើបក្រសួងអប់រំ យុវជន និងកីឡា ក្រោមការឧបត្ថម្ភរបស់រដ្ឋាភិបាលអង់គ្លេសតាមរយៈគម្រោងនៃការបង្រៀនភាសាអង់គ្លេសកម្រិតមធ្យមសម្រាប់កម្ពុជា (CAMSET) បានផលិតចេញនូវសៀវភៅសិក្សាគោល

សម្រាប់សាលាមធ្យមសិក្សាជាលើកដំបូង ដែលបានដាក់ឱ្យប្រើប្រាស់សាកល្បងនៅចុងទសវត្សឆ្នាំ1990 និងដើមទសវត្សឆ្នាំ2000 ក្នុងគោលបំណងកសាងសមត្ថភាពសិស្សានុសិស្សកម្ពុជាដើម្បីបម្រើឱ្យសេចក្ដីត្រូវការរបស់ប្រទេសជាតិទៅថ្ងៃអនាគត ។ គម្រោងនេះចាត់ចែងដោយ CfBT Education Services ។ តាមរយៈគម្រោងនេះ ក្រសួងអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសអង់គ្លេស (DFID) បានផ្ដល់មូលនិធិសម្រាប់ការអភិវឌ្ឍកម្មវិធីសិក្សា ការបណ្ដុះបណ្ដាលគ្រូ ការរៀបចំប្រព័ន្ធអធិការកិច្ចសាលារៀន និងការបណ្ដុះណ្ដាលផ្នែកអ្នកនិពន្ធ ផ្នែករៀបរៀង ព្រមទាំងការបោះពុម្ព និងផ្នែកចែកផ្សាយសៀវភៅទាំងនេះផងដែរ ។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

ចាប់តាំងពីពិភពលោកបានក្លាយទៅជាសាកលភាវូបនីយកម្មមក ទំនាក់ទំនង បច្ចេកវិទ្យាព័ត៌មាន វប្បធម៌ និងប្រព័ន្ធសេដ្ឋកិច្ចសង្គមផ្សេងៗត្រូវបានចែករំលែក និងត្រូវបានធ្វើឡើងជាភាសាអង់គ្លេស ។ ភាសាអង់គ្លេសត្រូវបានគេប្រើទូទាំងពិភពលោកដើម្បីបំពេញតម្រូវការទីផ្សារការងារ ។ ដូច្នេះ ភាសានេះបានក្លាយទៅជាឧបករណ៍សម្រាប់ភ្ជាប់សង្គមការងារទៅនឹងសាកលភាវូបនីយកម្ម ។ គេសង្កេតឃើញថា ភាសាអង់គ្លេសមានប្រជាប្រិយភាពគួរឱ្យកត់សម្គាល់ក្នុងចំណោមសិស្សកម្ពុជាជាពិសេសចាប់តាំងពីការប្រកាសគោលនយោបាយអប់រំសម្រាប់ទាំងអស់គ្នា (EFA) ពីរដ្ឋាភិបាលឆ្នាំ 1990 កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសនៅឆ្នាំ1991 វត្តមានរបស់អាជ្ញាធរអន្តរកាលសហប្រជាជាតិនៅកម្ពុជា (UNTAC) ក្នុងអំឡុងឆ្នាំ1992-1993 ការដាក់បញ្ចូលសេដ្ឋកិច្ចសាកលក្នុងតំបន់ សហគមន៍ជំនួយអន្តរជាតិ (Clayton, 2009) និងសមាជិកភាពពេញសិទ្ធិនៃសមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ (ASEAN) នៅឆ្នាំ1999 (Igawa, 2008) ។ លើសពីនេះទៅទៀត ភាសាអង់គ្លេសគឺជាភាសាផ្លូវការតែមួយគត់សម្រាប់សមាគមន៍នេះ ហើយវាមិនត្រឹមតែកំណត់ចំពោះនយោបាយប៉ុណ្ណោះទេ ប៉ុន្តែវាក៏មានសារៈសំខាន់ផងដែរនៅក្នុងវិស័យសេដ្ឋកិច្ច និងវិស័យផ្សេងទៀតផងដែរ (Igawa, 2008) ។ រដ្ឋាភិបាល និងប្រជាជនកម្ពុជាបានជ្រើសរើសភាសាអង់គ្លេសជាភាសាបរទេសដើម្បីធ្វើការទំនាក់ទំនង និងធ្វើអាជីវកម្មជាមួយមនុស្ស អង្គការ និងក្រុមហ៊ុនមកពីបរទេស ។ ក្នុងន័យនេះ ប្រទេសកម្ពុជាបង្ហាញពីឧទាហរណ៍ច្បាស់លាស់នៃគោលនយោបាយភាសា និងផលប៉ះពាល់របស់វាទៅលើជីវភាពរស់នៅរបស់ប្រជាជន ការអប់រំ និងអនាគតនៃប្រទេសដែលកំពុងតែផ្លាស់ប្ដូរ (Igawa, 2008) ។

ក្រសួងអប់រំយុវជននិងកីឡា (MoEYS) បានដឹងថាប្រជាជនកម្ពុជាគ្រប់ស្រទាប់វណ្ណៈមានឆន្ទៈក្នុងការរៀនភាសាអង់គ្លេស ហើយមិនត្រូវមានការពន្យារពេលណាមួយឡើយ ។ ប៉ុន្តែការសិក្សាភាសានេះត្រូវចាប់ផ្ដើមពីមូលដ្ឋានធនធានទាបបំផុត ដោយគ្មានកម្មវិធីសិក្សា គ្មានសៀវភៅសិក្សា ហើយគ្រូបង្រៀនភាសាអង់គ្លេសនៅកម្ពុជាមានចំនួនតិចតួច (Pith, 1996) ។ ក្រសួងបានដាក់មុខវិជ្ជាភាសាអង់គ្លេសទៅក្នុងកម្មវិធីសិក្សាសាលាមធ្យមសិក្សារដ្ឋតាំងពីឆ្នាំ1989 (Vira, 2002) ។

សព្វថ្ងៃនេះ ភាសាអង់គ្លេសត្រូវបានប្រើសម្រាប់ការបង្រៀនជាភាសាបរទេសរយៈពេល 3 ឆ្នាំនៅកម្រិតអនុវិទ្យាល័យ និង 3 ឆ្នាំទៀតនៅកម្រិតវិទ្យាល័យ ។ សិស្សទាំងអស់ត្រូវបានបង្រៀនភាសាអង់គ្លេសជាផ្លូវការរយៈពេល 6 ឆ្នាំមុនពេលពួកគេបញ្ចប់ថ្នាក់វិទ្យាល័យ ។ សិស្សដែលមានកម្រិត

ជំនាញភាសាអង់គ្លេសកម្រិតខ្ពស់ពីវិទ្យាល័យមក ពួកគេមានឱកាសទទួលបានភាពជោគជ័យនៅកម្រិតសាកលវិទ្យាល័យជាង (Nith, 2004) ។

នៅអនុវិទ្យាល័យ និងវិទ្យាល័យ ចាប់ពីថ្នាក់ទី 7 ដល់ថ្នាក់ទី 12 ក្រសួងអប់រំ យុវជន និងកីឡា បានប្រើប្រាស់ស៊េរីសៀវភៅដែលមានឈ្មោះថា English for Cambodia (ភាសាអង់គ្លេសសម្រាប់កម្ពុជា) ដើម្បីបង្រៀនសិស្ស ហើយដែលត្រូវបានដាក់ឱ្យសាកល្បងដំបូងនៅក្នុងឆ្នាំសិក្សា1996-1997 (MoEYS, 1999) ។ មុនពេលបោះពុម្ពផ្សាយសៀវភៅ English for Cambodia (EFC) ស៊េរីសៀវភៅជាច្រើនដូចជា Headway, English for Today, និង Streamline ជាដើម ត្រូវបានប្រើដើម្បីបង្រៀនសិស្សនៅអនុវិទ្យាល័យ និងវិទ្យាល័យនៅកម្ពុជា ។ មិនយូរប៉ុន្មាន បន្ទាប់ពីគម្រោងជាច្រើនត្រូវបានរៀបចំឡើងដើម្បីអភិវឌ្ឍសៀវភៅភាសាអង់គ្លេសសមស្របសម្រាប់ប្រទេសកម្ពុជា ស៊េរីសៀវភៅសិក្សា EFC ត្រូវបានបោះពុម្ពផ្សាយជា 6 កម្រិតដែលកម្រិតនីមួយៗមួយត្រូវបានកំណត់សម្រាប់មួយឆ្នាំសិក្សាទាំងមូលនៃថ្នាក់នីមួយៗនៅតាមសាលាអនុវិទ្យាល័យ និងវិទ្យាល័យនៅប្រទេសកម្ពុជា ។ សៀវភៅស៊េរីនេះត្រូវបានបោះពុម្ពដាច់ៗពីគ្នា និងតាមលំដាប់ដូចតទៅ៖ EFC Book 1, 1996; EFC Book 2, 1997; EFC Book 3, 1998; EFC Book 4, 1999; EFC Book 5, 2000 និងចុងក្រោយ EFC Book 6, 2001 (Vira, 2002) ។

យ៉ាងណាក៏ដោយ ចាប់តាំងពីការដាក់បញ្ចូលមុខវិជ្ជាភាសាអង់គ្លេសទៅក្នុងកម្មវិធីសិក្សានៅមធ្យមសិក្សានៅឆ្នាំ1989 (Vira, 2002) មក មិនទាន់មានការសិក្សាណាមួយទៅលើឥរិយាបថរបស់សិស្សចំពោះភាសានេះនៅឡើយទេ ។ ហេតុដូច្នេះហើយ នៅក្នុងការសិក្សានេះ អ្នកសិក្សានឹងធ្វើការសិក្សាស្វែងយល់ពីឥរិយាបថរបស់សិស្សចំពោះមុខវិជ្ជាភាសាអង់គ្លេសនៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ចាម ដោយពិនិត្យលើឥរិយាបថរួម និងធ្វើការប្រៀបធៀបឥរិយាបថរបស់សិស្សដោយផ្អែកលើភេទ កម្រិតថ្នាក់ និងតំបន់ ។ បន្ថែមពីលើនេះទៀត អ្នកសិក្សាក៏នឹងរកឱ្យឃើញនូវបញ្ហាប្រឈមនានាក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ចាមនា ពេលបច្ចុប្បន្នផងដែរ ។

### ១.៣ គោលបំណងនៃស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទនេះមានគោលបំណង៖

១. សិក្សាស្វែងយល់ពីឥរិយាបថរបស់សិស្សចំពោះមុខវិជ្ជាភាសាអង់គ្លេសនៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ចាម ។

២. រកភាពខុសគ្នារវាងឥរិយាបថរបស់សិស្សចំពោះមុខវិជ្ជាភាសាអង់គ្លេសទៅតាមភេទ កម្រិតថ្នាក់ និងតំបន់ ។

៣. រកឱ្យឃើញនូវបញ្ហាប្រឈមនានាក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ចាមនាពេលបច្ចុប្បន្ន ។

### ១.៤ សំណួរស្រាវជ្រាវ

ការសិក្សានេះត្រូវបានធ្វើឡើងនៅសាលាកម្រិតមធ្យមសិក្សាបឋមភូមិ ដើម្បីឆ្លើយទៅនឹងសំណួរស្រាវជ្រាវចំនួនបីដូចខាងក្រោម៖

១. តើសិស្សនៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ចាម មានឥរិយាបថដូចម្តេចខ្លះចំពោះមុខវិជ្ជាភាសាអង់គ្លេស?

២. បើគិតតាមភេទ កម្រិតថ្នាក់ និងតំបន់ តើសិស្សនៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ចាម មានឥរិយាបថខុសគ្នាឬទេចំពោះមុខវិជ្ជាភាសាអង់គ្លេស?

៣. តើអ្វីខ្លះជាបញ្ហាប្រឈមក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ចាមនាពេលបច្ចុប្បន្ន?

## ១.៥ សារៈសំខាន់នៃការស្រាវជ្រាវ

ភាសាអង់គ្លេសជាមុខវិជ្ជាសំខាន់មួយក្នុងចំណោមមុខវិជ្ជាសិក្សាគោលដទៃទៀត ដែលមាននៅក្នុងកម្មវិធីសិក្សាសម្រាប់សិស្សកម្រិតមធ្យមសិក្សា ។ មុខវិជ្ជានេះត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សាតាំងពីឆ្នាំ1989 មកម្លេះ (Vira, 2002) ។ ថ្មីៗនេះ ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើការសិក្សាស្រាវជ្រាវពីលទ្ធភាពក្នុងការដាក់មុខវិជ្ជានេះទៅជាមុខវិជ្ជាកតព្វកិច្ចក្នុងការប្រឡងសញ្ញាបត្រទាំងមធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិ ។ ដូចនេះការសិក្សានេះនឹងធ្វើឱ្យយើងៈ

១. ដឹងពីឥរិយាបថពិតប្រាកដរបស់សិស្សចំពោះមុខវិជ្ជាភាសាអង់គ្លេសនៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ចាម ។

២. រកឃើញនូវភាពខុសគ្នា ឬដូចគ្នានៃឥរិយាបថរបស់សិស្សចំពោះមុខវិជ្ជាភាសាអង់គ្លេសនៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ចាម ។

៣. រកឃើញនូវបញ្ហាប្រឈមនានាក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ចាម ។

ការយល់ដឹងពីឥរិយាបថរបស់សិស្សបានច្បាស់លាស់ រកឃើញនូវភាពខុសគ្នា ឬដូចគ្នានៃឥរិយាបថរបស់សិស្ស និងការរកឃើញនូវបញ្ហាប្រឈមនានាដែលសិស្សជួបប្រទះក្នុងការសិក្សាភាសាអង់គ្លេស អាចនឹងជួយឱ្យគ្រូបង្រៀនភាសាអង់គ្លេស អ្នកអប់រំ ក៏ដូចជាអ្នកពាក់ព័ន្ធនានាយល់ពីតម្រូវការរបស់អ្នកសិក្សាកាន់តែច្បាស់ដើម្បីធ្វើការកែលម្អ និងជម្នះនូវរាល់ការលំបាកទាំងអស់នោះតាមដែលអាចធ្វើទៅបាន ។

## ១.៦ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

ការសិក្សានេះ នឹងត្រូវធ្វើឡើងនៅសាលាគោលដៅចំនួន ១៥ ដែលក្នុងនោះមានវិទ្យាល័យ ៥ និងអនុវិទ្យាល័យ ១០ នៅក្នុងក្រុង/ស្រុកចំនួន ៦ នៃខេត្តកំពង់ចាម ដោយ ១ ស្រុករើសយក ៣ សាលា (១ នៅទីប្រជុំជន ឬទីរួមស្រុក ១ នៅពាក់កណ្តាលទីប្រជុំជន ឬទីរួមស្រុក និង ១ ទៀតនៅទីជនបទ ឬតំបន់ដាច់ស្រយាលបំផុត) លើកលែងតែក្រុងកំពង់ចាម ដោយយកតែវិទ្យាល័យ ១ គត់គឺ វិទ្យាល័យព្រះសីហនុ ព្រោះក្នុងក្រុងកំពង់ចាមមិនមានអនុវិទ្យាល័យទេ និងស្រុកកំពង់សៀម ដោយយកតែ ២ អនុវិទ្យាល័យ ដែលនៅជិតទីរួមខេត្តជាងគេ ដើម្បីរួមគ្នាជាមួយក្រុងកំពង់ចាមធ្វើជា ១ ស្រុក ។ សាលាទាំងនោះរួមមានៈ ១) ក្រុងកំពង់ចាម មាន ១ សាលាគឺ វិទ្យាល័យព្រះសីហនុ ។ ២) ស្រុកកំពង់សៀម មាន ២ សាលាគឺ អនុវិទ្យាល័យអង្គរ និងអនុវិទ្យាល័យថ្មគោល ។ ៣) ស្រុកកោះសូទិន មាន ៣ សាលាគឺ វិទ្យាល័យជីហែ អនុវិទ្យាល័យល្វេ និងអនុវិទ្យាល័យព្រែកតានង់ ។ ៤) ស្រុកព្រៃឈរ មាន ៣ សាលា

គឺ វិទ្យាល័យនរោត្តមរណឫទ្ធិ-គន្ធបុប្ផា អនុវិទ្យាល័យខ្វិតធំ និងអនុវិទ្យាល័យប្រិមប្រីយ៍ ។ ៥) ស្រុកបាធាយ មាន ៣ សាលាគឺ វិទ្យាល័យហោណាំហុងព្រៃញា អនុវិទ្យាល័យទំនប់ និង អនុវិទ្យាល័យគ្រប់ និង៦) ស្រុកស្រីសន្ធរ មាន ៣ សាលាគឺវិទ្យាល័យស្រីសន្ធរ អនុវិទ្យាល័យបារាយណ៍ និងអនុវិទ្យាល័យស្វាយពោធិ៍ ។ ការសិក្សានេះនឹងជួបជាមួយនាយកសាលាសរុបចំនួន ១៥ នាក់ ដោយ ១ សាលាយក ១ នាក់ គ្រូបង្រៀនភាសាអង់គ្លេសសរុបចំនួន ៤៥ នាក់ ដោយ ១ សាលាយកគ្រូ ៣ នាក់ (គ្រូថ្នាក់ទី៧, ទី៨ និងទី៩) និងសិស្សសរុបចំនួន ៤៥០ នាក់ ដោយ ១ សាលាយកសិស្ស ៣០ នាក់ (ថ្នាក់ទី៧ ចំនួន ១០ នាក់, ថ្នាក់ទី៨ ចំនួន ១០ នាក់ និងថ្នាក់ទី៩ ចំនួន ១០នាក់) ។

## ១. ៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះចែកចេញជា ៥ ជំពូកដូចខាងក្រោម៖

❖ ***ជំពូកទី១៖ សេចក្តីផ្តើម:*** ពណ៌នាដោយសង្ខេបទៅលើលំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

❖ ***ជំពូកទី២៖ រំឭកទ្រឹស្តី:*** ធ្វើការបង្ហាញ និងពន្យល់យ៉ាងលម្អិតទៅលើទ្រឹស្តីទាំងឡាយ ដែលជាប់ទាក់ទងទៅនឹងឥរិយាបថរបស់សិស្សចំពោះការសិក្សាភាសាអង់គ្លេស ។

❖ ***ជំពូកទី៣៖ វិធីសាស្ត្រនៃការស្រាវជ្រាវ:*** ជំពូកនេះលើកឡើងពីវិធីសាស្ត្រនៃការស្រាវជ្រាវ និងគម្រោងនៃការវិភាគ ការកំណត់ពេលវេលា និងទីកន្លែងដែលត្រូវសិក្សា ការជ្រើសរើសវិធីសាស្ត្រប្រមូលទិន្នន័យ ការវិភាគសំណាក ការប្រើប្រាស់ឧបករណ៍ស្ថិតិ និងការប្រើរូបមន្តសម្រាប់គណនា ។

❖ ***ជំពូកទី៤៖ លទ្ធផល និងការពិភាក្សា:*** ជំពូកនេះអ្នកស្រាវជ្រាវនឹងធ្វើការវិភាគយ៉ាងលម្អិតទៅលើកម្រងសំណួរសម្រាប់យកមកវិភាគទិន្នន័យ ធ្វើការបកស្រាយទិន្នន័យដែលប្រមូលបានជាក់ស្តែង ដើម្បីរកឱ្យឃើញពីកម្រិតនៃឥរិយាបថរបស់សិស្សចំពោះមុខវិជ្ជាភាសាអង់គ្លេស ភាពខុសគ្នា ឬដូចគ្នានៃឥរិយាបថរបស់សិស្ស និងបញ្ហាប្រឈមនានាក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ចាម ។

❖ ***ជំពូក្សទី៥៖ សេចក្តីសន្និដ្ឋាន និងសំណូមពរ:*** ធ្វើការសន្និដ្ឋានទៅលើគ្រប់ចំណុចទាំងអស់ដែលបានវិភាគ និងផ្តល់ជាយោបល់ទៅលើចំណុចត្រូវកែលម្អ ឬចំណុចខ្វះខាត។

# ជំពូកទី២
# រំឮកទ្រឹស្តី

# ជំពូកទី២
# រំឮកទ្រឹស្តី

## ២.១ និយមន័យនៃឥរិយាបថ

ឥរិយាបថគឺជាប្រតិកម្មតប ឬជាការវាយតម្លៃរបស់បុគ្គលម្នាក់ៗទៅលើស្ថានភាពជាក់លាក់ ឬវត្ថុអ្វីមួយដោយផ្អែកលើគំនិត និងជំនឿរបស់គេផ្ទាល់ (Abidin, Mohammadi & Alzwari 2012) ។ ចំណែកឯ ALNorsi (2013) និង Eshghinejad (2016) វិញ និយាយថា ឥរិយាបថត្រូវបានគេមើលឃើញថាជាដំណើរការនៃចិត្តសាស្ត្រដែលអ្នកសិក្សាពេញចិត្ត ឬមិនពេញចិត្តចំពោះស្ថានភាពជាក់លាក់ណាមួយ ។ Al-Mamun, Rahman, Rahman, and Hossaim (2012) បានកំណត់និយមន័យនៃឥរិយាបថថាជាសំណង់ចិត្តសាស្ត្រដែលកំណត់នូវអាកប្បកិរិយាជាក់លាក់ ។ ចំណែក Brown (2001) ឥរិយាបថត្រូវបានកំណត់លក្ខណៈដោយការជាប់ពាក់ព័ន្ធនឹងភាពរំជួលចិត្តមួយភាគធំ ដូចជាអារម្មណ៍ខ្លួនឯង និងទំនាក់ទំនងនៅក្នុងសហគមន៍ ។ ការរៀនសូត្រមិនអាចកើតមានដោយស្រួលទេ ប្រសិនបើសិស្សមិនមានឥរិយាបថវិជ្ជមានចំពោះការសិក្សា ហើយម៉្យាងវិញទៀតឥរិយាបថក៏អាចមានប្រភពមកពីបទពិសោធន៍ផ្សេងៗនៃជីវិត ។ ដូចនេះ ក្នុងការសិក្សាឥរិយាបថដើរតួនាទីសំខាន់ណាស់ ដោយសារវាអាចជះឥទ្ធិពលដល់ភាពជោគជ័យ ឬភាពបរាជ័យរបស់អ្នកសិក្សា ។ Ajzen (2005) ជឿជាក់ថា ដូចគ្នានឹងបុគ្គលិកលក្ខណៈ ឥរិយាបថគឺជាសំណង់សម្មតិកម្មដែលមិនបានសង្កេតដោយផ្ទាល់ ហើយត្រូវបានគេសន្និដ្ឋានពីការឆ្លើយតបដែលអាចវាស់វែងបានដែលឆ្លុះបញ្ចាំង និងវាយតម្លៃឥរិយាបថវិជ្ជមានឬអវិជ្ជមាន ។ Gardner (1980) កំណត់និយមន័យថា ឥរិយាបថជាផលបូកនៃសភាវគតិ និងអារម្មណ៍របស់មនុស្ស ការរើសអើង ឬលម្អៀង សញ្ញាណគិតទុកជាមុន ការភ័យខ្លាច ការគំរាមកំហែង និងការព្រមព្រៀងអំពីប្រធានបទណាមួយជាក់លាក់។

Ajzan បានអះអាងថាឥរិយាបថរបស់បុគ្គលណាម្នាក់គឺជាលក្ខណៈវិជ្ជមាន ឬអវិជ្ជមានចំពោះអ្វីមួយ (Ajzan, 1988) ។ ឥរិយាបថជារបៀបនៃការប្រព្រឹត្តដែលស្ថិតស្ថេររបស់បុគ្គលណាម្នាក់ទៅតាមរបៀបណាមួយ (Baker, 1992) ។ ឥរិយាបថគឺជាធាតុដ៏សំខាន់ក្នុងការសិក្សាភាសា (Gardner, 1985) ។ Wenden និយាយថាឥរិយាបថមានធាតុបីគឺ អារម្មណ៍ ការយល់ដឹង និងអាកប្បកិរិយា ។ ឥរិយាបថយល់ដឹងបង្កើតដោយជំនឿជាក់ និងគំនិត ឬការយល់ឃើញអំពីអ្វីមួយ ។ ចំពោះឥរិយាបថអារម្មណ៍សំដៅទៅលើអារម្មណ៍ ឬភាពរំជួលចិត្តដែលនរណាម្នាក់មានចំពោះអ្វីមួយថាតើគេចូលចិត្ត ឬមិនចូលចិត្ត ។ រីឯឥរិយាបថបែបអាកប្បកិរិយាវិញសំដៅទៅលើសកម្មភាព ឬជាប្រតិកម្មត្រឡប់របស់នរណាម្នាក់ទៅលើអ្វីមួយ (Wenden, 1991) ។

ការរៀនភាសាមួយគឺវាមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងឥរិយាបថចំពោះភាសា (Starks and Paltridge, 1996) ។

ឥរិយាបថគឺជាការបង្ហាញនូវការភ័យខ្លាច អារម្មណ៍ ឬសេចក្តីលម្អៀងអំពីការរៀនភាសាអង់គ្លេសជាភាសាទី២ (Spolsky, 2000) ។ ជាទូទៅ វាត្រូវបានគេជឿថាឥរិយាបថ បំណិន និងយុទ្ធសាស្ត្ររបស់អ្នកសិក្សាកំណត់ថាតើពួកគេអាចស្រូបយកនូវភាពស្មុគស្មាញនៃភាសាបានដែរ ឬទេ (Oxford, 1990; Nunan, 2000) ។

Ajzen (2005) គាត់បាននិយាយថាឥរិយាបថគឺជាទំនោរឆ្លើយតបគាំទ្រ ឬមិនគាំទ្រចំពោះវត្ថុ បុគ្គល ស្ថាប័ន ឬព្រឹត្តិការណ៍ណាមួយ ។

Karahan (2007) និយាយថាឥរិយាបថវិជ្ជមានចំពោះភាសានាំឱ្យអ្នកសិក្សាមានការតម្រង់ទិសដ៏ល្អចំពោះការសិក្សាភាសាអង់គ្លេស ។

ឥរិយាបថត្រូវបានគេទទួលស្គាល់ថា ជាគោលគំនិតសំខាន់ដើម្បីយល់ពីអាកប្បកិរិយារបស់មនុស្សហើយក៏ត្រូវបានគេឱ្យនិយមន័យថា ជាសភាពនៃចិត្តដែលរាប់បញ្ចូលទាំងជំនឿ និងអារម្មណ៍ (Latchanna & Dagnew, 2009) ។

នៅក្នុងការសិក្សានេះ អ្នកសិក្សាកំណត់យកតាមនិយមន័យរបស់លោក (Wenden, 1991) ដោយហេតុថាក្នុងការសិក្សានេះអ្នកសិក្សាចង់ដឹងពីកម្រិតនៃការចូលចិត្ត កម្រិតនៃការយល់ដឹង និងទង្វើរបស់សិស្សនៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ចាមចំពោះមុខវិជ្ជាភាសាអង់គ្លេស ។

## ២.២ លក្ខណៈទូទៅនៃឥរិយាបថ

អ្នកស្រាវជ្រាវភាគច្រើនដែលបាននិយាយអំពីបញ្ហាឥរិយាបថ និងការលើកទឹកចិត្តបានសន្និដ្ឋានថាឥរិយាបថរបស់សិស្សគឺជាផ្នែកសំខាន់មួយនៃការសិក្សា ។ ដូច្នេះហើយ វាគួរតែក្លាយជាសមាសភាគដ៏សំខាន់មួយខាងគរុកោសល្យនៃការសិក្សាភាសាទីពីរ (Inal, et al, 2003) ។ លើសពីនេះទៀត ពួកគេបាននិយាយពីហេតុផលជាច្រើនអំពីមូលហេតុថាហេតុអ្វីបានជាការស្រាវជ្រាវលើឥរិយាបថរបស់សិស្សចំពោះការសិក្សាភាសាបរទេសមានសារៈសំខាន់ ។ ក្នុងចំណោមចំណុចទាំងនេះមានដូចខាងក្រោម៖ ទី១ ឥរិយាបថចំពោះការសិក្សាត្រូវបានគេជឿថាមានឥទ្ធិពលលើអាកប្បកិរិយា (Kaballa and Crowley, 1985) ។ ទី២ ទំនាក់ទំនងរវាងឥរិយាបថ និងសមិទ្ធផលត្រូវបានបង្ហាញថាមាន ។

តាមពិត ការរកឃើញនូវឥរិយាបថ និងការលើកទឹកចិត្តរបស់សិស្សអំពីភាសានឹងជួយទាំងគ្រូទាំងសិស្សក្នុងដំណើរការនៃការបង្រៀន និងរៀន។

ចំណាប់អារម្មណ៍ក្នុងការសិក្សាពីការលើកទឹកចិត្ត និងឥរិយាបថខាងចិត្តវិទ្យា និងការអប់រំ បានកើតមានតាំងពីដើមនៃសតវត្សទី២០ ដែលគ្រូបង្រៀនភាសា និងអ្នកស្រាវជ្រាវជាច្រើនបានសន្មតថាឥរិយាបថ និងការលើកទឹកចិត្តជះឥទ្ធិពលដល់ភាពជោគជ័យនៃការអប់រំរបស់សិស្សជាទូទៅ (Dornyei, 2001, Gander, 2006) ។

ឥរិយាបថមិនសមរម្យចំពោះការសិក្សាភាសាអាចបង្អាក់ទឹកចិត្តរបស់អ្នកសិក្សា ហើយរារាំងដល់ការសិក្សាភាសា ខណៈដែលឥរិយាបថវិជ្ជមានអាចផ្តល់លទ្ធផលផ្ទុយពីនេះ ។ ដូចេនះ វាជាការសំខាន់សម្រាប់គ្រូបង្រៀនភាសាក្នុងការពិនិត្យមើលឥរិយាបថសិស្សរបស់គាត់ (Oxford, 2001) ។

### ២.២.១ ទិដ្ឋភាពនៃឥរិយាបថ

#### *២.២.១.១ ទិដ្ឋភាពនៃឥរិយាបថអារម្មណ៍*

Wenden (1991) ឥរិយាបថអារម្មណ៍គឺសំដៅលើអារម្មណ៍ ឬភាពរំជួលចិត្តដែលនរណាម្នាក់មានទៅលើអ្វីមួយ (ចូលចិត្ត ឬមិនចូលចិត្ត ស្រប ឬប្រឆាំង) ។ Feng និង Chen (2009) បាននិយាយថា ដំណើរការនៃការសិក្សាគឺជាដំណើរការនៃអារម្មណ៍ ។ វាត្រូវបានប៉ះពាល់ដោយកត្តានៃអារម្មណ៍ខុសៗគ្នា ។ គ្រូបង្រៀន និងសិស្សរបស់គាត់ចូលរួមក្នុងសកម្មភាពនៃអារម្មណ៍ផ្សេងៗគ្នា ។ ឥរិយាបថ

អាចជួយឱ្យសិស្សបង្ហាញថាតើពួកគេចូលចិត្ត ឬមិនចូលចិត្តវត្ថុ ឬស្ថានភាពជុំវិញ ។ វាត្រូវបានគេយល់ស្របគ្នាថាអារម្មណ៍ខាងក្នុង និងអារម្មណ៍នៃសិស្សភាសាបរទេស មានឥទ្ធិពលលើទស្សនវិស័យ និងឥរិយាបថរបស់ពួកគេចំពោះភាសាគោលដៅ (Choy & Troudi, 2006) ។

#### *២.២.១.២ ទិដ្ឋភាពនៃឥរិយាបថយល់ដឹង*

សមាសធាតុនៃឥរិយាបថយល់ដឹងត្រូវបានបង្កើតឡើងដោយជំនឿ និងទស្សនៈ ឬគំនិតអំពីអ្វីមួយ (Wenden, 1991) ។ ទិដ្ឋភាពនៃឥរិយាបថយល់ដឹងជាប់ទាក់ទងទៅនឹងជំនឿរបស់សិស្សដែលរៀនភាសា អំពីចំណេះដឹងដែលពួកគេទទួល និងការយល់ដឹងរបស់ពួកគេក្នុងដំណើរការនៃការរៀនភាសា ។ ឥរិយាបថនៃការយល់ដឹងអាចត្រូវបានចាត់ថ្នាក់ជាបួនជំហាន៖ ការផ្សារភ្ជាប់ចំណេះដឹងពីមុន និងចំណេះដឹងថ្មី ការបង្កើតចំណេះដឹងថ្មី ការត្រួតពិនិត្យចំណេះដឹងថ្មី និងការអនុវត្តចំណេះដឹងថ្មីនៅក្នុងស្ថានភាពជាច្រើន ។

ជំនឿជាចំណុចសំខាន់ដែលជាប់ទាក់ទងទៅនឹងការសិក្សារបស់សិស្ស (Ajzen, 1988) ។ ជំនឿរបស់សិស្សអាចជាឧបសគ្គប្រសិនបើពួកគេជឿថាពួកគេមិនអាចរៀនភាសាថ្មីបានដោយជោគជ័យនោះទេ ។

លោក Seyed Yousef Savaedi និង Sedigheh Vahdat (2017) ដែលបានពិនិត្យមើលឥរិយាបថរបស់សិស្សមធ្យមសិក្សាបឋមភូមិរបស់ប្រទេសអ៊ីរ៉ង់ចំនួន ៨០ នាក់ បានបង្ហាញថាជំនឿជាក់អំពីចំណេះដឹង និងការយល់ដឹងរបស់ពួកគេចំពោះភាសាអង់គ្លេសមានលក្ខណៈវិជ្ជមាន ។ ពួកគេក៏យល់ទៀតថា ការដែលពូកែខាងភាសាអង់គ្លេសនឹងជួយឱ្យពួកគេរៀនមុខវិជ្ជាដទៃទៀតបានយ៉ាងងាយស្រួល ហើយពួកគេរៀនភាសាអង់គ្លេសមិនមែនដើម្បីឱ្យតែប្រឡងជាប់នោះទេ គឺពួកគេរៀនដោយមានគោលបំណងដើម្បីធ្វើការទំនាក់ទំនងគ្នានៅពេលពួកគេចេញពីសាលាទៀតផង ។

#### *២.២.១.៣. ទិដ្ឋភាពនៃឥរិយាបថបែបអាកប្បកិរិយា*

ឥរិយាបថបែបអាកប្បកិរិយាសំដៅលើសកម្មភាព ឬគោលចំណងរបស់នរណាម្នាក់ចំពោះអ្វីមួយ (Wenden, 1991) ។ ទិដ្ឋភាពអាកប្បកិរិយានៃឥរិយាបថទាក់ទងទៅនឹងរបៀបដែលមនុស្សប្រព្រឹត្ត និងប្រតិកម្មទៅតាមស្ថានភាពជាក់ស្តែង ។ តាមការពិត ការរៀនភាសាដោយជោគជ័យជួយលើកស្ទួយសិស្សឱ្យកំណត់អត្តសញ្ញាណខ្លួនឯងជាមួយអ្នកនិយាយភាសាដើម និងទទួលបាន ឬចាប់យកទិដ្ឋភាពផ្សេងៗនៃអាកប្បកិរិយាដែលបង្ហាញលក្ខណៈជាសមាជិកនៃសហគមន៍ភាសាគោលដៅ ។ Kara (2009) និយាយថា ឥរិយាបថវិជ្ជមាននាំឱ្យមានការបង្ហាញចេញនូវអាកប្បកិរិយាវិជ្ជមានចំពោះមុខវិជ្ជាសិក្សា ដែលអ្នកចូលរួមស្រូបទាញខ្លួនឯងចូលទៅក្នុងការសិក្សា និងខិតខំកាន់តែខ្លាំង ។ សិស្សបែបនេះក៏ត្រូវបានគេសង្កេតឃើញថាមានបំណងចង់ដោះស្រាយបញ្ហាដើម្បីទទួលបាននូវព័ត៌មាន និងជំនាញដែលមានប្រយោជន៍សម្រាប់ជីវិតប្រចាំថ្ងៃ និងដើម្បីចូលរួមដោយខ្លួនឯងប្រកបដោយភាពរំភើបចិត្ត ។

### ២.២.២ របកគំហើញនៃការសិក្សាអំពីឥរិយាបថ

មានអ្នកសិក្សាជាច្រើនដែលបានធ្វើការសិក្សាអំពីឥរយាបថរបស់សិស្សចំពោះការសិក្សាភាសា ក្នុងនោះរួមមាន៖

Chamber (1999) និយាយថាការសិក្សាភាសានឹងប្រព្រឹត្តទៅបានល្អពេលអ្នកសិក្សាមានឥរិយាបថវិជ្ជមាន ។

ការសិក្សាធ្វើឡើងដោយ Burden (2004) បង្ហាញថាឥរិយាបថវិជ្ជមាននឹងលើកទឹកចិត្តអ្នកសិក្សាឱ្យសម្រេចបាននូវគោលបំណងនៃការសិក្សារបស់ពួកគេ ។

អ្នកស្រាវជ្រាវជឿជាក់ថា ឥរិយាបថបង្កើតនូវចំណុចគ្រឹះនៅក្នុងដំណើរការនៃការរៀនភាសា ។ Kiziltepe (2000) បានធ្វើការអង្កេតទៅលើឥទ្ធិពលនៃឥរិយាបថ និងការលើកទឹកចិត្តទៅលើការសិក្សាភាសាអង់គ្លេសរបស់សិស្សតួគី ។ ការរកឃើញពីការស្រាវជ្រាវនេះបរិយាយថាសិស្សតួគីមានឥរិយាបថវិជ្ជមានចំពោះការសិក្សាភាសាអង់គ្លេស និងសហគមន៍អង់គ្លេស និងអាមេរិក ហើយថាពួកគេគ្មានការព្រួយបារម្ភនៅក្នុងថ្នាក់ទេ ។

Shams (2008) បានធ្វើការសិក្សាក្នុងគោលបំណងអង្កេតទៅលើឥរិយាបថរបស់សិស្ស ការលើកទឹកចិត្ត និងការព្រួយបារម្ភចំពោះការសិក្សាភាសាអង់គ្លេស ។ ការស្រាវជ្រាវបានគូសបញ្ជាក់ថានិស្សិតមានឥរិយាបថវិជ្ជមាន និងមានសេចក្ដីសាទរយ៉ាងខ្លាំងចំពោះភាសាអង់គ្លេស ។ នេះក៏បានគូសបញ្ជាក់ផងដែរថាភាគច្រើននៃពួកគេបានបង្ហាញឥរិយាបថវិជ្ជមានចំពោះភាសាអង់គ្លេស និងការរៀនភាសាអង់គ្លេស ដែលបានសង្កត់ធ្ងន់ទៅលើតម្លៃនៃប្រសិទ្ធភាពនៃការសិក្សាភាសាអង់គ្លេសនៅក្នុងជីវិតប្រចាំថ្ងៃជាថ្នូរត្រឡប់មកវិញ ។

Momani (2009) ក៏បានស្ទាបស្ទង់មតិអំពីឥរិយាបថរបស់សិស្សវិទ្យាល័យចំពោះការរៀនភាសាអង់គ្លេសជាភាសាបរទេស និងសមិទ្ធផលរបស់ពួកគេក្នុងការអាន ។ ការរកឃើញបានបង្ហាញថាអ្នកឆ្លើយសំណួរមានឥរិយាបថវិជ្ជមានចំពោះការសិក្សាភាសាអង់គ្លេស ។ ដូចគ្នានេះផងដែរមានទំនាក់ទំនងយ៉ាងស្អិតរមួតរវាងឥរិយាបថរបស់សិស្សចំពោះការសិក្សាភាសាអង់គ្លេស និងការប្រតិបត្តិនៃការអានរបស់ពួកគេ ។

លទ្ធផលនៃការសិក្សារបស់ Al-Tamimi និងShuib (2009) ស្ដីពីការជំរុញទឹកចិត្ត និងឥរិយាបថរបស់និស្សិតផ្នែកវិស្វកម្មប្រេងឥន្ទនៈចំពោះការរៀនភាសាអង់គ្លេសបានបង្ហាញថាពួកគេមានឥរិយាបថវិជ្ជមានចំពោះការប្រើប្រាស់ភាសាអង់គ្លេសក្នុងបរិបទសង្គម និងការអប់រំយេម៉ែន ។ ពួកគេក៏បានបង្ហាញឥរិយាបថវិជ្ជមានចំពោះវប្បធម៌នៃពិភពដែលនិយាយភាសាអង់គ្លេសផងដែរ ។

នៅក្នុងការសិក្សាអថេរប្រចាំឆ្នាំ Al-Zahrani (2008) បានធ្វើការសិក្សាដើម្បីកំណត់ឥរិយាបថសិស្សអារ៉ាប៊ីសាអ៊ូឌីតចំពោះការសិក្សាភាសាអង់គ្លេស ។ ការវិភាគស្ថិតិបានបង្ហាញថាមិនមានភាពខុសប្លែកគ្នាច្បាស់លាស់ទេ ក្នុងរយៈពេល 3 ឆ្នាំ ចំពោះឥរិយាបថរបស់ពួកគេទៅលើការសិក្សាភាសាអង់គ្លេស ដោយស្ថិតិបានបង្ហាញថាអ្នកឆ្លើយសំណួរក្នុងរយៈពេល 3 ឆ្នាំ មានកម្រិតនៃឥរិយាបថដូចៗគ្នា ។

នៅក្នុងការសិក្សាមួយដែលធ្វើឡើងដោយ Malallah (2010) បង្ហាញថាសិស្ស នៃសាកលវិទ្យាល័យគុយវ៉ែត មានឥរិយាបថវិជ្ជមានចំពោះការសិក្សាភាសាអង់គ្លេស និងអ្នកនិយាយភាសា

អង់គ្លេសដើមកំណើត ។ ការសិក្សានេះក៏បានបង្ហាញពីអាទិភាពនៃទំនាក់ទំនងវិជ្ជមានរវាងឥរិយាបថរបស់អ្នកឆ្លើយ និងសមិទ្ធផលរបស់ពួកគេ ហើយនឹងតម្រូវការជាក់ស្តែងនៃភាសាអង់គ្លេស ។

Shirbaji (2010) បានសិក្សាអំពីឥរិយាបថរបស់និស្សិតថ្នាក់បរិញ្ញាបត្រនៅមហាវិទ្យាល័យមនុស្សសាស្ត្រទៅលើការសិក្សាភាសាអង់គ្លេសជាភាសាបរទេស ។ សំណាកគំរូធំៗចំនួន 400 នាក់ (48.3% នារី និងបុរស 51.7%) បានបញ្ចប់សំណួរដែលបង្កើតឡើងដោយអ្នកស្រាវជ្រាវ ។ ការរកឃើញបានបង្ហាញថាអ្នកចូលរួមមានឥរិយាបថវិជ្ជមានចំពោះការសិក្សាភាសាអង់គ្លេស។

ឥរិយាបថចំពោះការសិក្សាភាសាអង់គ្លេសជាភាសាបរទេសក្នុងចំណោមនិស្សិតមុនមធ្យម និងមធ្យមរបស់អារ៉ាប់ នៅវិទ្យាស្ថានភាសាអង់គ្លេស នៃសាកលវិទ្យាល័យ King Abdulaziz ត្រូវបានស៊ើបអង្កេតឡើងដោយ Alkaff (2013) ។ និស្សិតស្រី 47 នាក់បានបង្កើតគំរូនៃការសិក្សា និងបានបញ្ចប់សំណួរដែលបង្កើតឡើងដោយអ្នកស្រាវជ្រាវ ។ លទ្ធផលបានបង្ហាញថាសិស្សគំរូមានឥរិយាបថវិជ្ជមានចំពោះការសិក្សាភាសាអង់គ្លេស ។ អ្នកចូលរួមក៏បានរាយការណ៍ពីទំនោរខ្លាំងឆ្ពោះទៅរកការធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពភាសាអង់គ្លេសរបស់ពួកគេ ថ្វីបើឱកាសនៃការអនុវត្តភាសាអង់គ្លេសនៅក្នុងសង្គមដែលភាសាអង់គ្លេសជាភាសាបរទេសរបស់ពួកគេនៅមានកំណត់យ៉ាងណាក្តី ។

Al Noursi (2013) បានសិក្សាស្រាវជ្រាវពីឥរិយាបថរបស់និស្សិតអារ៉ាប់អេមីរ៉ាត ចំពោះការសិក្សាភាសាអង់គ្លេសជាភាសាបរទេស ។ និស្សិតចំនួន 196 នាក់នៅវិទ្យាល័យបច្ចេកវិទ្យាគឺជាអ្នកចូលរួមក្នុងការសិក្សានេះ ។ ពួកគេត្រូវបានគេរាយការណ៍ថាមានឥរិយាបថវិជ្ជមានចំពោះការរៀនភាសាអង់គ្លេស ។ ការរកឃើញគួរឱ្យចាប់អារម្មណ៍មួយជាប់ទាក់ទងទៅនឹងកំណើតរបស់គ្រូបង្រៀនដែលមិនមានឥទ្ធិពលណាមួយទៅលើឥរិយាបថរបស់អ្នកឆ្លើយតប ចំពោះភាសាអង់គ្លេសជាភាសាបរទេសនោះទេ ។

ឥរិយាបថរបស់និស្សិតហ្សកដានីអំពីការរៀនភាសាអង់គ្លេសត្រូវបានរកឃើញដោយ Tahaineh និងDana (2013) ។ សំណាកនៅក្នុងការស្រាវជ្រាវនេះមាននិស្សិតស្រី 184 នាក់ ជំនាញភាសាអង់គ្លេស និងអក្សរសាស្ត្រ ។ អ្នកចូលរួមបានបញ្ចប់តេស្តអំពីឥរិយាបថ និងការលើកទឹកចិត្ត ។ និស្សិតបានបង្ហាញឥរិយាបថវិជ្ជមានចំពោះភាសាអង់គ្លេសជាភាសាបរទេស ក៏ដូចជាចំពោះមនុស្សដែលនិយាយភាសាអង់គ្លេសផងដែរ ។

នៅក្នុងការសិក្សាដ៏សំខាន់មួយធ្វើឡើងដោយ Al Samadani and Ibnian (2015) អំពីផលប៉ះពាល់នៃឥរិយាបថនិស្សិតភាសាអង់គ្លេសជាភាសាបរទេសរបស់អារ៉ាប៊ីសាអ៊ូឌីត ចំពោះការសិក្សាភាសាអង់គ្លេស ។ សមិទ្ធផលសិក្សារបស់ពួកគេត្រូវបានសិក្សាយ៉ាងហ្មត់ចត់អាស្រ័យលើសំណាកសិស្សឯកទេសភាសាអង់គ្លេសចំនួន 112 នាក់ ដែលមានចាប់ពីសិស្សថ្មីរហូតដល់សិស្សចាស់ដែលមានមធ្យមពិន្ទុ (GPA) ផ្សេងគ្នា ។ ការស្រាវជ្រាវបានបង្ហាញថាសិស្សជាទូទៅមានឥរិយាបថវិជ្ជមានចំពោះការសិក្សាភាសាអង់គ្លេស ។ សិស្សដែលមាន GPA ខ្ពស់ត្រូវបានរាយការណ៍ពីឥរិយាបថវិជ្ជមានខ្ពស់បំផុតចំពោះការសិក្សាភាសាអង់គ្លេស ហើយតាមពីក្រោយបន្តបន្ទាប់ដោយនិសិត្ស GPA មធ្យម និងទាប ។

Ahmed (2015) បានស្រាវជ្រាវពីឥរិយាបថរបស់និសិត្យថ្នាក់បរិញ្ញាបត្រម៉ាឡេស៊ី ចំពោះការសិក្សាភាសាអង់គ្លេស ។ អ្នកចូលរួម 238 នាក់ដែលបានបំពេញកម្រងសំណួរដែលមាន 30 សំណួរបានបង្ហាញថាមានឥរិយាបថវិជ្ជមានចំពោះភាសាអង់គ្លេសជាភាសាបរទេស ។ ទោះបីជាពួកគេបានរៀនភាសាអង់គ្លេសនៅក្នុងស្ថាប័នអប់រំរបស់ពួកគេក៏ដោយ ក៏ពួកគេនៅតែស្វែងរកការយកចិត្តទុកដាក់បន្ថែមដោយបានទៅរៀនភាសាអង់គ្លេសនៅតាមមជ្ឈមណ្ឌលភាសាឯកជន ។ វាក៏ត្រូវបានរកឃើញផងដែរថាអ្នកសិក្សាចាប់អារម្មណ៍ក្នុងការរៀនជំនាញភាសាទាំងអស់ប្រកបដោយការយកចិត្តទុកដាក់ដូចៗគ្នា ។ ដូច្នេះវាចាំបាច់ក្នុងការដាក់មេរៀនលើការស្តាប់ និងនិយាយទៅក្នុងកម្មវិធីសិក្សាភាសាអង់គ្លេស ។

ការសិក្សាខ្លះភ្ជាប់ឥរិយាបថទៅនឹងសមិទ្ធផល ។ ឧទាហរណ៍៖ នៅក្នុងការសិក្សាទៅលើសិស្សវិទ្យាល័យឆ្នាំចុងក្រោយនៅភាគខាងកើតប្រទេសតួគី Inal, et al (2003) សង្កត់ធ្ងន់ទៅលើគំនិតដែលថា មានទំនាក់ទំនងខ្ពស់រវាងឥរិយាបថ និងសមិទ្ធផល ។ ដូចគ្នានេះដែរ Al-Mansour (2007) បានសន្និដ្ឋានថាការមានឥរិយាបថវិជ្ជមានចំពោះអ្នកនិយាយភាសាអារ៉ាប់ និងការចំណាយពេលវេលាគ្រប់គ្រាន់នៅក្នុងប្រទេសនិយាយភាសាអារ៉ាប់ គឺជាកត្តាដែលជួយឱ្យមានការបញ្ចេញសំឡេងភាសាអារ៉ាប់បានល្អបំផុត ។

Borromeo-Samonte (1981) បានសិក្សាអំពីឥរិយាបថរបស់និស្សិតមហាវិទ្យាល័យភីលីពីនចំពោះការសិក្សាភាសាអង់គ្លេស។ លទ្ធផលបានបង្ហាញថានិស្សិតទាំងនោះចូលចិត្តភាសាអង់គ្លេសហើយឥរិយាបថបែបនេះត្រូវបានជះឥទ្ធិពលដោយការលើកទឹកចិត្ត ដោយសារពួកគេអាចកំណត់អត្តសញ្ញាណរបស់ពួកគេជាមួយនឹងវប្បធម៌បានយ៉ាងងាយស្រួល ។ ការរកឃើញស្រដៀងគ្នានេះត្រូវបានធ្វើឡើងដោយ El-Dash & Busnardo (2001) នៅប្រទេសប្រេស៊ីល ។ លទ្ធផលបង្ហាញថាភាគច្រើននៃក្មេងជំទង់ប្រេស៊ីលពេញចិត្តភាសាអង់គ្លេសជាងភាសាព័រទុយហ្គាល់ នៅក្នុងលក្ខខណ្ឌនៃការគោរព និងសាមគ្គីភាព ។ ការពេញចិត្តភាសាអង់គ្លេសជាងភាសាកំណើត (ភាសាព័រទុយហ្គាល់) ត្រូវបានសន្មតថាជាការយល់ដឹងជាទូទៅអំពីភាសាអង់គ្លេសថាជាភាសាអន្តរជាតិដ៏ល្បីល្បាញ និងការប្រើប្រាស់ជានិមិត្តរូបក្នុងចំណោមក្រុមមនុស្សវ័យជំទង់ ។ ចំពោះសង្គមភាគច្រើន ជាដំណើរការដ៏ចាំបាច់មួយដើម្បីទទួលបានភាពជោគជ័យសម្រាប់ជីវិតនៅក្នុងបរិយាកាសដែលបានផ្លាស់ប្តូរនៅថ្ងៃនេះ ។

Lafaye និង Tsuda (2002) បានធ្វើការស្ទង់មតិនិស្សិតឆ្នាំទី 1 និងទី 2 នៃមហាវិទ្យាល័យមនុស្សសាស្ត្រនៅសាកលវិទ្យាល័យ Tokai Gakuen ដែលកំពុងសិក្សាមុខវិជ្ជាចរិតលក្ខណៈមនុស្សទំនាក់ទំនងភាសា និងវប្បធម៌អន្តរជាតិ ។ ការស្ទង់មតិនេះបង្ហាញថាសិស្សភាគច្រើនគិតថាភាសាអង់គ្លេសគឺចាំបាច់សម្រាប់ការធ្វើដំណើរ ការប្រើប្រាស់កុំព្យូទ័រ និងការកម្សាន្តដូចជា ភាពយន្ត ឬតន្ត្រីជាដើម ។ ថ្វីបើពួកគេយល់ថាភាសាអង់គ្លេសត្រូវបានគេប្រើយ៉ាងទូលំទូលាយនៅក្នុងពិភពលោកក៏ដោយ ក៏ពីរភាគបី (2/3) នៃសិស្សទាំងអស់និយាយថាពួកគេមិនចូលចិត្តសិក្សាភាសាអង់គ្លេសទេ ។ Lafaye និង Tsuda (2002) បានចង្អុលបង្ហាញថាមានការផ្ទុយគ្នារវាងការយល់ដឹងរបស់សិស្សអំពីសារៈសំខាន់នៃភាសាអង់គ្លេស និងឥរិយាបថរបស់ពួកគេចំពោះវា ។ លទ្ធផលស្ទង់មតិក៏បង្ហាញផងដែរថាសិស្សចង់ឱ្យភាសាអង់គ្លេសរបស់ពួកគេមានសមត្ថភាពខ្ពស់ ប៉ុន្តែពួកគេមិនចូលចិត្តសិក្សាភាសាអង់គ្លេសនៅឯសាលានោះទេ ។

Tsuda (2003) បានរកឃើញមូលហេតុមួយចំនួនដែលធ្វើឱ្យនិស្សិតជប៉ុនមិនចូលចិត្តរៀនភាសាអង់គ្លេស ។ ចម្លើយអវិជ្ជមានដ៏សាមញ្ញជាងគេគឺថាសិស្សគិតថាភាសាអង់គ្លេសនឹងមិនមានសារៈសំខាន់ទៀតទេក្នុងជីវិតប្រចាំថ្ងៃរបស់ពួកគេ ។ សិស្សមួយចំនួនទៀតឆ្លើយថាពួកគេមានអារម្មណ៍ថា ឥទ្ធិពលអាមេរិកកាន់តែខ្លាំងឡើងនៅពេលដែលពួកគេនាំគ្នារៀនភាសាអង់គ្លេស ។ ចំណែកឯសិស្សមួយចំនួនទៀតពន្យល់ថាពួកគេមិនចូលចិត្តរៀនភាសាអង់គ្លេសគឺដោយសារតែវាពិបាក ហើយពួកគេមិនដែលរីករាយក្នុងការសិក្សាវេយ្យាករណ៍នោះទេ ។ ពួកគេក៏បានពន្យល់ផងដែរថាការសិក្សាភាសាអង់គ្លេសនៅក្នុងប្រទេសជប៉ុនគឺមិនមែនដើម្បីទំនាក់ទំនងគ្នានោះទេ តែគឺដើម្បីការប្រឡងតែប៉ុណ្ណោះ ។ សិស្សដទៃទៀតនិយាយថាមានតែគ្រូប៉ុណ្ណោះដែលនិយាយភាសាអង់គ្លេស ហើយថាពួកគេមានឱកាសតិចណាស់ក្នុងការប្រើប្រាស់ភាសាអង់គ្លេស ។ សិស្សភាគច្រើននិយាយថាពួកគេចង់សិក្សាការសន្ទនាជាមួយគ្រូជនជាតិដើម ។ ពួកគេក៏បាននិយាយផងដែរថា ពួកគេចង់រៀនភាសាអង់គ្លេសតាមរយៈបទចម្រៀង ឬភាពយន្តដែលពេញនិយម ។ ពួកគេក៏និយាយដែរថាពួកគេមិនចង់ឱ្យភាសាអង់គ្លេសក្លាយជាមុខវិជ្ជាកាតព្វកិច្ចនោះទេ ។

អាកប្បកិរិយាអវិជ្ជមានចំពោះភាសាអង់គ្លេស ឬមុខវិជ្ជាភាសាអង់គ្លេសលេចឡើងនៅក្នុងការសិក្សាមួយចំនួន ។ ឧទាហរណ៍៖ Abd Aziz (1994) ប្រកាសថានិស្សិតសាកលវិទ្យាល័យ UKM (សាកលវិទ្យាល័យ Kebangsaan ម៉ាឡេស៊ី ឬសាកលវិទ្យាល័យជាតិម៉ាឡេស៊ី) បានបង្ហាញពីឥរិយាបថវិជ្ជមានចំពោះការនិយាយភាសាអង់គ្លេសជាទូទៅ ប៉ុន្តែពួកគេមានឥរិយាបថអវិជ្ជមានទៅវិញនៅពេលដែលភាសាអង់គ្លេសជាមុខវិជ្ជាសិក្សានៅឯសាកលវិទ្យាល័យ ។ ដូចគ្នានេះដែរ Abu-Melhim (2009) បានពិនិត្យមើលហេតុផលនៅក្រោយការជ្រើសរើសភាសាអង់គ្លេសជាមុខវិជ្ជាឯកទេសរបស់និស្សិតហ្ស៊កដង់ នៅសាកលវិទ្យាល័យ Irbid ហើយបានសន្និដ្ឋានថាខុសពីការរំពឹងទុកសិស្សប្រមាណពាក់កណ្តាលមានឥរិយាបថអវិជ្ជមានចំពោះការសិក្សាភាសាអង់គ្លេស ។ ម៉្យាងវិញទៀតការសិក្សារបស់ Despagne (2010) លើនិស្សិតដែលរៀនភាសាអង់គ្លេសនៅសាកលវិទ្យាល័យចំនួនពីររបស់ប្រទេសម៉ិកស៊ិកូ បានបង្ហាញពីឥរិយាបថអវិជ្ជមានដែលគាត់បានភ្ជាប់ជាមួយនឹងអតីតអាណានិគមម៉ិចស៊ិកូ និងឥទ្ធិពលនៃចក្រពត្តិនិយមភាសា ។

ឥរិយាបថចំពោះភាសាអាចត្រូវបានកំណត់ថាជាអារម្មណ៍វិជ្ជមាន ឬអវិជ្ជមានដែលមនុស្សមាននៅពេលពួកគេប្រឈមមុខនឹងជម្រើសរវាងភាសានៅក្នុងស្ថានភាពផ្សេងៗគ្នា ឬកំពុងរៀនភាសា (Smit, 1996) ។ ឥរិយាបថជំរុញអារម្មណ៍ក្នុងការពង្រឹងការសិក្សា (Spolsky, 1989) ។ ឥរិយាបថរបស់សិស្សត្រូវបានគេទទួលស្គាល់ថាជាកត្តាសំខាន់បំផុតមួយដែលជះឥទ្ធិពលទៅលើការសិក្សាភាសា (Fakeye, 2010) ។

Dennis Soku (2011) និយាយថា ភេទមានឥទ្ធិពលយ៉ាងខ្លាំងទៅលើឥរិយាបថរបស់សិស្សចំពោះការសិក្សាភាសាអង់គ្លេស ។

យោងតាម Keller (1983) Aacken (1999) Dornyei និង Shoaib (2005) បានឱ្យដឹងថាភេទត្រូវបានគេចាត់ទុកថាជាផ្នែកមួយសំខាន់នៅក្នុងការសិក្សាភាសាទី2 ហើយដែលបង្ហាញថាសិស្សស្រីមានចំណាប់អារម្មណ៍ និងមានអាកប្បកិរិយាវិជ្ជមានជាងសិស្សប្រុស ។

លោក Shahrzad Eshghinejad (2016) បានធ្វើការសិក្សាពីឥរិយាបថរបស់និស្សិត សាកលវិទ្យាល័យកាស្ហានរបស់ប្រទេសអ៊ីរ៉ង់ (Kashan University, Iran) ដោយពិនិត្យរកភាពដូចគ្នា ឬខុសគ្នារវាងសិស្សប្រុស និងសិស្សស្រី ។ ការសិក្សាបង្ហាញថា ទាំងនិស្សិតប្រុស និងនិស្សិតស្រីមានឥរិយាបថវិជ្ជមានដូចគ្នាទៅលើធាតុទាំងបីនៃឥរិយាបថ ។ ក្នុងការសិក្សារបស់គាត់ដដែលក៏បានរកឃើញផងដែរថាកម្រិតនៃឥរិយាបថអារម្មណ៍របស់សិស្សស្រីមានកម្រិតខ្ពស់ជាងសិស្សប្រុស ។

លោក Gajalakshmi (2013) បានធ្វើការសិក្សាទៅលើសិស្សវិទ្យាល័យនៅតំបន់ Puducherry នៃប្រទេសឥណ្ឌា ។ គាត់រកឃើញថាឥរិយាបថរបស់សិស្សមកពីតំបន់ប្រជុំជនមានកម្រិតខ្ពស់ជាងឥរិយាបថរបស់សិស្សមកពីតំបន់ជនបទ ។

លោក Mehmet Nuri Gömleksiz (2010) បានធ្វើការសិក្សាអំពីឥរិយាបថរបស់និស្សិតឆ្នាំទី1 និងឆ្នាំទី2 នៃសាកលវិទ្យាល័យហ្វារ៉ាតប្រទេសតួគី (Farat University, Turkey) ដោយផ្តោតលើភេទ កម្រិតថ្នាក់ និងបម្រែបម្រួលដេប៉ាតឺម៉ង់ ។ ក្នុងការសិក្សានោះ គាត់រកឃើញថា និស្សិតថ្នាំទី2មានឥរិយាបថល្អប្រសើរជាងនិស្សិតឆ្នាំទី1 ដោយសារពួកគេមានចំណាប់អារម្មណ៍ មានទំនុកចិត្តលើខ្លួនឯង និងយល់ពីសារប្រយោជន៍អំពីភាសាអង់គ្លេសជាង ។

ដូច្នេះ ការសិក្សានេះនឹងពិនិត្យទៅលើគំនិតនៃឥរិយាបថដែលជាកត្តាដ៏មានប្រសិទ្ធភាពសំខាន់មួយសម្រាប់ភាពជោគជ័យក្នុងការរៀនភាសាបរទេស ។ ជាពិសេសការសិក្សានេះនឹងពិនិត្យទៅលើឥរិយាបថរបស់សិស្សអនុវិទ្យាល័យចំពោះការសិក្សាភាសាអង់គ្លេស ដោយសង្កេតទៅលើចំណុចបីធំៗ គឺ ការយល់ដឹង (Cognitive) អារម្មណ៍ (Emotional/Affective) និងអាកប្បកិរិយា (Behavioral) (Wenden, 1991) ។ បន្ថែមពីលើនេះផងដែរ ការសិក្សានេះក៏នឹងពិនិត្យរកភាពខុសគ្នារវាងឥរិយាបថរបស់សិស្សចំពោះមុខវិជ្ជាភាសាអង់គ្លេសដោយផ្អែកលើភេទ កម្រិតថ្នាក់ និងតំបន់ផងដែរ ហើយក៏នឹងរកឱ្យឃើញនូវបញ្ហាប្រឈមនានាក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនៅមធ្យមសិក្សាបឋមភូមិនៅក្នុងខេត្តកំពង់ចាមផងដែរ ។

# ជំពូកទី៣
# វិធីសាស្ត្រស្រាវជ្រាវ

# ជំពូកទី៣
# វិធីសាស្ត្រស្រាវជ្រាវ

## ៣.១ ព័ត៌មានទូទៅស្តីពីការស្រាវជ្រាវ

ការស្រាវជ្រាវនេះត្រូវបានរៀបចំធ្វើឡើងដោយប្រើទិន្នន័យបរិមាណវិស័យ និងគុណវិស័យ ដែលបានយកមកវិភាគដើម្បីស្វែងយល់ពីកម្រិតនៃឥរិយាបថរបស់សិស្ស ភាពខុសគ្នា ឬដូចគ្នានៃឥរិយាបថរបស់សិស្សចំពោះមុខវិជ្ជាភាសាអង់គ្លេស និងបញ្ហាប្រឈមនានាក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ចាមនាពេលបច្ចុប្បន្ននេះ ។

## ៣.២ ទីកន្លែងសិក្សាស្រាវជ្រាវ

ការស្រាវជ្រាវនេះបានជ្រើសរើសយកខេត្តកំពង់ចាមជាទីតាំងសិក្សា ហើយស្រុកចំនួន ៦ ក្នុងចំណោមស្រុកទាំងអស់ ១០ ត្រូវបានជ្រើសរើសចេញពីខេត្តនេះ ដែលរួមមាន ១) ក្រុងកំពង់ចាម ២) ស្រុកកំពង់សៀម ៣) ស្រុកកោះសូទិន ៤) ស្រុកព្រៃឈរ ៥) ស្រុកបាធាយ និង ៦) ស្រុកស្រីសន្ធរ ។ ក្នុងនោះអ្នកសិក្សាបានកំណត់ជ្រើសរើសយកសាលាជាគោលដៅចំនួន ១៥ រួមមាន វិទ្យាល័យចំនួន ៥ ក្នុងចំណោម ៣៨ វិទ្យាល័យ និងអនុវិទ្យាល័យចំនួន ១០ ក្នុងចំណោម ៨១ អនុវិទ្យាល័យ ។ ក្នុងនោះផងដែរ ក្នុង ១ ស្រុកអ្នកសិក្សាបានជ្រើសរើសយកសាលាចំនួន ៣ ដោយផ្អែកលើលក្ខណៈភូមិសាស្ត្រខុសៗគ្នា គឺ ១ សាលា ជាវិទ្យាល័យធំជាងគេនៅតំបន់ប្រជុំជន ១ សាលា ជាអនុវិទ្យាល័យនៅតំបន់ពាក់កណ្តាលប្រជុំ និង ១ សាលាទៀត ជាអនុវិទ្យាល័យដែលនៅតំបន់ដាច់ស្រយាលបំផុត លើកលែងតែក្រុងកំពង់ចាម ដែលអ្នកសិក្សាជ្រើសរើសយកតែវិទ្យាល័យ ១ ដែលធំជាងគេ ព្រោះក្នុងក្រុងនេះមិនមានអនុវិទ្យាល័យទេ ហើយនឹងស្រុកកំពង់សៀមដែលជាស្រុកមានព្រំប្រទល់ជាប់នឹងក្រុងកំពង់ចាម អ្នកសិក្សាជ្រើសយកតែ ២ អនុវិទ្យាល័យប៉ុណ្ណោះដែលនៅជិតក្រុងជាងគេ ដោយយកក្រុងកំពង់ចាមបូកនឹងស្រុកកំពង់សៀមធ្វើជា ១ ស្រុក ។ អ្នកសិក្សាជ្រើសរើសសាលាគោលដៅរបៀបនេះ គឺដើម្បីទទួលបាននូវទិន្នន័យពីគ្រប់តំបន់ (ទីក្រុង/ប្រជុំជន ពាក់កណ្តាលប្រជុំជន និងជនបទដាច់ស្រយាល) ហើយដែលសាលាគោលដៅទាំងនោះរួមមាន៖ ១) ក្រុងកំពង់ចាម៖ វិទ្យាល័យព្រះសីហនុ ២) ស្រុកកំពង់សៀម៖ អនុវិទ្យាល័អង្គរ និងអនុវិទ្យាល័យថ្មគោល ៣) ស្រុកកោះសូទិន៖ វិទ្យាល័យជីហែ អនុវិទ្យាល័យល្វេ និងអនុវិទ្យាល័យព្រែកតានង់ ៤ ) ស្រុកព្រៃឈរ៖ វិទ្យាល័យនរោត្តរណឫទ្ធិ-គន្ធបុប្ផា អនុវិទ្យាល័យខ្វិតធំ និងអនុវិទ្យាល័យប្រិមប្រីយ៍ ៥ ) ស្រុកបាធាយ៖ វិទ្យាល័យហោណាំហុងព្រៃញា អនុវិទ្យាល័យទំនប់ និងអនុវិទ្យាល័យត្រប់ និង ៦) ស្រុកស្រីសន្ធរ៖ វិទ្យាល័យស្រីសន្ធរ អនុវិទ្យាល័យបារាយណ៍ និងអនុវិទ្យាល័យស្វាយពោធិ៍ ។

## ៣.៣ ក្រុមគោលដៅ

ក្នុងការសិក្សានេះអ្នកស្រាវជ្រាវបានកំណត់ក្រុមគោលដៅ ៣ គឺនាយក/នាយករងចំនួន ១៥ នាក់ ដោយយក ១ សាលា ១ នាក់ ។ គ្រូបង្រៀនភាសាអង់គ្លេសថ្នាក់ទី ៧, ៨ និង ៩ ចំនួន ៤៥ នាក់ ដោយ ១ សាលាយកគ្រូ ៣ នាក់ និងសិស្សថ្នាក់ទី ៧, ៨ និង ៩ ចំនួន ៤៥០ នាក់ ដោយ ១ សាលាយកសិស្ស ៣០ នាក់ ។

**តារាងទី១៖ ក្រុមគោលដៅ និងអ្នកចូលរួម**

| ល.រ | ក្រុមគោលដៅ | អ្នកចូលរួម |
|---|---|---|
| ១ | នាយកសាលាវិទ្យាល័យ និងអនុវិទ្យាល័យ | ១៥ នាក់ |
| ២ | គ្រូបង្រៀនភាសាអង់គ្លេសទី ៧ ដល់ទី ៩ | ៤៥ នាក់ |
| ៣ | សិស្សានុសិស្សថ្នាក់ទី ៧ ដល់ទី ៩ | ៤៥០ នាក់ |
| សរុប | | ៥១០ នាក់ |

## ៣.៤ ទំហំសំណាក

ភាគសំណាកសម្រាប់ការសិក្សាស្រាវជ្រាវនេះរួមមាន នាយកសាលាចំនួន ១៥ នាក់ លោកគ្រូ/អ្នកគ្រូបង្រៀនភាសាអង់គ្លេសថ្នាក់ទី ៧ ដល់ថ្នាក់ទី ៩ ចំនួន ៤៥ នាក់ និងសិស្សថ្នាក់ថ្នាក់ទី ៧ ដល់ថ្នាក់ទី ៩ ចំនួន ៤៥០ នាក់ ដែលមានទីតាំងនៅក្នុងក្រុង/ស្រុកចំនួន ៦ គឺ ក្រុងកំពង់ចាម ស្រុកកំពង់សៀម ស្រុកកោះសូទិន ស្រុកព្រៃឈរ ស្រុកបាធាយ និងស្រុកស្រីសន្ធរ ដែលស្ថិតនៅក្នុងទឹកដីខេត្តកំពង់ចាមតែមួយប៉ុណ្ណោះ ។ ការជ្រើសរើសសិស្សមកធ្វើជាភាគសំណាកគឺធ្វើឡើងដោយប្រើប្រាស់គេហទំព័រ អូធិនអេភី (www.openepi.com) ក្នុងកម្រិតជឿជាក់ ៩៥% ដែលជាមធ្យមក្នុងមួយសាលាត្រូវយកសិស្សចំនួន ៣០ នាក់ ។ ចំណែកឯការជ្រើសរើសនាយក និងគ្រូមកធ្វើជាភាគសំណាកវិញ ត្រូវបានកំណត់ដូចតទៅ៖ ក្នុង ១ សាលាកំណត់យកនាយក/នាយករង ១ នាក់ និងលោកគ្រូ/អ្នកគ្រូបង្រៀនភាសាអង់គ្លេសដែលកំពុងបង្រៀនថ្នាក់ទី៧ ដល់ថ្នាក់ទី៩ ចំនួន ៣ នាក់ (គ្រូបង្រៀនថ្នាក់ទី ៧ ចំនួន ១ នាក់ ថ្នាក់ទី ៨ ចំនួន ១ នាក់ និងថ្នាក់ ទី៩ ចំនួន ១ នាក់ ដោយមិនគិតឯកទេសដើមឡើយ) ។

**តារាងទី២៖ ចំនួននាយក គ្រូ និងសិស្សតាមសាលាគោលដៅ**

| ល.រ | ខេត្ត | ស្រុក/ក្រុង | សាលាគោលដៅ | អ្នកចូលរួម (នាក់) | | | សរុប |
|---|---|---|---|---|---|---|---|
| | | | | នាយក | គ្រូ | សិស្ស | |
| 1 | កំពង់ចាម | កំពង់ចាម | វិ. ព្រះសីហនុ | 01 | 03 | 30 | 34 |
| 2 | | កំពង់សៀម | អនុ. អង្គរ | 01 | 03 | 30 | 34 |
| 3 | | | អនុ. ថ្មគោល | 01 | 03 | 30 | 34 |
| 4 | | កោះសូទិន | វិ. ជីហែ | 01 | 03 | 30 | 34 |
| 5 | | | អនុ. ល្វេ | 01 | 03 | 30 | 34 |
| 6 | | | អនុ. ព្រែកតានង់ | 01 | 03 | 30 | 34 |
| 7 | | ព្រៃឈរ | វិ. នរ. រណឫទ្ធិ-គន្ធបុប្ផា | 01 | 03 | 30 | 34 |
| 8 | | | អនុ. ខ្វិតធំ | 01 | 03 | 30 | 34 |
| 9 | | | អនុ. ប្រិមប្រីយ៍ | 01 | 03 | 30 | 34 |
| 10 | | បាធាយ | វិ. ហហ. ព្រែញ | 01 | 03 | 30 | 34 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 11 | | | អនុ. ទំនប់ | 01 | 03 | 30 | 34 |
| 12 | | | អនុ. ត្រប់ | 01 | 03 | 30 | 34 |
| 13 | | ស្រីសន្ធរ | វិ. ស្រីសន្ធរ | 01 | 03 | 30 | 34 |
| 14 | | | អនុ. បារាយណ៍ | 01 | 03 | 30 | 34 |
| 15 | | | អនុ. ស្វាយពោធិ៍ | 01 | 03 | 30 | 34 |
| **សរុប** | 01 | 06 | 15 | 15 | 45 | 450 | **510** |

## ៣.៥ ឧបករណ៍សិក្សាស្រាវជ្រាវ

ចំពោះឧបករណ៍ស្រាវជ្រាវដែលត្រូវយកមកប្រើនៅក្នុងការប្រមូលទិន្នន័យ មានកម្រងសំណួរដែលមានកម្រិតចម្លើយ (ទម្រង់បិទ) និងកម្រងសំណួរទម្រង់បើក ។ ដើម្បីប្រមូលទិន្នន័យបាន អ្នកស្រាវជ្រាវបានរៀបចំកម្រងសំណួរសម្រាប់សិស្ស កម្រងសំណួរសម្រាប់គ្រូ និងកម្រងសំណួរសម្រាប់នាយក/នាយករង និងមានការសម្ភាសគណៈគ្រប់គ្រងសាលាផងដែរ ។ កម្រងសំណួរត្រូវបានបង្កើតឡើងជា ៣ ប្រភេទ ដើម្បីធ្វើការប្រមូលទិន្នន័យនេះ ក្នុងនោះរួមមាន៖ កម្រងសំណួរសម្រាប់នាយក/នាយករង កម្រងសំណួរសម្រាប់គ្រូបង្រៀនភាសាអង់គ្លេស និងកម្រងសំណួរសម្រាប់សិស្ស ។ ការសិក្សានេះ អ្នកសិក្សាប្រើកម្រងសំណួរចំនួន ៥១០ ច្បាប់ ក្នុងនោះសម្រាប់នាយក/នាយករង ១៥ ច្បាប់ លោកគ្រូ/អ្នកគ្រូបង្រៀនភាសាអង់គ្លេសចំនួន ៤៥ ច្បាប់ និងសម្រាប់សិស្សចំនួន ៤៥០ ច្បាប់ ។ មុនពេលផ្តល់កម្រងសំណួរដល់អ្នកចូលរួមផ្តល់ព័ត៌មាន ជាដំបូង អ្នកសិក្សាបានធ្វើការទាក់ទងជាមួយមន្ត្រីនៅថ្នាក់មន្ទីរ ថ្នាក់ស្រុក និងបន្ទាប់មកបានធ្វើការទាក់ទងជាមួយនាយក/នាយករង និងលោកគ្រូ/អ្នកគ្រូ ដើម្បីឱ្យមានការឯកភាព និងមានភាពងាយស្រួលក្នុងការបំពេញកម្រងសំណួរ ។

***១.កម្រងសំណួរសម្រាប់នាយក/នាយករង***

កម្រងសំណួរសម្រាប់នាយក/នាយករង មានគោលបំណងរកឱ្យឃើញនូវបញ្ហាប្រឈមនានាក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនៅកម្រិតមធ្យសិក្សាបឋមភូមិក្នុងខេត្តកំពង់ចាម ។ កម្រងសំណួរសម្រាប់នាយក/នាយករងមាន ៣ ផ្នែក៖

**ផ្នែកទី១៖** ព័ត៌មានទូទៅៈ អ្នកស្រាវជ្រាវចង់ដឹងពីឈ្មោះខេត្ត ឈ្មោះស្រុក ឈ្មោះសាលា ភេទ និងអាយុនៃនាយក/នាយករងដែលបានចូលរួមផ្តល់ទិន្នន័យ ។

**ផ្នែកទី២៖** កម្រងសំណួរៈ សំណួរផ្តោតលើបញ្ហាប្រឈមនានាក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ចាម ដែលមាន ២០ សំណួរ មានទាំងសំណួរបិទ និងសំណួរបើក ។ សំណួរទាំងនោះផ្តោតទៅលើ ចំនួនម៉ោងសិក្សាភាសាអង់គ្លេស សៀវភៅសិក្សាគោលភាសាអង់គ្លេសសម្រាប់សិស្ស គ្រូបង្រៀនភាសាអង់គ្លេស បណ្ណាល័យ សម្ភារឧបទេស ឯកសារស្រាវជ្រាវ និងការគ្រប់គ្រងបុគ្គលិក ។

**ផ្នែកទី៣៖** គឺយោបល់ និងសំណូមពររបស់នាយក/នាយករង ។

***២.កម្រងសំណួរសម្រាប់គ្រូ***

កម្រងសំណួរសម្រាប់គ្រូ គឺមានគោលបំណងរកឱ្យឃើញនូវ ១) ឥរិយាបថរបស់សិស្សចំពោះមុខវិជ្ជាភាសាអង់គ្លេស ២) ភាពខុសគ្នា ឬដូចគ្នានៃឥរិយាបថរបស់សិស្សចំពោះមុខវិជ្ជាភាសាអង់គ្លេស ដោយផ្អែកលើភេទ កម្រិតថ្នាក់ និងតំបន់ និង៣) បញ្ហាប្រឈមនានាក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ចាម ។ កម្រងសំណួរសម្រាប់គ្រូមាន ៣ ផ្នែក៖

**ផ្នែកទី១៖** ព័ត៌មានទូទៅៈ អ្នកស្រាវជ្រាវចង់ដឹងពីឈ្មោះខេត្ត ឈ្មោះស្រុក ឈ្មោះសាលា ថ្នាក់ដែលទទួលភារកិច្ចបង្រៀន ភេទ និងអាយុ ។

**ផ្នែកទី២៖** នៅផ្នែកនេះចែកចេញជា ២ ផ្នែកបន្តទៀត គឺផ្នែកទី ១ កម្រងសំណួរអំពីឥរិយាបថរបស់សិស្សចំពោះមុខវិជ្ជាភាសាអង់គ្លេសដែលមាន ១៥ សំណួរ និងផ្នែកទី២ មាន ១៥ សំណួរផ្តោតលើចំនួនម៉ោងសិក្សាភាសាអង់គ្លេស សៀវភៅសិក្សាគោល គ្រូបង្រៀនភាសាអង់គ្លេស បណ្ណាល័យ សម្ភារឧបទេស ឯកសារស្រាវជ្រាវ និងការគ្រប់គ្រងបុគ្គលិក ។

**ផ្នែកទី៣៖** គឺយោបល់ និងសំណូមពររបស់គ្រូបង្រៀនភាសាអង់គ្លេស ។

***៣.កម្រងសំណួរសម្រាប់សិស្ស***

កម្រងសំណួរសម្រាប់សិស្ស មានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងកម្រងសំណួរសម្រាប់គ្រូដែរ គឺមានគោលបំណងរកឱ្យឃើញនូវ ១) ឥរិយាបថរបស់សិស្សចំពោះមុខវិជ្ជាភាសាអង់គ្លេស ២) ភាពខុសគ្នា ឬដូចគ្នានៃឥរិយាបថរបស់សិស្សចំពោះមុខវិជ្ជាភាសាអង់គ្លេសដោយផ្អែកលើភេទ កម្រិតថ្នាក់ និងតំបន់ និង៣) បញ្ហាប្រឈមនានាក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ចាម ។ កម្រងសំណួរសម្រាប់សិស្សមាន ៣ ផ្នែក៖

**ផ្នែកទី១៖** ព័ត៌មានទូទៅៈ អ្នកស្រាវជ្រាវចង់ដឹងពីឈ្មោះខេត្ត ឈ្មោះស្រុក ឈ្មោះសាលា ថ្នាក់ ភេទ និងអាយុ ។

**ផ្នែកទី២៖** នៅផ្នែកនេះចែកចេញជា ២ ផ្នែកបន្តទៀត គឺផ្នែកទី ១ កម្រង់សំណួរអំពីឥរិយាបថរបស់សិស្សចំពោះមុខវិជ្ជាភាសាអង់គ្លេសដែលមាន១៥ សំណួរ និងផ្នែកទី២ ក៏មាន ១៥ សំណួរផងដែរ ដែលផ្តោតទៅលើចំនួនម៉ោងសិក្សាភាសាអង់គ្លេស សៀវភៅសិក្សាគោល គ្រូបង្រៀនភាសាអង់គ្លេស បណ្ណាល័យ សម្ភារឧបទេស ឯកសារស្រាវជ្រាវ និងការគ្រប់គ្រងបុគ្គលិក ។

**ផ្នែកទី៣៖** គឺយោបល់ និងសំណូមពររបស់សិស្ស ។

ដោយសារតែពេលវេលាមានកំណត់ ដូច្នេះរយៈពេលនៃការឆ្លើយសំណួរជាមធ្យមមានរយៈពេលពី ១០ ទៅ១៥ នាទី សម្រាប់នាយក/នាយករង និងគ្រូបង្រៀនភាសាអង់គ្លេស និងមានរយៈពេលពី៣០ ទៅ៤០ នាទី សម្រាប់សិស្ស ។ រីឯការសម្ភាសមានរយៈពេលពី១០ ទៅ១៥ នាទី ទៅតាមទីកន្លែង និងពេលវេលាដែលបានព្រមព្រៀងគ្នារវាងអ្នកស្រាវជ្រាវ និងអ្នកផ្តល់ចម្លើយ ព្រមទាំងទទួលបានការអនុញ្ញាតពីប្រធានមន្ទីរ និងប្រធានការិយាល័យអប់រំ យុវជន និងកីឡា ក្នុងខេត្តកំពង់ចាមផងដែរ ។

## ៣.៦ វិធីសាស្ត្រប្រមូលទិន្នន័យ

ការសិក្សានេះប្រើប្រាស់វិធីសាស្ត្របរិមាណវិស័យ និងគុណវិស័យ ក្នុងការប្រមូលទិន្នន័យ ។ របៀបប្រមូលទិន្នន័យសម្រាប់បរិមាណវិស័យ គឺបានផ្តល់កម្រងសំណួរ (សំណួរបិទ) ដែលបានរៀបចំទុកជាមុនស្របតាមគោលបំណងនៃការស្រាវជ្រាវដល់នាយក/នាយករង លោកគ្រូ/អ្នកគ្រូ និងសិស្សឆ្លើយ ដោយមានការសម្របសម្រួលផ្ទាល់ពីអ្នកស្រាវជ្រាវ ។ ចំណែកឯទិន្នន័យសម្រាប់គុណវិស័យវិញគឺបានផ្តល់កម្រងសំណួរ (សំណួរបើក) ដល់នាយក/នាយករង លោកគ្រូ/អ្នកគ្រូ និងសិស្សឆ្លើយ និងដោយមានការសម្ភាសបន្ថែមផ្ទាល់ជាមួយលោកនាយក/នាយករងគ្រប់សាលា ស្តីពី ទី១) អង្គការដៃគូជួយផ្នែកភាសាអង់គ្លេស ទី២) បញ្ហាប្រឈមដទៃទៀតដែលមិនបានលើកឡើងក្នុងកម្រងសំណួរ ទី៣) អវត្តមានគ្រូបង្រៀនភាសាអង់គ្លេស ទី៤) របាយការណ៍អធិការកិច្ចមុខវិជ្ជាភាសាអង់គ្លេស និងទី៥) របាយការណ៍ប្រជុំបច្ចេកទេសមុខវិជ្ជាភាសាអង់គ្លេស ។

## ៣.៧ ដំណើរការក្នុងការប្រមូលទិន្នន័យ

ការសិក្សាស្រាវជ្រាវនេះ បានធ្វើឡើងដោយអ្នកស្រាវជ្រាវបានធ្វើការទាក់ទងសុំការអនុញ្ញាតជាមុនពីមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ការិយាល័យអប់រំ យុវជន និងកីឡាស្រុក និងគ្រឹះស្ថានសិក្សាដែលជាគោលដៅនៃការសិក្សាស្រាវជ្រាវនេះ ។ ជាដំបូង អ្នកសិក្សាបានជួបជាមួយប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ដោយយកទៅជាមួយនូវលិខិតជូនដំណឹងរបស់ក្រសួងអប់រំ យុវជន និងកីឡា លេខ ១៦០៧ អយក.វជអ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៨ និងចុះហត្ថលេខាដោយឯកឧត្តមបណ្ឌិត្យសភាចារ្យ **ហង់ ជួន ណារ៉ុន** ផ្ញើជូនលោកប្រធានមន្ទីរអប់រំ យុវជន និងកីឡា រាជធានី-ខេត្ត ស្តីពីការចុះប្រមូលទិន្នន័យដើម្បីសរសេរសារណាបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៥ និងលិខិតឧទ្ទេសនាមរបស់ក្រសួងអប់រំ យុវជន និងកីឡា លេខ ២២១៨ អយក.ឧទន ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៨ ចុះហត្ថលេខាដោយឯកឧត្តមបណ្ឌិត្យសភាចារ្យ **ហង់ ជួន ណារ៉ុន** ស្តីពីការចាត់តាំងឱ្យនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៥ នៃវិទ្យាស្ថានជាតិអប់រំ ចំនួន ២៤ នាក់ ចុះប្រមូលទិន្នន័យ ដើម្បីសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅតាមរាជធានី-ខេត្តនានា ចាប់ពីថ្ងៃទី២០ ខែមីនា ដល់ថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ២០១៨ ទៅជាមួយផង ។

បន្ទាប់ពីបានការអនុញ្ញាតពីប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តរួចមក អ្នកស្រាវជ្រាវក៏បានថតចម្លងលិខិតទាំងពីររបស់ក្រសួងអប់រំ យុវជន និងកីឡា និងលិខិតអនុញ្ញាតរបស់ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ដាក់ជូនដល់ប្រធានការិយាល័យអប់រំ យុវជន និងកីឡាស្រុក នៅគ្រប់ស្រុកដែលជាគោលដៅជាមុនៗចុះទៅប្រមូលទិន្នន័យនៅតាមគ្រឹះស្ថានសិក្សាក្នុងស្រុកនីមួយៗ ។ បន្ទាប់ពីដាក់លិខិតជូនប្រធានការិយាល័យអប់រំ យុវជន និងកីឡាស្រុករួចមក អ្នកសិក្សាស្រាវជ្រាវបានធ្វើការទាក់ទងតាមទូរស័ព្ទដោយផ្ទាល់ជាមួយនាយក/នាយករងគ្រប់សាលាគោលដៅ ដើម្បីជម្រាបជូនពួកគាត់ពីគោលបំណងនៃការសិក្សាស្រាវជ្រាវ ហើយក៏បានធ្វើការណាត់ជួប និងសុំកិច្ចសហការណ៍ ដោយកំណត់ថ្ងៃខែ និងក្រុមគោលដៅដែលត្រូវជួបជាមុន ។

នៅថ្ងៃចុះប្រមូលទិន្នន័យ អ្នកសិក្សាបានទៅដល់សាលាគោលដៅតាមកាលកំណត់ ដោយដំបូងជួបជារួមជាមួយនាយក/នាយករង និងលោកគ្រូ/អ្នកគ្រូ ដោយជូនលិខិតអនុញ្ញាត និងជម្រាបជូនពួកគាត់ពីគោលបំណងនៃកាសិក្សាស្រាវជ្រាវបន្ថែមម្តងទៀត និងសុំឱ្យពួកគាត់ជួយឆ្លើយកម្រងសំណួរ ។ ក្រោយមក អ្នកសិក្សាបានជួបដាច់ដោយឡែកជាមួយនាយក/នាយករង ដើម្បីសម្ភាសបន្ថែមលើបញ្ហាមួយចំនួនដែលទាក់ពាក់ព័ន្ធនឹងប្រធានបទនៃការស្រាវជ្រាវនេះ ។ ជាចុងក្រោយ អ្នកសិក្សាជួបជាមួយសិស្សនៅបន្ទប់រួមមួយដែលមានសិស្សចម្រុះគ្នាថ្នាក់ទី៧ ថ្នាក់ទី៨ និងថ្នាក់ទី៩ ដែលគណៈគ្រប់គ្រងសាលាបានរៀបចំចាត់ចែងឱ្យ និងបានជម្រាបជូនពួកគេពីគោលបំណងនៃការសិក្សាស្រាវជ្រាវ និងសុំឱ្យពួកគេជួយបំពេញកម្រងសំណួរ ដោយមានការពន្យល់ និងណែនាំពីរបៀបឆ្លើយយ៉ាងល្អិតល្អន់មុននឹងឱ្យពួកគេឆ្លើយសំណួរ ។ ក្រោយពីក្រុមគោលដៅបំពេញកម្រងសំណួរចប់សព្វគ្រប់ អ្នកសិក្សាបានប្រមូលកម្រងសំណួរ និងចម្លើយដែលបានពីការសម្ភាសនាយក/នាយករងមកធ្វើការវិភាគទិន្នន័យ ។

ការសិក្សាស្រាវជ្រាវនេះបានធ្វើឡើងទៅតាមទីកន្លែងដែលបានជ្រើសរើស ហើយមានរយៈពេល ៧ ថ្ងៃ គឺចាប់ពីថ្ងៃទី៣ ខែកក្កដា ដល់ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៨ ។

## ៣.៨ ការវិភាគទិន្នន័យ

រាល់ចម្លើយដែលបានមកពីការបំពេញកម្រងសំណួរ បូករួមទាំងចម្លើយដែលបានមកពីការសម្ភាសនាយក/នាយករង ត្រូវបានយកមកវិភាគដោយប្រើវិធីសាស្ត្របរិមាណវិស័យ និងគុណវិស័យ ។ ការវិភាគទិន្នន័យបែបបរិមាណវិស័យ អ្នកស្រាវជ្រាវបានប្រើប្រាស់វិធីសាស្ត្រវិភាគតាមបែបពណ៌នាស្ថិតិ (Descriptive Statistics) រកតម្លៃមធ្យម (M) តម្លៃគម្លាតស្តង់ដារ (SD) ដើម្បីឆ្លើយសំណួរស្រាវជ្រាវទី១ និងទី៣ ។ ដើម្បីឆ្លើយសំណួរស្រាវជ្រាវទី២ ក្នុងការកំណត់ភាពខុសគ្នានៃតម្លៃមធ្យមនៅក្នុងក្រុមភេទ កម្រិតថ្នាក់ និងតំបន់ អ្នកសិក្សាប្រើវិធី Independent-Samples T Test និង One-Way ANOVA ដើម្បីពិនិត្យទៅលើតម្លៃ Sig. (P-value) ក្នុងកម្មវិធី SPSS Version 22 និងកម្មវិធី Ms. Excel 2016 ដើម្បីសង់ក្រាហ្វិក និងផ្គុំតារាងបញ្ចូលគ្នា ។

ចំពោះការវិភាគទិន្នន័យដើម្បីឆ្លើយសំណួរស្រាវជ្រាវទី១ ដែលលើកឡើងថា តើសិស្សនៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ចាមមានឥរិយាបថដូចម្តេចខ្លះចំពោះមុខវិជ្ជាភាសាអង់គ្លេស អ្នកស្រាវជ្រាវបានធ្វើការវិភាគបែបពណ៌នាស្ថិតិ (Descriptive Statistics) តាមកម្មវិធី SPSS Version 22 ដែលទិន្នន័យបង្ហាញចេញមកជាតម្លៃមធ្យម (M) តម្លៃគម្លាតស្តង់ដារ (SD) ។ ផ្អែកតាមលទ្ធផលនៃការវិភាគនេះ អ្នកសិក្សាបានដាក់កម្រិតចម្លើយ និងចំណាត់ថ្នាក់ចម្លើយ និងបានធ្វើការវាស់វែងកម្រិតនៃឥរិយាបថរបស់សិស្សដែលមានធាតុ ៣ គឺ៖

| | | |
|---|---|---|
| ឥរិយាបថ | អារម្មណ៍ៈចូលចិត្ត ឬមិនចូលចិត្ត<br>យល់ដឹងៈគំនិត ទស្សនៈ ការជឿជាក់<br>អាកប្បកិរិយាៈសកម្មភាព ប្រតិកម្មតប | (Wenden, 1991) |

ដោយប្រើប្រាស់រូបមន្តរបស់លោក Oxford Bury-Stock (1995) ។ យោងតាមលោក Oxford និងលោក Bury-Stock (1995) ការវាយតម្លៃឥរិយាបថមាន ៣ កម្រិតគឺ៖

[M= 3.5 - 5.0 → កម្រិតខ្ពស់]

[M= 2.5 - 3.4 → កម្រិតមធ្យម]

[M= 1.0 - 2.4 → កម្រិតទាប]

## ៣.៩ ក្រមសីលធម៌នៃការសិក្សាស្រាវជ្រាវ

ក្រមសីលធម៌មានសារៈសំខាន់ណាស់សម្រាប់ការស្រាវជ្រាវ ពីព្រោះរាល់សំណួរ និងការសម្ភាសគឺអ្នកស្រាវជ្រាវមិនធ្វើឱ្យប៉ះពាល់ដល់អ្នកចូលរួមទេ ។ ដើម្បីរក្សាក្រមសីធម៌ អ្នកស្រាវជ្រាវបានណែនាំខ្លួន ប្រាប់ពីគោលបំណង រយៈពេលឆ្លើយសំណួរ និងការសុំសម្ភាស ការសន្យាលើលក្ខខណ្ឌមួយចំនួនដូចជា ការរក្សាការសម្ងាត់ជូនអ្នកចូលរួម ហើយព័ត៌មានដែលបានទទួលនឹងមិនត្រូវបានយកទៅប្រើប្រាស់ក្នុងគោលបំណងអ្វីផ្សេងទៀតឡើយ ។ រាល់ការសម្ភាសត្រូវបានសុំការអនុញ្ញាត និងមានការឯកភាពពីអ្នកដែលឆ្លើយតបការសម្ភាស ។ ក្នុងដំណើរការសម្ភាសគឺបានជ្រើសរើសកន្លែងដែលមិនមានការរំខានពីមជ្ឈដ្ឋានខាងក្រៅ ។ អ្នកសម្ភាសបានស្លៀកពាក់សម្លៀកបំពាក់សមរម្យ ទឹកមុខស្រស់ស្រាយ ញញឹមរួសរាយ និងបង្ហាញនូវភាពស្និទ្ធស្នាល សម្ដីទន់ភ្លន់ និងអង្គុយតាមបែបបទនៃគោលការណ៍អ្នកសម្ភាស ។

## ៣.១០ ព្រំដែននៃការសិក្សាស្រាវជ្រាវ

ការសិក្សានេះផ្តោតលើឥរិយាបថរបស់សិស្សចំពោះមុខវិជ្ជាភាសាអង់គ្លេស ភាពដូចគ្នា ឬខុសគ្នារវាងឥរិយាបថរបស់សិស្សដោយផ្អែកលើភេទ កម្រិតថ្នាក់ និងតំបន់ និងបញ្ហាប្រឈមនានាក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាបឋមភូមិក្នុងក្រុង/ស្រុកចំនួន ៦ ក្នុងខេត្តកំពង់ចាមតែប៉ុណ្ណោះ ។ ក្រុមគោលដៅដែលបានជ្រើសរើសយកមកសិក្សាគឺមាននាយក/នាយករង គ្រូបង្រៀនភាសាអង់គ្លេសថ្នាក់ទី៧ ដល់ទី ៩ (ដោយមិនគិតឯកទេស) និងសិស្សថ្នាក់ទី៧ ដល់ទី៩ ។ រាល់សំណួរ និងការសម្ភាសមិនបានសួរ និងសម្ភាសពីអ្វីដែលមិនទាក់ទងទៅនឹងប្រធានបទនោះទេ ។

ព័ត៌មានដែលទទួលបានត្រូវបានរក្សាទុកជាការសម្ងាត់ និងមិនបានយកឈ្មោះ ឬអ្វីដែលបញ្ជាក់ពីអត្តសញ្ញាណរបស់អ្នកចូលរួមទេ ។ ម្យ៉ាងវិញទៀត ចំពោះតំបន់គោលដៅដែលបានជ្រើសរើសយកមកសិក្សាមានលក្ខណៈតូចចង្អៀតនៅឡើយ ដូច្នេះ វាមិនអាចតំណាងឱ្យតំបន់ ឬខេត្តផ្សេងៗទៀតបានទេ ។

# ជំពូកទី៤
# លទ្ធផលស្រាវជ្រាវ

# ជំពូកទី៤
# លទ្ធផលស្រាវជ្រាវ និងការពិភាក្សា

នៅក្នុងជំពូកនេះ អ្នកស្រាវជ្រាវនឹងធ្វើការបង្ហាញ បកស្រាយ និងពិភាក្សាលទ្ធផលនៃការវិភាគទិន្នន័យដែលបានមកពីការបំពេញកម្រងសំណួរ និងការសម្ភាសនាយក/នាយករង ដើម្បីឱ្យដឹងថាតើសិស្សនៅកម្រិតមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ចាមមានឥរិយាបថបែបណា ចំពោះមុខវិជ្ជាភាសាអង់គ្លេស ហើយបើគិតតាមភេទ កម្រិតថ្នាក់ និងតំបន់ តើសិស្សនៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ចាមមានឥរិយាបថខុសគ្នាឬទេចំពោះមុខវិជ្ជាភាសាអង់គ្លេស និងដើម្បីឱ្យដឹងថាតើអ្វីខ្លះជាបញ្ហាប្រឈមក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ចាមនាពេលបច្ចុប្បន្ន ។

## ៤.១ ការវិភាគទិន្នន័យលើកម្រងសំណួរ

### *៤.១.១ កម្រងសំណួរផ្នែកទី១៖ ព័ត៌មានទូទៅ*

ក្នុងការសិក្សាស្រាវជ្រាវនេះ អ្នកស្រាវជ្រាវបានកំណត់យកសាលាចំនួន ១៥ ក្នុងក្រុង/ស្រុកចំនួន ៦ ក្នុងខេត្តកំពង់ចាម ជាគោលដៅនៃការសិក្សាស្រាវជ្រាវ ដោយ ១ ស្រុកយកសាលាចំនួន ៣ គឺវិទ្យាល័យធំជាងគេ ១ នៅតំបន់ប្រជុំជន និងអនុវិទ្យាល័យចំនួន ២ គឺអនុវិទ្យាល័យ ១ នៅចន្លោះទីប្រជុំជន និងទីជនបទ និងអនុវិទ្យាល័យ ១ ទៀតនៅទីជនបទ ឬតំបន់ចុងកាត់មាត់ញកនៃស្រុកនីមួយៗ លើកលែងតែក្រុងកំពង់ចាម គឺយកតែ ១ វិទ្យាល័យ ដោយសារតែក្រុងកំពង់ចាមមិនមានអនុវិទ្យាល័យម៉្យាងទៀត វិទ្យាល័យទាំងនោះមានទីតាំងនៅជិតៗគ្នា និងស្រុកកំពង់សៀម គឺកំណត់យកតែ ២ សាលា គឺអនុវិទ្យាល័យអង្គរ និងអនុវិទ្យាល័យថ្មគោល ដែលសាលាទាំង ២ នេះមានទីតាំងនៅជិតទីរួមខេត្តជាងគេ ហើយក្រុងកំពង់ចាមបូកនឹងស្រុកកំពង់សៀមសន្មតថាជាមួយស្រុក ។

**តារាងទី៣៖ សង្ខេបព័ត៌មានទូទៅ**

| ល.រ | ខេត្ត | ក្រុង/ស្រុក | សាលាគោលដៅ | អ្នកចូលរួម | | | |
|---|---|---|---|---|---|---|---|
| | | | | នាយក | គ្រូ | សិស្ស | សរុប |
| 1 | កំពង់ចាម | កំពង់ចាម | វិ. ព្រះសីហនុ | 01 | 02 | 27 | 30 |
| 2 | | កំពង់សៀម | អនុ. អង្គរ | 01 | 03 | 31 | 34 |
| 3 | | | អនុ. ថ្មគោល | 01 | 02 | 29 | 32 |
| 4 | | កោះសូទិន | វិ. ជីហែ | 01 | 02 | 33 | 36 |
| 5 | | | អនុ. ល្វេ | 01 | 01 | 30 | 32 |
| 6 | | | អនុ. ព្រែកតានង់ | 01 | 01 | 30 | 32 |
| 7 | | ព្រៃឈរ | វិ. នរ. រណឫទ្ធិ-គន្ធបុប្ផា | 01 | 02 | 33 | 36 |
| 8 | | | អនុ. ខ្វិតធំ | 01 | 01 | 30 | 32 |
| 9 | | | អនុ. ប្រិមប្រិយ៍ | 01 | 01 | 30 | 32 |
| 10 | | បាធាយ | វិ. ហាហ. ព្រៃញា | 01 | 03 | 30 | 34 |
| 11 | | | អនុ. ទំនប់ | 01 | 01 | 30 | 32 |
| 12 | | | អនុ. ត្រប់ | 01 | 01 | 30 | 32 |
| 13 | | ស្រីសន្ធរ | វិ. ស្រីសន្ធរ | 01 | 01 | 30 | 32 |
| 14 | | | អនុ. បារាយណ៍ | 01 | 01 | 31 | 33 |
| 15 | | | អនុ. ស្វាយពោធិ៍ | 01 | 01 | 40 | 42 |
| **សរុប** | **01** | **06** | **15** | **15** | **23** | **464** | **502** |

តាមរយៈតារាងខាងលើ យើងឃើញថា ទំហំនៃភាគសំណាកមានការប្រែប្រួលខុសពីផែនការដែលបានដាក់ចេញ ។ នៅក្នុងផ្នែកវិធីសាស្ត្រស្រាវជ្រាវ ចំនួនគ្រូបង្រៀនភាសាអង់គ្លេសក្នុង ១ សាលា ៣ នាក់ សរុបទាំងអស់ ៤៥ នាក់ តែចូលរួមជាក់ស្តែងបានតែ ២៣ នាក់ ។ បញ្ហានេះបណ្តាលមកពីចំនួនគ្រូបង្រៀនភាសាអង់គ្លេសជាក់ស្តែងនៅតាមសាលាគោលដៅទាំងអស់មិនគ្រប់តាមចំនួនដែលចង់បាន គឺនៅក្នុងសាលាគោលដៅទាំង ១៥ មានគ្រូបង្រៀនភាសាអង់គ្លេសនៅកម្រិតបឋមសិក្សាបឋមភូមិតែ ២៧ នាក់ប៉ុណ្ណោះ ។ ទោះជាយ៉ាងណាក៏ដោយ ចំនួនគ្រូបង្រៀនភាសាអង់គ្លេសដែលបានចូលរួមជាក់ស្តែងចំនួន ២៣ នាក់ គឺស្មើ ៨៥% ជាចំនួនច្រើនលើសលុប ។ ចំណែកឯចំនួនសិស្សដែលចូលរួមជាក់ស្តែងក៏មិនត្រូវតាមផែនការដែលបានកំណត់ដែរ គឺលើសផែនការចំនួន ១៩ នាក់ ។ យោងតាមការគណនាតាមគេហទំព័រ (www.openepi.com) ដើម្បីរកកម្រិតនៃភាពជឿជាក់ ក្នុងនោះកម្រិតជឿជាក់ ៩៥% ត្រូវយកសិស្ស ៤៥០ នាក់ ដែលក្នុង ១ សាលាត្រូវយកសិស្សប្រហែល ៣០ នាក់ តែនៅពេលចូលរួមជាក់ស្តែង សាលាខ្លះសិស្សចូលរួមមិនគ្រប់ ដោយសារការចុះប្រមូលទិន្នន័យមិនចំវេនដែលសិស្សត្រូវមករៀន (វេនសិស្សរៀនពេលព្រឹក ចុះប្រមូលពេលថ្ងៃ) រីឯសាលាខ្លះមានកម្មវិធីផ្សេងៗដែលធ្វើឱ្យសិស្សមិនអាចចូលរួមបានគ្រប់ចំនួន ។ ចំណែកឯសាលាខ្លះចំនួនសិស្សចូលរួមលើសពីផែនការគឺដោយសារសាលារៀបចំចំនួនសិស្សដាក់ឱ្យមកចូលរួមលើស ដោយប្រាប់ថាពួកគេសុំចូលរួមដែរ ដែលធ្វើឱ្យអ្នកស្រាវជ្រាវពិបាកនឹងដក ឬដេញពួកគេចេញពីបន្ទប់វិញណាស់ ។ ដូចនេះតាមរយៈតារាងសង្ខេបព័ត៌មានទូទៅខាងលើ ចំនួនភាគសំណាកសរុបស្មើនឹង ៥០២ ភាគសំណាក ។

### *៤.១.២ កម្រងសំណួរផ្នែកទី២*

#### *៤.១.២.១ កម្រងសំណួរអំពីឥរិយាបថរបស់សិស្សចំពោះមុខវិជ្ជាភាសាអង់គ្លេស*

**សំណួរស្រាវជ្រាវទី១៖ តើសិស្សនៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ចាមមានឥរិយាបថដូចម្តេចខ្លះចំពោះមុខវិជ្ជាភាសាអង់គ្លេស?**

**<u>កំណត់សម្គាល់ ១</u>៖** កម្រិតនៃចម្លើយមាន 5 គឺ 1 = SD = មិនយល់ស្របទាល់តែសោះ 2 = D = មិនយល់ស្រប 3 = N = អព្យាក្រឹត 4 = A = យល់ស្រប និង5 = SA = យល់ស្របទាំងស្រុង ។

**<u>កំណត់សម្គាល់ ២</u>៖** ចំពោះសំណួរទី7, 13, 16, 17, 20 និង21 ដែលមានអក្សរ**ដិត** និង*វ្រេត* ជាសំណួរបែបអវិជ្ជមានដែលតម្រូវឱ្យយើងធ្វើការ Transform កម្រិតចម្លើយនៅក្នុងកម្មវិធី SPSS ជាមុនសិនមុននឹងធ្វើការវិភាគ ទើបអាចរកតម្លៃមធ្យម និងគម្លាតស្តង់ដារបានត្រឹមត្រូវ ។ ដូចនេះ SD ប្តូរទៅជា SA ហើយ D ប្តូរទៅជា A វិញ ប៉ុន្តែ N នៅដដែល ។

**តារាងទី៤៖ចំនួនអ្នកឆ្លើយសំណួរតាមកម្រិត**

| ល.រ | សំណួរអំពីឥរិយាបថរបស់សិស្សចំពោះមុខវិជ្ជាភាសាអង់គ្លេស | ចំនួនអ្នកឆ្លើយសំណួរតាមកម្រិត | | | | |
|---|---|---|---|---|---|---|
| | | 1 | 2 | 3 | 4 | 5 |
| | | SD | D | N | A | SA |
| 7 | ***ខ្ញុំចូលចិត្តរៀនភាសាកំណើតរបស់ខ្ញុំជាងភាសាណាៗទាំងអស់*** | 45 | 148 | 81 | 154 | 30 |
| 8 | ខ្ញុំមានអារម្មណ៍ថាមានមោទនភាពណាស់ដែលបានសិក្សាភាសាអង់គ្លេស | 7 | 21 | 15 | 299 | 119 |

| | | | | | | |
|---|---|---|---|---|---|---|
| 9 | ការសិក្សាភាសាអង់គ្លេសធ្វើឱ្យខ្ញុំកាន់តែមានទំនុកចិត្ត | 5 | 26 | 22 | 297 | 106 |
| 10 | ការចេះភាសាអង់គ្លេសគឺជាគោលបំណងសំខាន់នៅក្នុងជីវិតរបស់ខ្ញុំ | 8 | 27 | 26 | 260 | 138 |
| 11 | ខ្ញុំរីករាយនឹងការសិក្សាមុខវិជ្ជាភាសាអង់គ្លេសជាងមុខវិជ្ជាដទៃទៀត | 20 | 121 | 109 | 158 | 49 |
| 12 | ខ្ញុំមានចំណេះ និងការយល់ដឹងកាន់តែច្រើន ពេលដែលខ្ញុំរៀនភាសាអង់គ្លេស | 8 | 15 | 12 | 261 | 166 |
| 13 | *និយាយដោយត្រង់ ខ្ញុំរៀនភាសាអង់គ្លេសគឺដើម្បីឱ្យប្រឡងជាប់តែប៉ុណ្ណោះ* | 16 | 30 | 26 | 229 | 160 |
| 14 | តាមគំនិតខ្ញុំ មនុស្សដែលនិយាយភាសាច្រើនជាងមួយ គឺជាមនុស្សដែលមានចំណេះវិជ្ជាខ្ពង់ខ្ពស់ | 13 | 38 | 49 | 248 | 112 |
| 15 | មុខវិជ្ជាភាសាអង់គ្លេសមានវិសាលភាពគ្របដណ្ដប់លើចំណេះដឹងច្រើនវិស័យ | 14 | 38 | 59 | 234 | 110 |
| 16 | *តាមគំនិតរបស់ខ្ញុំ ភាសាអង់គ្លេសគឺពិបាក និងស្មុគស្មាញក្នុងការរៀនណាស់* | 24 | 131 | 66 | 194 | 46 |
| 17 | *ការនិយាយភាសាអង់គ្លេសនៅកន្លែងណាមួយវាធ្វើឱ្យខ្ញុំបារម្ភណាស់* | 35 | 209 | 40 | 115 | 60 |
| 18 | ការរៀនភាសាអង់គ្លេសជួយខ្ញុំឱ្យមានទំនាក់ទំនងល្អជាមួយមិត្តភក្តិ | 5 | 22 | 25 | 300 | 106 |
| 19 | ការរៀនភាសាអង់គ្លេសជួយឱ្យសិស្សរកបាននូវការងារល្អៗនៅថ្ងៃអនាគត | 6 | 8 | 10 | 208 | 229 |
| 20 | *ខ្ញុំមានអារម្មណ៍ខ្មាសអៀនណាស់ក្នុងការនិយាយភាសាអង់គ្លេសនៅចំពោះមុខសិស្សដទៃទៀត* | 22 | 94 | 37 | 223 | 82 |
| 21 | *នៅពេលដែលខ្ញុំមិនបានទៅរៀនខ្ញុំមិនដែលសួរមិត្តភក្តិ ឬសួរគ្រូពីកិច្ចការផ្ទះដែលគ្រូបានដាក់ឱ្យទេ* | 20 | 44 | 17 | 228 | 153 |
| | ភាគរយនៃចំនួនអ្នកឆ្លើយសំណួរតាមកម្រិតនីមួយៗ | **3.56%** | **13.97%** | **8.54%** | **49.02%** | **23.96%** |

តាមរយៈលទ្ធផលនេះបង្ហាញថា ភាគរយខ្ពស់ជាងគេគឺកម្រិត “យល់ស្រប” ដែលមាន 49.02% បន្ទាប់មកគឺកម្រិត “យល់ស្របទាំងស្រុង” 23.96% កម្រិត “មិនយល់ស្រប” 13.97% កម្រិត “អព្យាក្រិត” 8.54% និងកម្រិត “មិនយល់ស្របទាល់តែសោះ” 3.56% ។

ដើម្បីសិក្សាស្វែងយល់ពីឥរិយាបថរបស់សិស្សចំពោះមុខវិជ្ជាភាសាអង់គ្លេស នៅមធ្យមសិក្សាបឋមភូមិ ក្នុងខេត្តកំពង់ចាម អ្នកសិក្សាប្រើសំណួរស្រាវជ្រាវចំនួនបីគឺ ១) តើសិស្សនៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ចាម មានឥរិយាបថដូចម្តេចខ្លះចំពោះមុខវិជ្ជាភាសាអង់គ្លេស? ។ ២) បើគិតតាមភេទ កម្រិតថ្នាក់ និងតំបន់ តើសិស្សនៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ចាម មានឥរិយាបថខុសគ្នាឬទេចំពោះមុខវិជ្ជាភាសាអង់គ្លេស? និង៣) តើអ្វីខ្លះជាបញ្ហាប្រឈមក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ចាមនាពេលបច្ចុប្បន្ន?

ដើម្បីឆ្លើយសំណួរទី១ អ្នកស្រាវជ្រាវប្រើប្រាស់កម្រងសំណួរបែបបរិមាណវិស័យ ហើយសំណួរទី៣ ទាំងបរិមាណវិស័យ និងគុណវិស័យ ហើយប្រើកម្មវិធី SPSS Version 22. ដើម្បីធ្វើការវិភាគទិន្នន័យតាមបែបពណ៌នាស្ថិតិ (Descriptive Statistics) រកតម្លៃមធ្យម (M) តម្លៃគម្លាតស្តង់ដារ (SD) និងភាគរយ ។ ប្រើវិធី Independent-Samples T Test និង One-Way ANOVA សម្រាប់សំណួរទី២ ដើម្បីពិនិត្យមើលលើតម្លៃ Sig. (P-value) ក្នុងការកំណត់ភាពខុសគ្នានៃតម្លៃមធ្យមនៅក្នុងក្រុមភេទ កម្រិតថ្នាក់ និងតំបន់ អមដោយការលើកអំណះអំណាងអំពីទ្រឹស្តី និងការសិក្សាស្រាវជ្រាវពីមុនៗ ថាតើលទ្ធផលនៅក្នុងការសិក្សានេះ ដូចគ្នា ឬខុសគ្នា ។

**លទ្ធផលនៃសំណួរស្រាវជ្រាវទី១៖ តើសិស្សនៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ចាមមានឥរិយាបថដូចម្ដេចខ្លះចំពោះមុខវិជ្ជាភាសាអង់គ្លេស?**

**តារាងទី៥៖ តម្លៃមធ្យម គម្លាតស្តង់ដារ កម្រិត និងចំណាត់ថ្នាក់នៃឥរិយាបថ**

| ល.រ | កម្រិតនៃឥរិយាបថរបស់សិស្សចំពោះមុខវិជ្ជាភាសាអង់គ្លេស | M | SD | Level | Rank |
|---|---|---|---|---|---|
| 7 | *ខ្ញុំចូលចិត្តរៀនភាសាកំណើតរបស់ខ្ញុំជាងភាសាណាៗទាំងអស់* | 2.9 | 1.15 | មធ្យម | 14 |
| 8 | ខ្ញុំមានអារម្មណ៍ថាមានមោទនភាពណាស់ដែលបានសិក្សាភាសាអង់គ្លេស | 4.1 | 0.78 | ខ្ពស់ | 3 |
| 9 | ការសិក្សាភាសាអង់គ្លេសធ្វើឱ្យខ្ញុំកាន់តែមានទំនុកចិត្ត | 4.0 | 0.78 | ខ្ពស់ | 7 |
| 10 | ការចេះភាសាអង់គ្លេសគឺជាគោលបំណងសំខាន់នៅក្នុងជីវិតរបស់ខ្ញុំ | 4.1 | 0.86 | ខ្ពស់ | 4 |
| 11 | ខ្ញុំរីករាយនឹងការសិក្សាមុខវិជ្ជាភាសាអង់គ្លេសជាងមុខវិជ្ជាដទៃទៀត | 3.2 | 1.08 | មធ្យម | 13 |
| 12 | ខ្ញុំមានចំណេះ និងការយល់ដឹងកាន់តែច្រើន ពេលដែលខ្ញុំរៀនភាសាអង់គ្លេស | 4.2 | 0.79 | ខ្ពស់ | 2 |
| 13 | *និយាយដោយត្រង់ ខ្ញុំរៀនភាសាអង់គ្លេសគឺដើម្បីឱ្យប្រឡងជាប់តែប៉ុណ្ណោះ* | 4.1 | 0.99 | ខ្ពស់ | 5 |
| 14 | តាមគំនិតខ្ញុំ មនុស្សដែលនិយាយភាសាច្រើនជាងមួយ គឺជាមនុស្សដែលមានចំណេះវិជ្ជាខ្ពង់ខ្ពស់ | 3.9 | 0.96 | ខ្ពស់ | 9 |
| 15 | មុខវិជ្ជាភាសាអង់គ្លេសមានវិសាលភាពគ្របដណ្ដប់លើចំណេះដឹងច្រើនវិស័យ | 3.9 | 0.98 | ខ្ពស់ | 10 |
| 16 | *តាមគំនិតរបស់ខ្ញុំ ភាសាអង់គ្លេសគឺពិបាក និងស្មុគស្មាញក្នុងការរៀនណាស់* | 3.2 | 1.12 | មធ្យម | 12 |
| 17 | *ការនិយាយភាសាអង់គ្លេសនៅកន្លែងណាមួយវាធ្វើឱ្យខ្ញុំបារម្ភណាស់* | 2.9 | 1.24 | មធ្យម | 15 |
| 18 | ការរៀនភាសាអង់គ្លេសជួយខ្ញុំឱ្យមានទំនាក់ទំនងល្អជាមួយមិត្តភក្តិ | 4.0 | 0.76 | ខ្ពស់ | 6 |
| 19 | ការរៀនភាសាអង់គ្លេសជួយឱ្យសិស្សរកបាននូវការងារល្អៗនៅថ្ងៃអនាគត | 4.4 | 0.74 | ខ្ពស់ | 1 |
| 20 | *ខ្ញុំមានអារម្មណ៍ខ្មាសអៀនណាស់ក្នុងការនិយាយភាសាអង់គ្លេសនៅចំពោះមុខសិស្សដទៃទៀត* | 3.5 | 1.14 | ខ្ពស់ | 11 |
| 21 | *នៅពេលដែលខ្ញុំមិនបានទៅរៀនខ្ញុំមិនដែលសួរមិត្តភក្តិ ឬសួរគ្រូពីកិច្ចការផ្ទះដែលគ្រូបានដាក់ឱ្យទេ* | 4.0 | 1.07 | ខ្ពស់ | 8 |
| | **សរុប** | **3.7** | **0.37** | **ខ្ពស់** | |

ក្នុងការវាយតម្លៃកម្រិតនៃឥរិយាបថរបស់សិស្សចំពោះការសិក្សាភាសាបរទេស មានអ្នកសិក្សាជាច្រើនប្រើប្រាស់រូបមន្តផ្សេងៗគ្នា ប៉ុន្តែនៅក្នុងការសិក្សានេះ អ្នកសិក្សាបានប្រើរូបមន្តរបស់លោក Oxford និង Burry-Stock (1995) (ដូចត្រូវបានដកស្រង់នៅក្នុងអត្ថបទស្រាវជ្រាវរបស់ Tamador Khalaf Abu-Snoubar, 2017) ដើម្បីវាយតម្លៃ ឬវាស់វែងកម្រិតនៃឥរិយាបថរបស់សិស្សចំពោះការសិក្សាភាសាអង់គ្លេសរបស់សិស្សនៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ចាម ។ យោងតាមលោក Oxford និង Burry-Stock ការវាយតម្លៃឥរិយាបថរបស់សិស្សចំពោះការសិក្សាភាសាបរទេសមាន ៣ កម្រិតគឺ តម្លៃមធ្យមចាប់ពី 3.5 ដល់ 5.0 កម្រិតខ្ពស់ តម្លៃមធ្យមចាប់ពី 2.5 ដល់ 3.4 កម្រិតមធ្យម និងតម្លៃមធ្យមចាប់ពី 1.0 ដល់ 2.4 កម្រិតទាប ។

ដូចនេះ បើយោងតាមលទ្ធផលនៃតារាងទី៥ បង្ហាញថាសំណួរចំនួន ១១ (គឺសំណួរទី 8, 9, 10, 12, 13, 14, 15, 18, 19, 20 និង21)មានតម្លៃមធ្យមកម្រិតខ្ពស់ រីឯ ៤ (គឺសំណួទី1, 11, 16 និង17) សំណួរទៀត មានតម្លៃមធ្យមស្ថិតក្នុងកម្រិតមធ្យម ។ សំណួរដែលឈរលំដាប់ទី១ និងមានតម្លៃមធ្យមខ្ពស់ជាងគេបំផុតគឺសំណួរទី19 ដែលលើកឡើងថា *«ការរៀនភាសាអង់គ្លេសជួយឱ្យសិស្សរកបាននូវ*

*ការងារល្អៗនៅថ្ងៃអនាគត»* ដែលមាន M = 4.4 និង SD = 0.74 ។ ចំណាត់ថ្នាក់លេខ២ គឺសំណួរទី12 ដែលលើកឡើងថា *«ខ្ញុំមានចំណេះ និងការយល់ដឹងកាន់តែច្រើនពេលដែលខ្ញុំរៀនភាសាអង់គ្លេស»* ដែលមាន M = 4.2 និង SD = 0.79 ។ ចំណែកឯសំណួរដែលលើកឡើងថា *«ខ្ញុំមានអារម្មណ៍ថាមានមោទនភាពណាស់ដែលបានសិក្សាភាសាអង់គ្លេស»* មាន M = 4.1 ដូចគ្នាទៅនឹងសំណួរទី10 *«ការចេះភាសាអង់គ្លេសគឺជាគោលបំណងសំខាន់នៅក្នុងជីវិតរបស់ខ្ញុំ»* និងសំណួរទី13 *«និយាយដោយត្រង់ខ្ញុំរៀនភាសាអង់គ្លេសគឺដើម្បីឱ្យប្រឡងជាប់តែប៉ុណ្ណោះ»* ប៉ុន្តែវាមានតម្លៃគម្លាតស្តង់ដារ SD = 0.78 < SD = 0.86 (សំណួរទី10) < SD = 0.99 (សំណួរទី13) ឈរលំដាប់ទី៣ ។ បន្ទាប់មក មានចំណាត់ថ្នាក់បន្តបន្ទាប់រហូតដល់សំណួរទី17 ដែលមាន M = 2.9 ស្មើនឹងសំណួរទី7 ដែលនិយាយថា *«ខ្ញុំចូលចិត្តរៀនភាសាកំណើតរបស់ខ្ញុំជាងភាសាណាៗទាំងអស់»* ប៉ុន្តែវាមាន SD = 1.24 > SD = 1.15 (សំណួរទី7) ស្ថិតក្នុងចំណាត់ថ្នាក់លេខ១៥ ។ ជារួម ឥរិយាបថរបស់សិស្សចំពោះមុខវិជ្ជាភាសាអង់គ្លេសនៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ចាម មានកម្រិតខ្ពស់ ដែលមានតម្លៃមធ្យម M = 3.7 និង SD = 0.37 ដោយសារសិស្សមានភាពសប្បាយរីករាយ មានមោទនភាពចំពោះការសិក្សាភាសាអង់គ្លេស មានការឱ្យតម្លៃ និងយល់ច្បាស់ពីសារៈសំខាន់នៃភាសាអង់គ្លេសសម្រាប់អនាគតរបស់ពួកគេ ហើយពួកគេបានខិតខំសិក្សាភាសាអង់គ្លេសដោយយកចិត្តទុកដាក់ ដោយពេញចិត្ត គ្មានការបង្ខិតបង្ខំ ហើយរៀនមិនមែនដើម្បីឱ្យតែប្រឡងជាប់នោះទេ ។ ការរកឃើញនេះគឺដូចគ្នានឹងការរកឃើញរបស់លោក Momani (2009) ដែលបានស្ទាបស្ទង់មតិអំពីឥរិយាបថរបស់សិស្សវិទ្យាល័យចំពោះការរៀនភាសាអង់គ្លេសជាភាសាបរទេស និងសមិទ្ធផលរបស់ពួកគេក្នុងការអាន ។ ការរកឃើញបានបង្ហាញថាអ្នកឆ្លើយសំណួរមានឥរិយាបថវិជ្ជមានចំពោះការសិក្សាភាសាអង់គ្លេស ។ ប៉ុន្តែខុសគ្នាត្រង់លោក Momani សិក្សាទៅលើសិស្សវិទ្យាល័យ ។ Tahaineh និង Dana (2013) បានសិក្សាពីឥរិយាបថរបស់និស្សិតហ្សកដានីអំពីការរៀនភាសាអង់គ្លេស ។ និស្សិតបានបង្ហាញឥរិយាបថវិជ្ជមានចំពោះភាសាអង់គ្លេសជាភាសាបរទេស ក៏ដូចជាចំពោះមនុស្សដែលនិយាយភាសាអង់គ្លេសផងដែរ ។

**តារាងទី៦៖ កម្រិតនៃធាតុទាំងបីនៃឥរិយាបថ**

| ល.រ | **កម្រិតនៃឥរិយាបថអារម្មណ៍របស់សិស្សចំពោះមុខវិជ្ជាភាសាអង់គ្លេស** | M | SD | Level | Rank |
|---|---|---|---|---|---|
| 7 | *ខ្ញុំចូលចិត្តរៀនភាសាកំណើតរបស់ខ្ញុំជាងភាសាណាៗទាំងអស់* | 2.9 | 1.15 | មធ្យម | 5 |
| 8 | ខ្ញុំមានអារម្មណ៍ថាមានមោទនភាពណាស់ដែលបានសិក្សាភាសាអង់គ្លេស | 4.1 | 0.78 | ខ្ពស់ | 1 |
| 9 | ការសិក្សាភាសាអង់គ្លេសធ្វើឱ្យខ្ញុំកាន់តែមានទំនុកចិត្ត | 4.0 | 0.78 | ខ្ពស់ | 3 |
| 10 | ការចេះភាសាអង់គ្លេសគឺជាគោលបំណងសំខាន់នៅក្នុងជីវិតរបស់ខ្ញុំ | 4.1 | 0.86 | ខ្ពស់ | 2 |
| 11 | ខ្ញុំរីករាយនឹងការសិក្សាមុខវិជ្ជាភាសាអង់គ្លេសជាងមុខវិជ្ជាដទៃទៀត | 3.2 | 1.08 | មធ្យម | 4 |
| | **សរុប** | **3.6** | **0.54** | **ខ្ពស់** | **3** |
| ល.រ | **កម្រិតនៃឥរិយាបថយល់ដឹងរបស់សិស្សចំពោះមុខវិជ្ជាភាសាអង់គ្លេស** | M | SD | Level | Rank |

| | | | | | |
|---|---|---|---|---|---|
| 12 | ខ្ញុំមានចំណេះ និងការយល់ដឹងកាន់តែច្រើន ពេលដែលខ្ញុំរៀនភាសាអង់គ្លេស | 4.2 | 0.79 | ខ្ពស់ | 1 |
| 13 | *និយាយដោយត្រង់ ខ្ញុំរៀនភាសាអង់គ្លេសគឺដើម្បីឱ្យប្រឡងជាប់តែប៉ុណ្ណោះ* | 4.1 | 0.99 | ខ្ពស់ | 2 |
| 14 | តាមគំនិតខ្ញុំ មនុស្សដែលនិយាយភាសាច្រើនជាងមួយ គឺជាមនុស្សដែលមានចំណេះវិជ្ជាខ្ពង់ខ្ពស់ | 3.9 | 0.96 | ខ្ពស់ | 3 |
| 15 | មុខវិជ្ជាភាសាអង់គ្លេសមានវិសាលភាពគ្របដណ្តប់លើចំណេះដឹងច្រើនវិស័យ | 3.9 | 0.98 | ខ្ពស់ | 4 |
| 16 | *តាមគំនិតរបស់ខ្ញុំ ភាសាអង់គ្លេសគឺពិបាក និងស្មុគស្មាញក្នុងការរៀនណាស់* | 3.2 | 1.12 | មធ្យម | 5 |
| | **សរុប** | **3.8** | **0.55** | **ខ្ពស់** | **1** |

| ល.រ | កម្រិតនៃឥរិយាបថបែបអាកប្បកិរិយារបស់សិស្សចំពោះមុខវិជ្ជាភាសាអង់គ្លេស | M | SD | Level | Rank |
|---|---|---|---|---|---|
| ***17*** | *ការនិយាយភាសាអង់គ្លេសនៅកន្លែងណាមួយវាធ្វើឱ្យខ្ញុំបារម្ភណាស់* | 2.9 | 1.24 | មធ្យម | 5 |
| 18 | ការរៀនភាសាអង់គ្លេសជួយខ្ញុំឱ្យមានទំនាក់ទំនងល្អជាមួយមិត្តភក្តិ | 4.0 | 0.76 | ខ្ពស់ | 2 |
| 19 | ការរៀនភាសាអង់គ្លេសជួយឱ្យសិស្សរកបាននូវការងារល្អៗនៅថ្ងៃអនាគត | 4.4 | 0.74 | ខ្ពស់ | 1 |
| 20 | *ខ្ញុំមានអារម្មណ៍ខ្មាសអៀនណាស់ក្នុងការនិយាយភាសាអង់គ្លេសនៅចំពោះមុខសិស្សដទៃទៀត* | 3.5 | 1.14 | ខ្ពស់ | 4 |
| 21 | *នៅពេលដែលខ្ញុំមិនបានទៅរៀនខ្ញុំមិនដែលសួរមិត្តភក្តិ ឬសួរគ្រូពីកិច្ចការផ្ទះដែលគ្រូបានដាក់ឱ្យទេ* | 4.0 | 1.07 | ខ្ពស់ | 3 |
| | **សរុប** | **3.8** | **0.56** | **ខ្ពស់** | **2** |

ផ្អែកតាមតារាងទី៦ យើងឃើញថា ផ្នែកទាំងបីនៃឥរិយាបថស្ថិតក្នុងកម្រិតខ្ពស់ដូចៗគ្នា ប៉ុន្តែបើពិនិត្យលើតម្លៃមធ្យមនៃឥរិយាបថយល់ដឹង និងឥរិយាបថបែបអាកប្បកិរិយាវិញ គឺមានតម្លៃមធ្យមស្មើគ្នា គឺ M = 3.8 ប៉ុន្តែឥរិយាបថយល់ដឹងមានគម្លាតស្តង់ដារ SD = 0.55 < SD = 0.56 (នៃម្លាតស្តង់ដារអាកប្បកិរិយា) នាំឱ្យឥរិយាបថយល់ដឹងស្ថិតក្នុងចំណាត់ថ្នាក់លេខ១ ឥរិយាបថបែបអាកប្បកិរិយាស្ថិតក្នុងចំណាត់ថ្នាក់លេខ២ ចំណែកឯឥរិយាបថអារម្មណ៍ស្ថិតក្នុងលំដាប់ទី៣ ដែលមាន M = 3.6 និង SD = 0.54 ។ ជារួម ឥរិយាបថរបស់សិស្សមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ចាមចំពោះមុខវិជ្ជាភាសាអង់គ្លេស គឺស្ថិតក្នុងកម្រិតខ្ពស់ ដែលមាន M = 3.7 និង SD = 0.37 ។ លទ្ធផលនេះបង្ហាញថាសិស្សរីករាយ មានមោទនភាព និងឱ្យតម្លៃខ្ពស់ទៅលើការសិក្សាភាសាអង់គ្លេស ហើយយល់ច្បាស់អំពីសារប្រយោជន៍នៃភាសាអង់គ្លេសសម្រាប់អនាគតរបស់ពួកគេទៅថ្ងៃអនាគត ។

**តារាងទី៧៖ សង្ខេបកម្រិតនៃធាតុទាំងបីនៃឥរិយាបថ**

| ល.រ | កម្រិតនៃឥរិយាបថរួមរបស់សិស្សចំពោះមុខវិជ្ជាភាសាអង់គ្លេស | M | SD | Level | Rank |
|---|---|---|---|---|---|
| 1 | ឥរិយាបថអារម្មណ៍ | 3.6 | 0.54 | ខ្ពស់ | 3 |
| 2 | ឥរិយាបថយល់ដឹង | 3.8 | 0.55 | ខ្ពស់ | 1 |
| 3 | ឥរិយាបថបែបអាកប្បកិរិយា | 3.8 | 0.56 | ខ្ពស់ | 2 |
| | **សរុប** | **3.7** | **0.37** | **ខ្ពស់** | |

យោងតាមលទ្ធផលនៃតារាងទី៦ និងទី៧ ខាងលើ ឥរិយាបថយល់ដឹងស្ថិតក្នុងចំណាត់ថ្នាក់ទី ១ ដែលមាន M = 3.8 និង SD = 0.55 ។ ចំណុចនេះដោយសារតែសិស្សយល់ថា ការចេះភាសាអង់គ្លេស នឹងធ្វើឱ្យពួកគេមានចំណេះដឹងកាន់តែច្រើនលើផ្នែកផ្សេងៗទៀត ហើយនឹងក្លាយជាមនុស្សដែលមានចំណេះដឹងខ្ពង់ខ្ពស់ ដោយសារតែភាសាអង់គ្លេសមានវិសាលភាពទូលំទូលាយ គ្របដណ្តប់ស្ទើរគ្រប់វិស័យ ។ ម៉្យាងទៀត ពួកគេសិក្សាដោយការយល់ និងការពេញចិត្ត មិនមែនដើម្បីឱ្យតែប្រឡងជាប់នោះទេ ហើយសិស្ស ១៩៤នាក់(តារាងទី១ សំណួរទី7) ក្នុងចំណោមសិស្សទាំងអស់យល់ថាភាសាអង់គ្លេសមិនពិបាកស្មុគស្មាញក្នុងការរៀននោះទេ ។ លទ្ធផលនេះដូចគ្នាទៅនឹងការរកឃើញរបស់ Seyed Yousef Savaedi និងSedigheh Vahdat (2017) ដែលបានពិនិត្យមើលឥរិយាបថរបស់សិស្សមធ្យមសិក្សាបឋមភូមិអ៊ីរ៉ង់ចំនួន ៨0 នាក់ បានបង្ហាញថា ជំនឿជាក់អំពីចំណេះដឹង និងការយល់របស់ពួកគេចំពោះភាសាអង់គ្លេសមានលក្ខណៈវិជ្ជមាន ។ ការដែលពូកែភាសាអង់គ្លេសនឹងជួយឱ្យពួកគេរៀនមុខវិជ្ជាដទៃទៀតបានយ៉ាងងាយស្រួល ហើយពួកគេរៀនភាសាអង់គ្លេសមិនមែនដើម្បីឱ្យតែប្រឡងជាប់នោះទេ គឺពួកគេរៀនដោយមានគោលបំណងសម្រាប់ការធ្វើទំនាក់ទំនងគ្នានៅពេលចេញពីសាលាទៀតផង ។ ម៉្យាងទៀត Ajzen (1988) បានបញ្ជាក់ថា ជំនឿជាចំណុចសំខាន់ដែលជាប់ទាក់ទងទៅនឹងការសិក្សារបស់សិស្ស ។ ជំនឿរបស់សិស្សអាចជាឧបសគ្គប្រសិនបើពួកគេជឿថាពួកគេមិនអាចរៀនភាសាថ្មីបានដោយជោគជ័យនោះទេ ។

ចំពោះឥរិយាបថបែបអាកប្បកិរិយាមានចំណាត់ថ្នាក់លេខ ២ មាន M = 3.8 និង SD = 0.56 ។ សិស្សភាគច្រើនលើសលុបឆ្លើយថា ការរៀនភាសាអង់គ្លេសជួយឱ្យពួកគេរកបាននូវការងារល្អនៅថ្ងៃអនាគត និងធ្វើឱ្យពួកគេមានទំនាក់ទំនងល្អជាមួយមិត្តភក្តិ ។ ពួកគេក៏បានបង្ហាញពីការខិតខំរបស់ពួកគេផងដែរក្នុងការសិក្សាភាសាអង់គ្លេស ដោយពួកគេតែងតែសួរនាំមិត្តភក្តិ ឬសួរគ្រូពីកិច្ចការផ្ទះ ឬអ្វីដែលបានបង្រៀនផងដែរ ។ ជាងនេះទៅទៀត ពួកគេមិនសូវជាមានការខ្មាសអៀនច្រើនទេក្នុងការនិយាយភាសាអង់គ្លេសនៅចំពោះមុខមិត្តភក្តិរបស់ពួកគេ ប៉ុន្តែពួកគេនៅមានការបារម្ភនៅឡើយប្រសិនបើពួកគេត្រូវនិយាយភាសាអង់គ្លេសនៅកន្លែងផ្សេង ។ Kara (2009) និយាយថា ឥរិយាបថវិជ្ជមាននាំឱ្យមានការបង្ហាញចេញនូវអាកប្បកិរិយាវិជ្ជមានចំពោះមុខវិជ្ជាសិក្សា ដែលអ្នកចូលរួមស្រូបទាញខ្លួនឯងចូលទៅក្នុងការសិក្សា និងខិតខំកាន់តែខ្លាំង ។ សិស្សបែបនេះក៏ត្រូវបានគេសង្កេតឃើញថាមានបំណងចង់ដោះស្រាយបញ្ហាដើម្បីទទួលបាននូវព័ត៌មាន និងជំនាញដែលមានប្រយោជន៍សម្រាប់ជីវិតប្រចាំថ្ងៃ និងដើម្បីចូលរួមដោយខ្លួនឯងប្រកបដោយភាពរំភើបចិត្ត ។

ចំណែកឯឥរិយាបថអារម្មណ៍វិញ ដែលមាន M = 3.6 និង SD = 0.54 ស្ថិតក្នុងលំដាប់ទី៣ ។ ផ្អែកតាមចម្លើយរបស់សិស្សយើងឃើញថា ពួកគេពិតជាមានមោទនភាពចំពោះខ្លួនគេណាស់ដែលមានឱកាសរៀនភាសាអង់គ្លេស ហើយវាធ្វើឱ្យពួកគេកាន់តែមានទំនុកចិត្តឡើងចំពោះជោគវាសនារបស់ពួកគេទៅថ្ងៃអនាគត ។ លទ្ធផលនេះ ដូចគ្នានឹងការរកឃើញរបស់លោក Shams (2008) ដែលបានធ្វើការសិក្សាក្នុងគោលបំណងសង្កេតមើលឥរិយាបថរបស់សិស្ស ការលើកទឹកចិត្ត និងការព្រួយបារម្ភចំពោះការសិក្សាភាសាអង់គ្លេស ។ តាមការស្រាវជ្រាវបានគូសបញ្ជាក់ថានិស្សិតមានឥរិយាបថវិជ្ជមាន និង

មានសេចក្ដីសាទរជាខ្លាំងចំពោះភាសាអង់គ្លេស ។ ប៉ុន្តែការសិក្សារបស់ Shams (2008) ធ្វើទៅលើនិស្សិត ចំណែកឯការសិក្សានេះធ្វើទៅលើសិស្សមធ្យមសិក្សាបឋមភូមិ ។

**លទ្ធផលនៃសំណួរស្រាវជ្រាវទី២៖ បើគិតតាមភេទ កម្រិតថ្នាក់ និងតំបន់ តើសិស្សនៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ចាម មានឥរិយាបថខុសគ្នាឬទេចំពោះមុខវិជ្ជាភាសាអង់គ្លេស?**

**តារាងទី៨៖ ពិនិត្យភាពខុសគ្នានៃតម្លៃមធ្យមតាមក្រុមភេទនៃឥរិយាបថ**

**កម្រិតនៃឥរិយាបថរបស់សិស្សចំពោះមុខវិជ្ជាភាសាអង់គ្លេសតាមភេទ**

| ល.រ | ឥរិយាបថ | ប្រុស (N=161) | | ស្រី (N=300) | | F | t | p-value (sig.) |
|---|---|---|---|---|---|---|---|---|
| | | M | SD | M | SD | | | |
| 1 | ឥរិយាបថអារម្មណ៍ | 3.6 | 0.63 | 3.6 | 0.49 | 9.43 | -0.31 | 0.02* |
| 2 | ឥរិយាបថយល់ដឹង | 3.8 | 0.57 | 3.8 | 0.55 | 0.00 | -0.06 | 0.97 |
| 3 | ឥរិយាបថបែបអាកប្បកិរិយា | 3.8 | 0.57 | 3.7 | 0.55 | 0.20 | 0.66 | 0.65 |
| | **សរុប** | **3.7** | **0.37** | **3.7** | **0.37** | **0.06** | **0.15** | **0.81** |

P < 0.05*

យោងតាមតារាងទី៨ ដែលបង្ហាញពីភាពខុសគ្នានៃតម្លៃមធ្យមតាមក្រុមភេទ យើងឃើញថាមិនមានភាពខុសគ្នាទេរវាងឥរិយាបថយល់ដឹង និងឥរិយាបថអាកប្បកិរិយា ដោយសារមានតម្លៃ Sig =0.97 > 0.65 > 0.05 ។ នេះមានន័យថា រវាងសិស្សប្រុស និងសិស្សស្រីនៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ចាម មានការយល់ដឹង ឬការឱ្យតម្លៃ និងមានសកម្មភាពចំពោះការសិក្សាភាសាអង់គ្លេសដូចគ្នា ។ ដោយឡែក ចំពោះឥរិយាបថអារម្មណ៍វិញ យើងឃើញថា តម្លៃ Sig =0.02 < 0.05 ដែលនេះមានន័យថា សិស្សប្រុស និងសិស្សស្រីមានអារម្មណ៍ខុសគ្នាចំពោះការសិក្សាភាសាអង់គ្លេស ។ បើយើងពិនិត្យទៅលើតម្លៃមធ្យមនៃក្រុមភេទទាំងពីរនៃឥរិយាបថអារម្មណ៍ យើងឃើញថា ក្រុមភេទទាំងពីរមានតម្លៃមធ្យមស្មើគ្នាគឺ M = 3.6 ប៉ុន្តែ បើពិនិត្យមើលតម្លៃនៃគម្លាតស្តង់ដារវិញ យើងឃើញថា សិស្សស្រីមានឥរិយាបថអារម្មណ៍ល្អជាងសិស្សប្រុស ដោយមាន SD = 0.49 < SD = 0.63 (នៃឥរិយាបថអារម្មណ៍របស់សិស្សប្រុស) ។ ជារួម រវាងសិស្សប្រុស និងសិស្សស្រីនៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ចាម មិនមានឥរិយាបថខុសគ្នានោះទេ ចំពោះមុខវិជ្ជាភាសាអង់គ្លេស គឺពួកគេសុទ្ធតែមានឥរិយាបថវិជ្ជមានចំពោះការសិក្សាភាសាអង់គ្លេស ដោយមាន p = 0.81 > 0.05 ។ ការរកឃើញនេះគឺដូចគ្នាទៅនឹងការស្រាវជ្រាវរបស់ Shahrzad Eshghinejad (2016) ដែលបានធ្វើការសិក្សាពីឥរិយាបថរបស់និស្សិតសាកលវិទ្យាល័យកាស្ហានរបស់ប្រទេសអ៊ីរ៉ង់ (Kashan University, Iran) ។ ការសិក្សាបង្ហាញថាទាំងនិស្សិតប្រុស និងនិស្សិតស្រីមានឥរិយាបថវិជ្ជមានដូចគ្នាទៅលើធាតុទាំងបីនៃឥរិយាបថ ។ ក្នុងការ

សិក្សារបស់គាត់ដដែល ក៏បានរកឃើញដូចគ្នានឹងការសិក្សារបស់យើងដែរថា កម្រិតនៃឥរិយាបថអារម្មណ៍របស់សិស្សស្រីមានកម្រិតខ្ពស់ជាងសិស្សប្រុស ។

**តារាងទី៩៖ ពិនិត្យភាពខុសគ្នានៃតម្លៃមធ្យមតាមក្រុមថ្នាក់នៃឥរិយាបថ**

| កម្រិតនៃឥរិយាបថរបស់សិស្សចំពោះមុខវិជ្ជាភាសាអង់គ្លេសតាមថ្នាក់ | | | | | |
|---|---|---|---|---|---|
| | SS | Df | MS | F | Sig. |
| | | | អារម្មណ៍ | | |
| ចន្លោះក្រុមថ្នាក់ | 1.80 | 2 | 0.90 | 3.08 | 0.06 |
| ក្នុងក្រុមថ្នាក់ | 134.36 | 459 | 0.29 | | |
| **សរុប** | **136.16** | **461** | | | |
| | | | យល់ដឹង | | |
| ចន្លោះក្រុមថ្នាក់ | 0.56 | 2 | 0.28 | 0.92 | 0.40 |
| ក្នុងក្រុមថ្នាក់ | 140.00 | 459 | 0.31 | | |
| **សរុប** | **140.56** | **461** | | | |
| | | | អាកប្បកិរិយា | | |
| ចន្លោះក្រុមថ្នាក់ | 2.14 | 2 | 1.07 | 3.48 | 0.03* |
| ក្នុងក្រុមថ្នាក់ | 141.62 | 459 | 0.31 | | |
| **សរុប** | **143.76** | **461** | | | |
| | | | ឥរិយាបថ | | |
| ចន្លោះក្រុមថ្នាក់ | 0.03 | 2 | 0.02 | 0.12 | 0.89 |
| ក្នុងក្រុមថ្នាក់ | 62.83 | 459 | 0.14 | | |
| **សរុប** | **62.87** | **461** | | | |

P < 0.05*

តារាងទី៩ បង្ហាញពីការប្រៀបធៀបរវាងក្រុមថ្នាក់របស់សិស្សមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ចាម ។ ក្រុមថ្នាក់មាន ៣ ក្រុមគឺ ១)ថ្នាក់ទី៧ ២) ថ្នាក់ទី៨ និង៣) ថ្នាក់ទី៩ ។ យោងតាមវិធី One-Way ANOVA ឥរិយាបថរបស់សិស្សចំពោះមុខវិជ្ជាភាសាអង់គ្លេសគឺមិនខុសគ្នាទៅតាមក្រុមថ្នាក់នោះទេ ដោយហេតុថា F [2, 459] = 0.12, p = 0.89 > 0.05; M = 3.7 និង SD = 0.37 ។ យោងតាមតារាង Descriptives នៅក្នុង Post Hoc Test បង្ហាញថា ១) ថ្នាក់ទី៧ M = 3.7, SD = 0.39 ២) ថ្នាក់ទី៨ M = 3.7, SD = 0.36 និង៣) ថ្នាក់ទី៩ M = 3.7, SD = 0.35 ។ តាមតារាងនេះបង្ហាញថា ឥរិយាបថអារម្មណ៍ និងឥរិយាបថយល់ដឹងរបស់សិស្សមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ចាមចំពោះមុខវិជ្ជាភាសាអង់គ្លេស គឺមិនខុសគ្នាតាមកម្រិតថ្នាក់នោះទេ ដោយហេតុថាឥរិយាបថយល់ដឹង p = 0.40 > ឥរិយាបថអារម្មណ៍ p = 0.06 > 0.05 ។ ដោយឡែក ចំពោះឥរិយាបថបែបអាកប្បកិរិយាវិញ យើងឃើញថា p = 0.03 < 0.05 ដែលនេះមានន័យថា ឥរិយាបថបែបអាកប្បកិរិយារបស់សិស្ស

ខុសគ្នាទៅតាមកម្រិតថ្នាក់ ។ បើយើងពីនិត្យមើលនៅក្នុងតារាង Post Hoc Test យើងឃើញថា មានភាពខុសគ្នារវាងក្រុមថ្នាក់ ២ គឺថ្នាក់ទី៧ និងថ្នាក់ទី៨ ហើយបើយើងពិនិត្យបន្តនៅក្នុងតារាង Descriptives លទ្ធផលបង្ហាញថា ថ្នាក់ទី៧ មានអាកប្បកិរិយាល្អជាងថ្នាក់ទី៨ ដោយហេតុថាថ្នាក់ទី៧ មាន M = 3.8 > M = 3.7 (ថ្នាក់ទី៨) និង SD = 0.55 < SD = 0.58 (ថ្នាក់ទី៨) ។ ជារួម ឥរិយាបថរបស់សិស្សមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ចាម ចំពោះមុខវិជ្ជាភាសាអង់គ្លេសមិនខុសគ្នាទៅតាមកម្រិតថ្នាក់នោះទេ ដោយសារ p = 0.89 > 0.05 ។ លោក Mehmet Nuri Gömleksiz (2010) បានធ្វើការសិក្សាអំពីឥរិយាបថរបស់និស្សិតឆ្នាំទី១ និងឆ្នាំទី២នៃសាកលវិទ្យាល័យហ្វារ៉ាតប្រទេសតួគី (Farat University, Turkey) ដោយផ្តោតលើភេទ កម្រិតថ្នាក់ និងបម្រែបម្រួលដេប៉ាតឺម៉ង់ ។ ក្នុងការសិក្សានោះ គាត់រកឃើញថា និស្សិតឆ្នាំទី២ មានឥរិយាបថល្អប្រសើរជាងនិស្សិតឆ្នាំទី១ ដោយសារពួកគេមានចំណាប់អារម្មណ៍ មានទំនុកចិត្តលើខ្លួនឯង និងយល់ពីសារប្រយោជន៍អំពីភាសាអង់គ្លេសខ្ពស់ជាង ។

**តារាងទី១០៖ ពិនិត្យភាពខុសគ្នានៃតម្លៃមធ្យមតាមក្រុមតំបន់នៃឥរិយាបថ**

| កម្រិតនៃឥរិយាបថរបស់សិស្សចំពោះមុខវិជ្ជាភាសាអង់គ្លេសតាមតំបន់ | | | | | |
|---|---|---|---|---|---|
| | SS | Df | MS | F | Sig. |
| | | | អារម្មណ៍ | | |
| ចន្លោះក្រុមតំបន់ | 0.04 | 2 | 0.02 | 0.07 | 0.93 |
| ក្នុងក្រុមតំបន់ | 136.12 | 459 | 0.30 | | |
| **សរុប** | **136.16** | **461** | | | |
| | | | យល់ដឹង | | |
| ចន្លោះក្រុមតំបន់ | 0.63 | 2 | 0.31 | 1.03 | 0.36 |
| ក្នុងក្រុមតំបន់ | 139.94 | 459 | 0.30 | | |
| **សរុប** | **140.56** | **461** | | | |
| | | | អាកប្បកិរិយា | | |
| ចន្លោះក្រុមតំបន់ | 0.36 | 2 | 0.18 | 0.57 | 0.56 |
| ក្នុងក្រុមតំបន់ | 143.40 | 459 | 0.31 | | |
| **សរុប** | **143.76** | **461** | | | |
| | | | ឥរិយាបថ | | |
| ចន្លោះក្រុមតំបន់ | 0.27 | 2 | 0.13 | 0.98 | 0.37 |
| ក្នុងក្រុមតំបន់ | 62.60 | 459 | 0.14 | | |
| **សរុប** | **62.87** | **461** | | | |

តារាងទី១០ បង្ហាញពីការប្រៀបធៀបរវាងក្រុមតំបន់របស់សិស្សមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ចាម ។ ក្រុមតំបន់មាន ៣ គឺ ១) តំបន់ប្រជុំជន ២) តំបន់ចន្លោះទីប្រជុំជន និងទីជនបទ និង៣) តំបន់ជនបទ ។ តាមវិធី One-Way ANOVA ឥរិយាបថរបស់សិស្សចំពោះមុខវិជ្ជាភាសាអង់គ្លេស គឺមិនខុសគ្នាទៅតាមក្រុមតំបន់នោះទេ ដោយហេតុថា $F [2, 459] = 0.98$, $p = 0.37$ ($M = 3.7$, $SD = 0.37$) ហើយបើយើងពិនិត្យលើធាតុនីមួយៗនៃឥរិយាបថវិញ តម្លៃ p ក៏មិនបង្ហាញថាខុសគ្នាដែរ (not statistically significant) ដែលឥរិយាបថអារម្មណ៍ $p = 0.93 >$ ឥរិយាបថអាកប្បកិរិយា $p = 0.56 >$ ឥរិយាបថយល់ដឹង $p = 0.36 > 0.05$ ។ តាមវិធី Descriptives នៅក្នុង Post Hoc Test បង្ហាញថា ១) តំបន់ប្រជុំជន $M = 3.8$, $SD = 0.38$ ២) តំបន់ចន្លោះប្រជុំជន និងជនបទ $M = 3.7$, $SD = 0.34$ និង៣) តំបន់ជនបទ $M = 3.7$, $SD = 0.40$ ដែលធាតុទាំងបីសុទ្ធតែស្ថិតនៅក្នុងកម្រិតខ្ពស់ដូចៗគ្នា ។ លទ្ធផលនេះ វាខុសគ្នាពីការសិក្សារបស់ Gajalakshmi (2013) ដែលគាត់បានធ្វើការសិក្សាទៅលើ សិស្សវិទ្យាល័យនៅតំបន់ Puducherry នៃប្រទេសឥណ្ឌា ។ គាត់រកឃើញថាឥរិយាបថរបស់សិស្សមកពីតំបន់ប្រជុំជន មានកម្រិតខ្ពស់ជាងឥរិយាបថរបស់សិស្សមកពីតំបន់ជនបទ ។

### *៤.១.២.២ កម្រងសំណួរអំពីបញ្ហាប្រឈមនានាក្នុងការបង្រៀន និងរៀនភាសាអង់គ្លេស*

**សំណួរស្រាវជ្រាវទី៣៖ តើអ្វីខ្លះជាបញ្ហាប្រឈមក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ចាមនាពេលបច្ចុប្បន្ន?**

ដើម្បីឆ្លើយសំណួរស្រាវជ្រាវទី២ អ្នកស្រាវជ្រាវបានប្រើវិធីសាស្ត្រចម្រុះទាំងបរិមាណវិស័យ និងគុណវិស័យ ដើម្បីធ្វើការវិភាគទៅលើលទ្ធផលដែលទទួលបានពីក្រុមគោលដៅដែលមាន នាយកសាលាចំនួន ១៥ នាក់ គ្រូបង្រៀនភាសាអង់គ្លេសថ្នាក់ទី៧ ដល់ទី៩ ចំនួន ២៣ នាក់ និងសិស្សថ្នាក់ទី៧ ដល់ទី៩ ចំនួន ៤៦៤ នាក់ សរុបទាំងអស់មានចំនួន ៥០២ នាក់ ។ កម្រងសំណួរផ្នែកនេះ អ្នកសិក្សាផ្តោតលើចំណុច ៥ ធំៗ គឺទី១ ចំនួនម៉ោងមុខវិជ្ជាភាសាអង់គ្លេស ទី២ សៀវភៅសិក្សាគោលភាសាអង់គ្លេស ទី៣ គ្រូបង្រៀនភាសាអង់គ្លេស ទី៤ បណ្ណាល័យ ឯកសារស្រាវជ្រាវ និងសម្ភារឧបទេស និងទី៥ ការគ្រប់គ្រងបុគ្គលិក ។ អ្នកស្រាវជ្រាវធ្វើការបង្ហាញ និងវិភាគទិន្នន័យរួមគ្នាតែម្តងរវាងអ្នកចូលរួមទាំងអស់ ។

#### *៤.១.២.២.១ ម៉ោងបង្រៀន និងរៀនភាសាអង់គ្លេស*

##### *៤.១.២.២.១.១ ចំនួនម៉ោងបង្រៀន និងរៀនភាសាអង់គ្លេស*

**ក្រាហ្វិកទី១៖ ចំនួនម៉ោងបង្រៀន និងបរៀនភាសាអង់គ្លេស**




ជាទូទៅ ម៉ោងសម្រាប់មុខវិជ្ជាភាសាអង់គ្លេសនៅមធ្យមសិក្សាបឋមភូមិគឺ ៤ ម៉ោងក្នុង១ សប្តាហ៍ លើកលែងតែសាលា ១ ប៉ុណ្ណោះដែលអនុវត្តតែ ២ ម៉ោងក្នុង ១ សប្តាហ៍សម្រាប់ថ្នាក់ទី៧ និងទី៨ ដោយចែក ២ ម៉ោងទៅឱ្យមុខវិជ្ជាភាសាបារាំង ។ តាមលទ្ធផលនេះបង្ហាញថាចំនួនម៉ោងក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសគឺស្របទៅតាមសេចក្តីណែនាំរបស់ក្រសួង (សេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា លេខ ៤៧ អយក.សណន ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការអនុវត្តសៀវភៅសិក្សាគោលភាសាអង់គ្លេស English Grade 7-9 និងការប្រើប្រាស់សៀវភៅ English is Fun សម្រាប់ការបង្រៀន និងរៀនភាសាអង់គ្លេសនៅមធ្យមសិក្សាបឋមភូមិ ) ។

***៤.១.២.២.១.២ ភាពគ្រប់គ្រាន់នៃចំនួនម៉ោងមុខវិជ្ជាភាសាអង់គ្លេស***

**ក្រាហ្វិកទី២៖ ភាពគ្រប់គ្រាន់នៃចំនួនម៉ោងមុខវិជ្ជាភាសាអង់គ្លេស**




ចំពោះសំណួរស្រាវជ្រាវដែលសួរថា តើចំនួនម៉ោងសម្រាប់មុខវិជ្ជាភាសាអង់គ្លេសគ្រប់គ្រាន់ដែរឬទេ? នាយក ៦៦.៦៧% គ្រូបង្រៀនភាសាអង់គ្លេស ៥២.១៧ % និងសិស្ស ៧១.៥៥ % គិតជាមធ្យមស្មើនឹង ៦៣.៤៦% នៃអ្នកចូលរួមក្នុងការស្រាវជ្រាវឆ្លើយថាគ្រប់គ្រាន់ ។ ដោយឡែកអ្នកចូលរួមប្រមាណជាជាង ៣០% ឆ្លើយថា ៤ ម៉ោង ក្នុង ១ សប្តាហ៍គឺមិនគ្រប់គ្រាន់ទេ ដោយពួកគាត់លើក

ហេតុផលមួយចំនួនដូចតទៅ៖ ១) នាយក/នាយករងពីរនាក់មានប្រសាសន៍ថា «*សិស្សត្រូវការការអនុវត្តច្រើន*» ។ នាយក/នាយករង ៦.៦៦% លើកឡើងថា «*គ្រូចំណាយពេលច្រើន ព្រោះសិស្សគ្មានមូលដ្ឋានគ្រឹះ*» ។ ចំណែកឯនាយក/នាយករង ៦.៦៦% ទៀតបានឆ្លើយថា « *គួរមានចាប់ពី ៦ ទៅ ៨ ម៉ោង*» ។ ២) គ្រូបង្រៀនភាសាអង់គ្លេស៖ គ្រូ ២៦.០៨% ឆ្លើយថា «*មេរៀនច្រើន តែម៉ោងតិច*» ។ គ្រូ ១៧.៣៩% ថា «*ការបង្រៀនមុខវិជ្ជាភាសាអង់គ្លេសមិនដែលទាន់កម្មវិធីសិក្សាទេ*» ។ លោកគ្រូ ១៣.០៤% ទៀតលើកឡើងថា «*សៀវភៅមានអត្ថបទសន្ទនាវែងៗពេក*» ។ ៣) សិស្ស៖ សិស្សចំនួន ១១.៤២% លើកឡើងថា «*ម៉ោងតិចពេក រៀនមិនបានលម្អិតទេ*» ។ សិស្ស ៣.០១% ទៀតឆ្លើយថា «*ពួកគេរៀនមិនទាន់*» ។ ចំណែកឯសិស្ស ០.៤៣% ទៀតថា «*សៀវភៅពុម្ពមានមេរៀនច្រើនពេក*» ។

សរុបមក ចំពោះម៉ោងសម្រាប់មុខវិជ្ជាភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាបឋមភូមិ មិនចោទជាបញ្ហាទេ ដែលជារួមប្រមាណជាជាង ៦០% នៃអ្នកចូលរួមឆ្លើយថាគ្រប់គ្រាន់ ។ ទន្ទឹមនឹងនេះផងដែរ ប្រសិនបើការបង្រៀន និងរៀនមុខវិជ្ជាភាសាអង់គ្លេសនៅបឋមសិក្សាដំណើរការល្អ នោះនឹងរិតតែធ្វើឱ្យការបង្រៀន និងរៀនភាសាអង់គ្លេសនៅមធ្យមសិក្សាបឋមភូមិនឹងប្រព្រឹត្តទៅកាន់តែរលូន ។

#### *៤.១.២.២.២ សៀវភៅសិក្សាគោលសម្រាប់សិស្ស*

##### *៤.១.២.២.២.១ ប្រភេទនៃសៀវភៅសិក្សាគោលសម្រាប់សិស្ស*

**ក្រាហ្វិកទី៣៖ សៀវភៅសិក្សាគោលសម្រាប់សិស្ស**




ក្នុងចំណោមសិស្សថ្នាក់ទី៧ ចំនួន ១៥៩ នាក់ ត្រូវជា ៣៤.២៧% ដែលបានចូលរួមឆ្លើយសំណួរ មាន ២២.៨៤ % ឆ្លើយថាពួកគេប្រើប្រាស់សៀវភៅ English Grade 7, 0.៨ % ឆ្លើយថាពួកគេប្រើប្រាស់សៀវភៅ English is Fun Book 1, 2 ហើយ ១០.៥៦% ឆ្លើយថាពួកគេប្រើប្រាស់ទាំងសៀវភៅ English Grad 7 និង English is Fun Book 1, 2 ព្រមគ្នាតែម្តង ។ រីឯសិស្សថ្នាក់ទី៨ ចំនួន ១៤៧ នាក់ ត្រូវជា ៣១.៦៨% ប្រើប្រាស់សៀវភៅ English Grade 8 ទាំងអស់ ។ ចំណែកឯសិស្សថ្នាក់ទី៩ ចំនួន ១៥៩ នាក់ ត្រូវជា ៣៤.០៥% ដែលបានចូលរួមក្នុងការសិក្សា ២១.៣៤% ប្រើប្រាស់

សៀវភៅ English Grade 9, ៣.៤៥% ប្រើប្រាស់សៀវភៅ English is Fun Book 5, 6 និង៩.០៥% នៅប្រើប្រាស់សៀវភៅចាស់ English for Cambodia Book 3 នៅឡើយ ។

តាមរយៈក្រាហ្វិកនេះយើងឃើញថាការប្រើប្រាស់សៀវភៅសិក្សាគោលនៅតាមគ្រឹះស្ថានសិក្សានៅកម្រិតមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ចាម គឺនៅមិនទាន់មានការឯកភាពគ្នាជារួមស្របតាមសេចក្ដីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា លេខ ៤៧ អយក.សណន ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ ២០១៦ ស្ដីពីការអនុវត្តសៀវភៅសិក្សាគោលភាសាអង់គ្លេស English Grade 7-9 និងការប្រើប្រាស់សៀវភៅ English is Fun សម្រាប់ការបង្រៀន និងរៀនភាសាអង់គ្លេសនៅមធ្យមសិក្សាបឋមភូមិនៅឡើយទេ ជាពិសេសថ្នាក់ទី៧ និងទី៩ ។

#### *៤.១.២.២.២.២ ការចូលចិត្តសៀវភៅសិក្សាគោលសម្រាប់សិស្ស*

**ក្រាហ្វិកទី៤៖ ការចូលចិត្តសៀវភៅសិក្សាគោលសម្រាប់សិស្ស**




យោងតាមក្រាហ្វិកទី៤ បង្ហាញថាសិស្សចូលចិត្តសិក្សាសៀវភៅសិក្សាគោលដែលពួកគេកំពុងតែប្រើខ្លាំងណាស់ ។ នាយក/នាយករង ៩៣.៣៣% ឆ្លើយថា ចូលចិត្ត និងត្រឹមតែ ៦.៦៧% ប៉ុណ្ណោះដែលឆ្លើយថា មិនចូលចិត្ត ។ គ្រូបង្រៀនភាសាអង់គ្លេស ៨២.៦១% ឆ្លើយថាចូលចិត្ត និង១៧.៦១% ឆ្លើយថា មិនចូលចិត្ត ។ ចំណែកឯសិស្សផ្ទាល់វិញ ៩៨.២៨% ឆ្លើយថាចូលចិត្ត ដែលជាភាគរយខ្ពស់បំផុត និងមានត្រឹមតែ១.៥១% ប៉ុណ្ណោះដែលឆ្លើយថាមិនចូលចិត្ត ។ ជារួម ជាង៩០% នៃអ្នកចូលរួមឆ្លើយថាសិស្សចូលចិត្តសិក្សាសៀវភៅសិក្សាគោលដែលពួកគេកំពុងតែប្រើប្រាស់ ដែលមានដូចជា ថ្នាក់ទី៧ សៀវភៅ English Grade 7 និង English is Fun Book 1, 2 ថ្នាក់ទី៨ សៀវភៅ English Grade 8 និងថ្នាក់ទី៩ សៀវភៅ English Grade 9, English is Fun Book 5, 6 និងសៀវភៅ English for Cambodia Book 3 ។

ទោះជាយ៉ាងណាក៏ដោយ ចំពោះអ្នកដែលឆ្លើយថាសិស្សមិនចូលចិត្តសិក្សាសៀវភៅសិក្សាគោលបច្ចុប្បន្ននេះទេ ពួកគាត់បានផ្ដល់នូវហេតុផលមួយចំនួនដូចតទៅ៖ ១) នាយក/នាយករង ៦.៦៦% ឆ្លើយថា «*មកពីសៀវភៅទាំងនេះមានពាក្យជ្រៅៗពេក*» ។ ២) គ្រូបង្រៀនភាសាអង់គ្លេស៖ គ្រូបង្រៀនចំនួន ៨.៦៩% ផ្ដល់ហេតុផលថា «*សៀវភៅនេះស្មុគស្មាញ ច្របូកច្របល់*» ។ ចំណែក

ឯគ្រូ ៤.៣៤% ទៀតថា «*មានវេយ្យាករណ៍ច្រើនជាន់គ្នាដដែលៗ*» ។ ៣) សិស្ស: ដោយឡែកចំពោះសិស្ស ១.៥១% ដែលឆ្លើយថាមិនចូលចិត្តរៀនសៀវភៅសិក្សាគោលទាំងនេះបានផ្តល់ហេតុផលថា «*ពួកគេរៀនមិនទាន់ទេ ព្រោះវាខ្ពស់ជាងសត្ថភាពរបស់ពួកគេ*» ។

សរុបមក ចំពោះសៀវភៅសិក្សាគោល ជាពិសេសសៀវភៅថ្មី English Grade 7, 8 & 9 and English is Fun Book 1, 2, 3, 4, 5 & 6 ទទួលបានការគាំទ្រយ៉ាងច្រើនលើសលុបពីសំណាក់សិស្ស និងលោកគ្រូ/អ្នកគ្រូដែលបង្រៀនភាសាអង់គ្លេស ទោះបីជាមិនទាន់មានការឯកភាពជារួមចំពោះការប្រើប្រាស់សៀវភៅទាំងអស់ក៏ដោយ ជាពិសេសចំពោះថ្នាក់ទី៩ ដែលនៅសាលាខ្លះ គ្រូ និងសិស្សនៅប្រើប្រាស់សៀវភៅចាស់ (EFC Book 3) នៅឡើយ ដោយសារតែសាលាមិនបានទទួលសៀវភៅថ្មីពីក្រសួងតាមការស្នើសុំរបស់សាលា (កង្វះសៀវភៅសិក្សាគោលជាង ៨០% ក្រាហ្វិកទី៦) ។

### *៤.១.២.២.២.៣ កម្រិតសមស្របនៃសៀវភៅសិក្សាគោលសម្រាប់សិស្ស*

**ក្រាហ្វិកទី៥៖ កម្រិតសមស្របនៃសៀវភៅសិក្សាគោលសម្រាប់សិស្ស**




តាមរយៈក្រាហ្វិកនេះ យើងសង្កេតឃើញថា នាយក/នាយករង ៦០% និងសិស្សរហូតដល់ ៩៤.១៨% ឆ្លើយថាសៀវភៅសិក្សាគោលមានកម្រិតសមស្របទៅនឹងសមត្ថភាពរបស់សិស្ស ។ ដោយឡែកចំពោះគ្រូបង្រៀនភាសាអង់គ្លេសវិញ ៥២.១៧% ឆ្លើយថាកម្រិតនៃសៀវភៅសិក្សាគោលមិនសមស្របនឹងចំណេះដឹងរបស់សិស្សទេ ។ ប៉ុន្តែបើគិតជារួម ភាគសំណាកច្រើនជាង ៦០% ដែលយល់ស្របគ្នាថា សៀវភៅសិក្សាគោលមានកម្រិតសមស្របទៅនឹងសមត្ថភាពរបស់សិស្ស ។ ចំពោះភាគសំណាកប្រមាណជាង ៣០% ដែលឆ្លើយថាសៀវភៅសិក្សាគោលមានកម្រិតមិនសមស្របទៅនឹងសមត្ថភាព ក៏ដូចជាចំណេះដឹងរបស់សិស្ស ពួកគាត់បានលើកហេតុផលមួយចំនួនដូចតទៅ៖ ១) នាយក/នាយករងចំនួន ១៣.៣៣% ឆ្លើយថា «*សៀវភៅមានកម្រិតខ្ពស់ជាងសមត្ថភាពសិស្ស*» ។ នាយក/នាយករង ១៣.៣៣% ទៀតលើកឡើងថា «*សិស្សខ្វះចំណេះដឹងមូលដ្ឋាន*» ។ ចំណែកនាយក/នាយករង ៦.៦៦% មានប្រសាសន៍ថា «*សមត្ថភាពរបស់សិស្សមានលក្ខណៈចម្រុះ*» ។ ២) គ្រូបង្រៀនភាសា

អង់គ្លេសៈ គ្រូបង្រៀនចំនួន ២១.៧៣% បានលើកឡើងដូចគ្នាទៅនឹងលោកនាយក/នាយករងដែរគឺ *«ចំណេះដឹងសិស្សទាបជាងសៀវភៅ»* ។ គ្រូបង្រៀន ១៣.០៤% លើកហេតុផលថា *«សិស្សគ្មានចំណេះដឹងមូលដ្ឋានពីថ្នាក់បឋមសិក្សា»* ។ គ្រូ ១៣.០៤% ទៀតមានប្រសាសន៍ថា *«សៀវភៅស្តង់ដារ ហើយ តែសមត្ថភាពសិស្សមិនទាន់មានស្តង់ដារ»* ។ ហើយមានគ្រូបង្រៀន ៤.៣៤% លើកឡើងថា *«សៀវភៅច្របូកច្របល់ ជំហានទីមួយៗមិនច្បាស់»* ។ ទី៣) សិស្សៈ ពួកគាត់ក៏បានផ្តល់នូវហេតុផលមិនខុសគ្នាពីនាយក/នាយករង និងគ្រូបង្រៀនភាសាអង់គ្លេសដែរ ។ សិស្សចំនួន ១.២៩% ឆ្លើយថា *«សៀវភៅមានកម្រិតខ្ពស់ជាងសមត្ថភាពរបស់ពួកគេ»* ។ សិស្សចំនួន ០.៨៦% ទៀតថា *«សៀវភៅមានវេយ្យាករណ៍ច្រើន និងមានពាក្យជ្រៅៗ»* ។ ហើយមានសិស្សចំនួន ០.៦៤% នាក់លើកឡើងថា *«ព្រោះពួកគេមិនបានរៀនភាសាអង់គ្លេសពីថ្នាក់បឋមមកទេ»* ។

ជាទូទៅ យើងអាចនិយាយបានថាកម្រិតនៃសៀវភៅសិក្សាគោលនៅមធ្យមសិក្សាបឋមភូមិ នៅមិនទាន់សមស្របទាំងស្រុងទៅនឹងកម្រិតយល់ដឹងរបស់សិស្សនៅឡើយទេ ដោយសារគ្រូបង្រៀនភាសាអង់គ្លេសជាង ៥០% ដែលជាអ្នកអនុវត្តផ្ទាល់ជាមួយនឹងសៀវភៅទាំងនេះ បានឯកភាពគ្នាថាសៀវភៅសិក្សាគោលសម្រាប់សិស្សមិនសមស្របទៅនឹងសមត្ថភាពរបស់សិស្សទេ ។ មូលហេតុសំខាន់ជាងគេគឺសិស្សមិនមានចំណេះដឹងមូលដ្ឋានពីថ្នាក់បឋមមក ដែលធ្វើឱ្យសិស្សរៀនមិនទាន់ ចាប់មិនបាន ហើយគ្រូក៏ពិបាកបង្រៀនផងដែរ ។

### *៤.១.២.២.២.៤ ភាពគ្រប់គ្រាន់នៃសៀវភៅសិក្សាគោលសម្រាប់សិស្ស*

**ក្រាហ្វិកទី៦៖ ភាពគ្រប់គ្រាន់នៃសៀវភៅសិក្សាគោលសម្រាប់សិស្ស**




បើសង្កេតមើលក្រាហ្វិកទី៦ ដែលបង្ហាញពីភាពគ្រប់គ្រាន់នៃសៀវភៅសិក្សាគោលសម្រាប់សិស្ស យើងឃើញថា ភាគរយរវាងនាយក និងគ្រូគឺប្រហាក់ប្រហែលគ្នា គឺ ៨០% ជាង តែភាគរយដែលទទួលបានពីសិស្សគឺបញ្ច្រាស់គ្នាស្ទើរទាំងស្រុងពីនាយក និងគ្រូ ដែលនេះមិនឆ្លុះបញ្ចាំងពីការពិតនោះទេ ។ ការដែលចម្លើយរបស់សិស្សមិនឆ្លុះបញ្ចាំងពីការពិតជាក់ស្តែងនៃសៀវភៅសិក្សាគោលសម្រាប់សិស្សនេះគឺអាចបណ្តាលមកពីសិស្សមួយចំនួនបានទិញសៀវភៅសិក្សាគោលនេះដោយខ្លួនឯងនៅតាមទីផ្សារយកមកប្រើ ។ ម្យ៉ាងទៀតបើយើងពិនិត្យលើភាគរយរបស់នាយក/នាយករង ដែលពួកគាត់ជាអ្នកគ្រប់គ្រង ពួកគាត់ដឹងច្បាស់ពីតម្រូវការនៃការប្រើប្រាស់សៀវភៅសិក្សាគោលសម្រាប់សិស្សរបស់ពួក

គាត់ យើងពិតជាអាចសន្និដ្ឋានបានថាអ្វីដែលសិស្សឆ្លើយវាពិតជាមិនបានឆ្លុះបញ្ចាំងពីភាពជាក់ស្ដែងនោះទេ ។ ភាពជាក់ស្ដែងគឺថាសៀវភៅសិក្សាគោលមិនថាតែមុខវិជ្ជាភាសាអង់គ្លេសទេ គឺខ្វះសឹងតែគ្រប់មុខ ។ ដូចនេះ ទាក់ទងនឹងសៀវភៅសិក្សាគោលនេះ អ្នកស្រាវជ្រាវធ្វើការវិភាគដោយផ្អែកលើតែចម្លើយរបស់នាយក/នាយករង និងគ្រូបង្រៀនភាសាអង់គ្លេសតែប៉ុណ្ណោះ ។ បើផ្អែកលើភាគរយរបស់នាយក/នាយករង និងគ្រូបង្រៀនភាសាអង់គ្លេស យើងឃើញថា សៀវភៅសិក្សាគោលខ្វះដល់ទៅជាង ៨០% ។ បើយោងតាមលទ្ធផលស្រាវជ្រាវបង្ហាញថា ការដែលខ្វះនេះគឺ នាយក/នាយករងចំនួន ៦០% ឆ្លើយថា «*ក្រសួងផ្ដល់ឱ្យមិនគ្រប់ទៅតាមតម្រូវការរបស់សាលាទេ*» ។ នាយក/នាយករង ២០% ទៀតផ្ដល់ហេតុផលថា «*ដោយសារតែក្រសួងកែតម្រូវសៀវភៅសិក្សាគោលថ្មី ទើបនាំឱ្យមានការយឺតយ៉ាវក្នុងការផ្ដល់ឱ្យ*» ។ ចំណែកឯគ្រូបង្រៀនភាសាអង់គ្លេសវិញ គ្រូចំនួន ៦០.៨៦% បានលើកឡើងដូចនាយក/នាយករងដែរគឺ «*ក្រសួងផ្ដល់ឱ្យមិនគ្រប់ទៅតាមតម្រូវការរបស់សាលាទេ*» ។ រីឯគ្រូបង្រៀនចំនួន ២១.៧៣% ឆ្លើយថា «*មកពីសិស្សកើនឡើងច្រើនពេក ទើបក្រសួងផ្ដល់សៀវភៅឱ្យមិនគ្រប់*» ។ ហើយក៏មាគ្រូ ៤.៣៤% បានឆ្លើយថា «*មកពីសាលារបស់គាត់នៅតំបន់ដាច់ស្រយាល*» ។ ដោយឡែកចំពោះសិស្សវិញ សិស្ស ៣.៨៧% ឆ្លើយថា «*ក្រសួងផ្ដល់ឱ្យមិនគ្រប់*» ។ សិស្ស ១.៩៣% ឆ្លើយថា «*មកពីសិស្សមានចំនួនច្រើនពេក*» ។ រីឯសិស្ស ១.២៩% ថា «*ដោយសារពួកគេប្រើសៀវភៅ ១ ក្បាល ២ នាក់*» ។ ចំណែកឯសិស្ស ០.៤៣% ទៀតថា «*ពួកគេខ្វះសៀវភៅ English is Fun ទាំងស្រុង*» ។

ដូចនេះ សរុបមក សៀវភៅសិក្សាគោលសម្រាប់សិស្សគឺមិនគ្រប់គ្រាន់តាមតម្រូវការជាក់ស្ដែងទេ ។ កង្វះសៀវភៅសិក្សាគោលគឺជាបញ្ហាចម្បងមួយដែលបង្កការរាំងស្ទះដល់ដំណើរការបង្រៀន និងរៀនភាសាអង់គ្លេស នៅមធ្យមសិក្សាបឋមភូមិ ។ កាលណាសិស្សមិនមានសៀវភៅសិក្សាគោលក្នុងដៃធ្វើឱ្យពួកគេបាត់ការផ្ដោតអារម្មណ៍ និងការចាប់អារម្មណ៍ទៅលើមុខវិជ្ជានេះ ។ កាលណាសិស្សបាត់បង់នូវការផ្ដោតអារម្មណ៍ ក៏ដូចជាបាត់បង់នូវការចាប់អារម្មណ៍ទៅលើមុខវិជ្ជានេះ វាក៏បង្កការលំបាកដល់គ្រូបង្រៀនក្នុងការគ្រប់គ្រងថ្នាក់ ដោយសារតែសិស្សមិនសូវយកចិត្តទុកដាក់ស្ដាប់គ្រូ ។ កាលណាសិស្សមិនសូវស្ដាប់គ្រូ ពួកគេក៏មិនអាចទទួលបាននូវចំណេះដឹងពេញលេញដែរ ។ ម៉្យាងទៀត ការសិក្សានាពេលបច្ចុប្បន្នគឺពឹងផ្អែកស្ទើរតែទាំងស្រុងទៅលើសៀវភៅសិក្សាគោល ។ សិស្សមិនត្រូវបានតម្រូវឱ្យកត់ត្រាអ្វីច្រើនដាក់ទៅក្នុងសៀវភៅកត់ត្រារបស់ពួកគេទេ ។ សកម្មភាពផ្សេងៗ ការងារប្រតិបត្តិ និងលំហាត់អនុវត្ត គឺតម្រូវឱ្យសិស្សធ្វើក្នុងសៀវភៅផ្ទាល់តែម្ដង ។

#### ***៤.១.២.២.៣ គ្រូបង្រៀនភាសាអង់គ្លេស***

##### ***៤.១.២.២.៣.១ ឯកទេសគ្រូបង្រៀនភាសាអង់គ្លេស***

**ក្រាហ្វិកទី៧៖ ឯកទេសគ្រូបង្រៀនភាសាអង់គ្លេស**




ផ្អែកតាមលទ្ធផលនៃការវិភាគក្នុងក្រាហ្វិកទី៧ នេះបង្ហាញថា នាយក/នាយករង ៦៦.៦៧% គ្រូបង្រៀនភាសាអង់គ្លេស ៦៤.១៧% និងសិស្ស ៤៧.៤២% ឆ្លើយថាគ្រូបង្រៀនខុសឯកទេស មានន័យថាគាត់មិនមែនជាគ្រូឯកទេសភាសាអង់គ្លេសទេ តែគាត់ទទួលភារកិច្ចបង្រៀនមុខវិជ្ជាភាសាអង់គ្លេស ។ បើយើងរកភាគរយមធ្យមនៃក្រុមគោលដៅទាំងបីគឺស្មើនឹង ៥៩.៤២% ដែលឆ្លើយថាគ្រូដែលកំពុងបង្រៀនភាសាអង់គ្លេសនៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ចាម គាត់មិនមែនជាគ្រូឯកទេសភាសាអង់គ្លេសទេ ។

បញ្ហាគ្រូបង្រៀនខុសឯកទេសក៏ជាកត្តាមួយដែលជះឥទ្ធិពលមិនល្អដល់ដំណើរការបង្រៀន និងរៀនផងដែរ មិនថាតែមុខវិជ្ជាភាសាអង់គ្លេសនោះទេ ។ កាលណាគាត់បង្រៀនខុសឯទេស ឬខុសមុខជំនាញរបស់គាត់ គឺចំណេះដឹងរបស់គាត់មិនបានទូលំទូលាយឡើយ ។ គាត់ពិបាកស្រាវជ្រាវមេរៀន សិស្សមិនសូវមានទំនុកចិត្ត ហើយសិស្សអាចនឹងមិនទទួលបាននូវចំណេះដឹងពេញលេញលើមុខវិជ្ជានេះផងដែរ ។

### *៤.១.២.២.៣.២ ចំណេះដឹងគ្រូបង្រៀនភាសាអង់គ្លេស*

**ក្រាហ្វិកទី៨៖ ចំណេះដឹងគ្រូបង្រៀនភាសាអង់គ្លេស**



លទ្ធផលនៃការស្រាវជ្រាវបានបង្ហាញតាមរយៈក្រាហ្វិកទី៨ នេះថា ចំណេះដឹងភាសាអង់គ្លេសរបស់គ្រូបង្រៀនភាសាអង់គ្លេសនៅមានកម្រិតទាបនៅឡើយ ។ ផ្អែកតាមក្រាហ្វិកនេះ បើគិតជាមធ្យមមានអ្នកចូលរួមតែ ៣៦.៧៦% ប៉ុណ្ណោះដែលឆ្លើយថាចំណេះដឹងគ្រូភាសាអង់គ្លេសស្ថិតក្នុងកម្រិតល្អ ចំណែកឯល្អបង្គួរ មាន ៤០.៥៥% មធ្យមមាន ២១.០៣% និង១.៥៩% ឆ្លើយថាខ្សោយ ។ ជារួម យើងពិនិត្យឃើញថាទាំងល្អ និងល្អបង្គួរគឺនៅក្រោម ៥០% នៅឡើយទេ ។ នេះសបញ្ជាក់ឱ្យយើងដឹងថាសមត្ថភាពក៏ដូចជាចំណេះដឹងគ្រូបង្រៀនភាសាអង់គ្លេស នៅមិនទាន់សមស្របទៅតាមតម្រូវការក្នុងការលើកស្ទួយចំណេះដឹងផ្នែកភាសាអង់គ្លេសរបស់សិស្សនៅឡើយទេ ។ កាលណាចំណេះដឹងលើមុខវិជ្ជាដែលគាត់កំពុងបង្រៀននៅមិនទាន់បានល្អ នោះការបង្រៀន ការផ្ទេរចំណេះដឹងទៅឱ្យសិស្ស ក៏នៅមិនទាន់បានល្អដែរ ។ បញ្ហានេះ អាចបណ្តាលមកពីគ្រូបង្រៀនភាសាអង់គ្លេសភាគច្រើន (៥៩.៤២% ក្រាហ្វិកទី៧) មិនមែនជាគ្រូឯកទេសភាសាអង់គ្លេស ។ ពួកគាត់ត្រូវបានចាត់តាំងឱ្យបង្រៀនមុខវិជ្ជាភាសាអង់គ្លេសទៅតាមស្ថានភាពជាក់ស្តែង នៃសាលានីមួយៗដែលនៅមានបញ្ហាខ្វះគ្រូឯកទេស ។

### *៤.១.២.២.៣.៣ វិធីសាស្ត្របង្រៀនរបស់គ្រូបង្រៀនភាសាអង់គ្លេស*

**ក្រាហ្វិកទី៩៖ វិធីសាស្ត្របង្រៀនរបស់គ្រូបង្រៀនភាសាអង់គ្លេស**




វិធីសាស្ត្របង្រៀនជាចំណុចគន្លឹះក្នុងការផ្ទេរចំណេះដឹងពីគ្រូទៅសិស្ស ។ កាលណាគ្រូមានវិធីសាស្ត្របង្រៀនល្អ វាធ្វើឱ្យដំណើរការបង្រៀន និងរៀនប្រព្រឹត្តទៅដោយរលូន ហើយសិស្សឆាប់ចាប់បាននូវអ្វីដែលគ្រូចង់ឱ្យសិស្សចេះផងដែរ ។ យោងតាមក្រាហ្វិកទី៩ បង្ហាញថានាយក/នាយករង ៦.៦៧% គ្រូ ១៣.០៤% និងសិស្ស ៥៧.៩៥% បើគិតជាមធ្យម ២៥.៨៩% ឆ្លើយថាវិធីសាស្ត្របង្រៀនរបស់គ្រូបង្រៀនភាសាអង់គ្លេសមានលក្ខណៈល្អ ។ ចំណែកឯនាយក/នាយករង ៥៣.៣៣% គ្រូ ៥៦.៥២% និងសិស្ស ៣៤.៩១% ដែលជាមធ្យមស្មើនឹង ៤៨.២៦% ឆ្លើយថាវិធីសាស្ត្របង្រៀនរបស់គាត់ល្អបង្គួរ ។ រីឯនាយក/នាយករង ៤០.០០% គ្រូ ៣០.៤៣% និងសិស្ស ៦.៤៧% គិតជាមធ្យម ២៥.៦៣% ផ្តល់ចម្លើយថាវិធីសាស្ត្របង្រៀនរបស់ពួកគាត់មានកម្រិតមធ្យមប៉ុណ្ណោះ ។ ដោយឡែក

សិស្ស ០.៤៣% វាយតម្លៃវិធីសាស្ត្របង្រៀនរបស់គ្រូបង្រៀនភាសាអង់គ្លេសថាមានកម្រិតខ្សោយ ។ បើពិនិត្យជារួម យើងអាចនិយាយបានថាវិធីសាស្ត្របង្រៀនរបស់គ្រូបង្រៀនភាសាអង់គ្លេសនៅមិនទាន់បានល្អទេ ដែលកត្តានេះក៏អាចជាកត្តាជះឥទ្ធិពលមិនល្អដល់ដំណើរការបង្រៀន និងរៀនភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ចាមផងដែរ ។ ចំណុចនេះក៏មិនខុសពីចំណុចដែលនិយាយអំពីកម្រិតនៃចំណេះដឹងគ្រូបង្រៀនភាសាអង់គ្លេសដែរគឺមួយផ្នែកធំបណ្ដាលមកពីពួកគាត់បង្រៀនខុសឯកទេស (៥៩.៤២% ក្រាហ្វិកទី៧) ។ កាលណាបង្រៀនខុសឯកទេស មិនថាតែចំណេះដឹងលើមុខវិជ្ជាទេដែលមិនទាន់ទូលំទូលាយ សូម្បីតែវិធីសាស្ត្រក្នុងការបង្រៀន យ៉ាងណាក៏មិនដូចគ្រូដែលបង្រៀនត្រូវឯកទេសដែរ ។ ដូចនេះ សរុបមក វិធីសាស្ត្របង្រៀនរបស់គ្រូបង្រៀនភាសាអង់គ្លេសនៅមានបញ្ហានៅឡើយ ដែលតម្រូវឱ្យមានការយកចិត្តទុកដាក់ពីសំណាក់ក្រសួងអប់រំ យុវជន និងកីឡា ក៏ដូចជាអ្នកពាក់ព័ន្ធនានាចូលរួមដោះស្រាយទាំងអស់គ្នា ដោយរៀបចំសិក្ខាសាលា ឬវគ្គបំប៉នសមត្ថភាពខ្លីៗឱ្យបានញឹកញាប់ ទើបអាចកែប្រែស្ថានការណ៍នេះបាន ។

### *៤.១.២.២.៣.៤ អវត្តមានរបស់គ្រូបង្រៀនភាសាអង់គ្លេស*

**ក្រាហ្វិកទី១០៖ អវត្តមានរបស់គ្រូបង្រៀនភាសាអង់គ្លេស**




អវត្តមានបញ្ជាក់ពីការយកចិត្តទុកដាក់ក្នុងការបំពេញការងាររបស់បុគ្គលិក ។ បើបុគ្គលិកណាម្នាក់ឈប់ញឹកញាប់ដោយគ្មានមូលហេតុសមរម្យ វាបញ្ជាក់ឱ្យឃើញថាគាត់បំពេញការងារមិនបានល្អទេ គាត់មិនឱ្យតម្លៃទៅលើការងាររបស់គាត់ទេ ដែលប្រការនេះវាអាចប៉ះពាល់ដល់ការបង្រៀនសិស្សផងដែរ ។

ចំពោះសំណួរដែលលើកឡើងពីបញ្ហាអវត្តមានរបស់គ្រូបង្រៀនភាសាអង់គ្លេស នាយក/នាយករង ៩៩.៣៣% និងសិស្ស ៦៩.៤០% ឆ្លើយថាគ្រូឈប់ម្តងម្កាល ចំណែកឯនាយក/នាយករងត្រឹមតែ ៦.៦៧% និងសិស្ស១៧.៨៩% ឆ្លើយថាគ្រូមិនដែលឈប់ទេ ។ ដោយឡែកក៏មានសិស្ស ១២.៧២% បានឆ្លើយថាគ្រូរបស់ពួកគេឈប់ញឹកញាប់ណាស់ ហើយមិនមាននាយក/នាយករងណាម្នាក់ឆ្លើយថាគ្រូបង្រៀនភាសាអង់គ្លេសរបស់ពួកគាត់ឈប់ញឹកញាប់នោះទេ ។ តាមរយៈក្រាហ្វិកនេះ យើងសង្កេតឃើញថាអវត្តមានរបស់គ្រូបង្រៀនភាសាអង់គ្លេសមិនចោទជាបញ្ហាអ្វីទេ ។ ម្យ៉ាងទៀតទាក់ទងនឹងចំណុចនេះ អ្នកស្រាវជ្រាវបានធ្វើការសម្ភាសជាមួយនាយក/នាយករង ដោយសុំបញ្ជីវត្តមានរបស់បុគ្គលិកមកពិនិត្យ ។ ក្រោយពីពិនិត្យ អ្នកស្រាវជ្រាវអាចធ្វើការសន្និដ្ឋានបានថាសាលាជាង ៩០% សុទ្ធតែមានបញ្ជីវត្តមានរបស់បុគ្គលិកត្រឹមត្រូវ ដោយមានការចុះហត្ថលេខាតាមម៉ោង និងតាមថ្ងៃហើយនឹងបូកយោងតាមខែនីមួយៗ យ៉ាងច្បាស់លាស់ ។ តាមការពិនិត្យ និងកត់ត្រា គ្រូបង្រៀនដែលអវត្តមានច្រើនបំផុតគិតត្រឹមថ្ងៃដែលអ្នកស្រាវជ្រាវចុះប្រមូលទិន្នន័យទៅតាមសាលាគោលដៅទាំង ១៥ នៅដើមខែកក្កដា ឆ្នាំ២០១៨ គឺមានចំនួនត្រឹម ៥ ដង ប៉ុណ្ណោះ (បូកយោងតាមខែ) ។

### *៤.១.២.២.៣.៥ ការគោរពម៉ោងចេញចូលរបស់គ្រូបង្រៀនភាសាអង់គ្លេស*

**ក្រាហ្វិកទី១១៖ ការគោរពម៉ោងចេញចូលរបស់គ្រូបង្រៀនភាសាអង់គ្លេស**




រីឯការគោរពម៉ោងចេញ ម៉ោងចូលបានល្អរបស់គ្រូបង្រៀនក៏បង្ហាញមួយផ្នែកពីការយកចិត្តទុកដាក់ទៅលើការងារបង្រៀនរបស់ពួកគាត់ផងដែរ ។ តាមរយៈក្រាហ្វិកទី១១ មាននាយក/នាយករង ៣៣.៣៣% និងសិស្ស ៥២.៥៩% ឆ្លើយថាគ្រូបង្រៀនភាសាអង់គ្លេសគោរពម៉ោងចេញ ម៉ោងចូលបានល្អ ។ រីឯនាយក/ នាយករង ៦០.០០% និងសិស្ស៣៧.៧២% ឆ្លើយថាគ្រូបង្រៀនភាសាអង់គ្លេសគោរពពេលវេលាបានល្អបង្គួរ និងមាននាយក/នាយករង ៦.៦៧% និងសិស្ស ៩.៤៨% ផ្តល់ចម្លើយថាគ្រូបង្រៀនភាសាអង់គ្លេស គោរពពេលវេលាបានត្រឹមកម្រិតមធ្យម ។ ម្យ៉ាងទៀតសិស្ស ០.២២% ឆ្លើយថាគ្រូរបស់ពួកគេគោរពពេលវេលាចេញចូលបានត្រឹមកម្រិតខ្សោយ ។ ជាទូទៅ យើងអាចនិយាយបានថា លោកគ្រូ/អ្នកគ្រូដែលបង្រៀនភាសាអង់គ្លេសគោរពពេលវេលាបានល្អ ដែលបង្ហាញពីការយកចិត្តទុកដាក់របស់ពួកគាត់ក្នុងការងារបង្ហាត់បង្រៀនកូនសិស្សឱ្យមានចំណេះដឹងទូលំទូលាយ ទោះពួកគាត់មួយចំនួនធំ (៥៩.៤២% ក្រាហ្វិកទី៧) មិនមែនជាគ្រូឯកទេសភាសាអង់គ្លេសក៏ដោយ ។

### *៤.១.២.២.៣.៦ ការប្រើប្រាស់សម្ភារឧបទេសរបស់គ្រូបង្រៀនភាសាអង់គ្លេស*

**ក្រាហ្វិកទី១២៖ ការប្រើប្រាស់សម្ភារឧបទេសរបស់គ្រូបង្រៀនភាសាអង់គ្លេស**




សម្ភារឧបទេសគឺជាជំនួយក្នុងដំណើរការបង្រៀន និងរៀន ។ វាជាកាតាលីករក្នុងកិច្ចដំណើរការបង្រៀន និងរៀន ។ វាធ្វើឱ្យដំណើរការនៃការបង្រៀន និងរៀនប្រព្រឹត្តទៅដោយរលូន ដោយសិស្សឆាប់យល់ និងអាចចងចាំខ្លឹមសារមេរៀនបានយូរ ។ ផ្អែកតាមក្រាហ្វិកទី១២ ដែលបង្ហាញពីការប្រើប្រាស់សម្ភារឧបទេសរបស់គ្រូបង្រៀនភាសាអង់គ្លេស យើងសង្កេតឃើញថា ចំពោះនាយក/នាយករង គ្រូបង្រៀនដែលប្រើប្រាស់សម្ភារឧបទេសញឹកញាប់មិនមានទេ មានតែប្រើប្រាស់ម្ដងម្កាល ៩៣.៣៣% និងមិនដែលប្រើប្រាស់សម្ភារឧបទេសសោះ ៦.៦៧% ។ ចំណែកឯសិស្សានុសិស្សវិញ ១២.៥០% ឆ្លើយថាគ្រូប្រើប្រាស់សម្ភារឧបទេសញឹកញាប់ ៥៥.៨២% ប្រើប្រាស់ម្ដងម្កាល និង៣១.០៣% ឆ្លើយថាមិនដែលប្រើទេ ។

យោងលទ្ធផលខាងលើ ការប្រើប្រាស់សម្ភារឧបទេសក្នុងដំណើរការនៃការបង្រៀន និងរៀនភាសាអង់គ្លេសនៅមានកម្រិតទាបគួរឱ្យកត់សម្គាល់ ។ បើគិតជាមធ្យម គ្រូបង្រៀនត្រឹម ៦.២៥% ប៉ុណ្ណោះដែលប្រើប្រាស់សម្ភារឧបទេសញឹកញាប់ និង៧៤.៥៨% ប្រើប្រាស់ម្ដងម្កាល ។ កត្តានេះបណ្ដាលមកពីកង្វះសម្ភារឧបទេសនៅក្នុងសាលារៀន (៧៨.៦៦% ក្រាហ្វិកទី១៥) និងដោយសារគ្រូមិនបានផលិតដោយជាប់រវល់នឹងជីវភាពប្រចាំថ្ងៃ ។

### *៤.១.២.២.៤ បណ្ណាល័យ ឯកសារស្រាវជ្រាវ និងសម្ភារឧបទេស*

#### *៤.១.២.២.៤.១ បណ្ណាល័យ*

បណ្ណាល័យជាកន្លែងផ្ទុកឯកសារផ្សេងៗដូចជា សៀវភៅសិក្សាគោល ឯកសារអានបន្ថែមដូចជា សៀវភៅព័ត៌មាន សៀវភៅអក្សរសិល្ប៍ សៀវភៅបំណិនជីវិត សៀវភៅបច្ចេកទេស សៀវភៅអប់រំសុខភាព សៀវភៅស្រាវជ្រាវផ្សេងៗទៀត និងឯកសារសោទស្សន៍ដូចជា CD, VCD, DVD, Cassette Tape, Video Tape, MP3, ទូរទស្សន៍ និងម៉ាស៊ីនចាក់ DVD និងកុំព្យូទ័រ ជាដើម ។ល។ ហើយវាក៏ជាកន្លែងដែលគ្រូ និងសិស្សចូលអាន ឬខ្ចីសៀវភៅ និងរកឯកសារពាក់ព័ន្ធនានាដើម្បីជាជំនួយដល់ការបង្រៀន និងរៀនដើម្បីពង្រឹងសមត្ថភាពរបស់ខ្លួនផងដែរ ។ យោងតាមចម្លើយរបស់នាយក/នាយករង និងការសង្កេតមើលដោយផ្ទាល់ពេលចុះប្រមូលទិន្នន័យតាមសាលាគោលដៅទាំង១៥ គឺមានតែសាលាចំនួន ៤ ប៉ុណ្ណោះ (ស្មើនឹង ៧៣.៣៣%) ដែលមានបណ្ណាល័យ ។ ដូចនេះជារួម សាលាភាគច្រើនមិនមានបណ្ណាល័យទេ ។ ការដែលមិនមានបណ្ណាល័យ អាចធ្វើឱ្យគ្រូបង្រៀន និងសិស្សដែលមានបំណង

ចង់អាន ឬរកឯកសារស្រាវជ្រាវផ្សេងៗមានការពិបាក និងបាត់បង់នូវឱកាសក្នុងការពង្រឹងសមត្ថភាពរបស់ពួកគាត់ ព្រោះបណ្ណាល័យជាឃ្លាំងផ្ទុកសៀវភៅ និងឯកសារផ្សេងៗ ។ សៀវភៅ និងឯកសារជាគ្រូរបស់អ្នកសិក្សាគ្រប់កាលៈទេសៈ ។

### *៤.១.២.២.៤.២ ឯកសារស្រាវជ្រាវ*

**ក្រាហ្វិកទី១៣៖ ឯកសារស្រាវជ្រាវដើម្បីពង្រឹងសមត្ថភាពភាសាអង់គ្លេស**




ក្រៅពីសិក្សាជាមួយគ្រូនៅក្នុងថ្នាក់ សិស្សគួរឈ្លាតពេលទំនេររកឯកសារភាសាអង់គ្លេសផ្សេងៗ ដូចជា សៀវភៅរឿងខ្លីៗ សៀវភៅប្រលោមលោក សៀវភៅវិទ្យាសាស្ត្រ ។ល។ ដើម្បីពង្រឹងចំណេះដឹងភាសាអង់គ្លេសរបស់ពួកគេឱ្យកាន់តែទូលំទូលាយឡើង ។

ចំពោះសំណួរដែលសួរថា តើសាលារបស់អ្នកមានឯកសារស្រាវជ្រាវដើម្បីពង្រឹងសមត្ថភាពភាសាអង់គ្លេសរបស់សិស្សគ្រប់គ្រាន់ដែរឬទេ? សិស្ស៥៣.៨៨ % ឆ្លើយថាមានគ្រប់គ្រាន់ ៤៥.៤៧ % ឆ្លើយថាមិនគ្រប់គ្រាន់ ។ ចំណែកឯលោកគ្រូ/អ្នកគ្រូវិញ ៨.៧០ % ប៉ុណ្ណោះឆ្លើយថាគ្រប់គ្រាន់ ហើយ ៩១.៣០ % ឆ្លើយថាមិនគ្រប់គ្រាន់ ។ ចំពោះសំណួរដដែល នាយក/នាយករង ២០.០០ % ឆ្លើយថាគ្រប់គ្រាន់ ហើយ ៨០.០០ % ឆ្លើយថាមិនគ្រប់គ្រាន់ ។ បើគិតជាមធ្យម ៧២.២៦% នៃអ្នកចូលរួមឆ្លើយថាសាលារបស់ពួកគាត់មិនមានឯកសារស្រាវជ្រាវគ្រប់គ្រាន់នោះទេ មានតែ២៧.៥២% ប៉ុណ្ណោះដែលឆ្លើយថាមានគ្រប់គ្រាន់ ។ ចំពោះមូលហេតុដែលសាលាភាគច្រើនលើសលុបមិនមានឯកសារស្រាវជ្រាវដើម្បីពង្រឹងចំណេះដឹងភាសាអង់គ្លេសរបស់សិស្សត្រូវបានអ្នកចូលរួមពន្យល់ថា៖ ១)នាយក/នាយករងៈនាយក/នាយករងចំនួន ៣៣.៣៣% ពន្យល់ថា «*សាលារបស់គាត់មិនមានបណ្ណាល័យសម្រាប់ទុកដាក់ឯកសារទេ*» ។ នាយក/នាយករង ១៣.៣៣% លើកឡើងថា «*ក្រសួងមិនផ្តល់ឱ្យ*» ។ នាយក/នាយករង ១៣.៣៣% មានប្រសាសន៍ថា «*សាលាគ្មានថវិកាទិញថែម*» ។ ហើយនាយក/នាយករង ៦.៦៦% ឆ្លើយថា «*មកពីសាលារបស់ពួកគាត់នៅតំបន់ជួបការលំបាក*» ។ ២) គ្រូបង្រៀនភាសាអង់គ្លេសៈ ចម្លើយរបស់គ្រូបង្រៀនក៏មិនខុសគ្នាពីចម្លើយរបស់នាយក/នាយករងដែរ ដោយពួកគាត់ ៥២.១៧% ពន្យល់ថា «*មកពីសាលាគ្មានបណ្ណាល័យ គ្មានអ្នកជួយឧបត្ថម្ភ និងក្រសួងមិនមានលទ្ធភាពផ្តល់ឱ្យគ្រប់សាលា*» ។ ចំណែកសិស្សវិញ សិស្ស ១៥.៩៤% ឆ្លើយថា «*មកពីសាលាគ្មានបណ្ណាល័យ*» ។ សិស្ស ១.៥០% ឆ្លើយថា «*មកពីសាលានៅជនបទ គ្មានអ្នកជួយឧបត្ថម្ភ*» ។ សិស្ស ១.៥០% ទៀតឆ្លើយថា «*សាលាមិនបានទទួលពីក្រសួង*» ។ សិស្ស ១.២៩% លើកឡើងថា «*មិនដែលឃើញមាន*» ។ ហើយសិស្សចំនួន ០.៨៦% ផ្សេងទៀតឆ្លើយថា «*មកពីគ្រូគ្មានលទ្ធភាពទិញ*» ។

ដូចនេះ យើងឃើញថាឯកសារស្រាវជ្រាវផ្សេងៗដើម្បីពង្រឹងចំណេះដឹងភាសាអង់គ្លេសរបស់សិស្ស មានចំនួនតិចតួចណាស់ ដែលមិនអាចបំពេញតាមសេចក្តីត្រូវការរបស់សិស្សបានទេ ពេលណាដែលពួកគេចង់អានពេលពួកគេទំនេរពីការសិក្សា ឬពេលណាពួកគេត្រូវការឯកសារចាំបាច់។

### *៤.១.២.២.៤.៣ សម្ភារឧបទេស*

**ក្រាហ្វិកទី១៤៖ សម្ភារឧបទេសបម្រើឱ្យការបង្រៀន និងរៀន ភាសាអង់គ្លេស**




យើងទាំងអស់គ្នាដឹងហើយថា សម្ភារឧបទេសដើរតួនាទីសំខាន់ណាស់ក្នុងដំណើរការបង្រៀន និងរៀន ។ វាធ្វើឱ្យដំណើរការនៃការបង្រៀន និងរៀនប្រព្រឹត្តទៅដោយរលូន ដោយសារវាចំណេញពេលវេលាទាំងគ្រូទាំងសិស្ស សិស្សឆាប់យល់បាតុភូត ឬខ្លឹមសារនៃមេរៀន ជាពិសេសវាធ្វើឱ្យសិស្សចងចាំខ្លឹមសារមេរៀន ឬបាតុភូតបានយូរ ។

ចំពោះសំណួរដែលសួរថា តើសាលាអ្នកមានសម្ភារឧបទេសដែលបម្រើឱ្យការបង្រៀន និងរៀនភាសាអង់គ្លេសគ្រប់គ្រាន់ដែរឬទេ? សិស្ស ៥២.១៦ % ឆ្លើយថាមានគ្រប់គ្រាន់ ៤៦.៩៨ % ឆ្លើយ ថា មិនគ្រប់គ្រាន់ ។ សម្រាប់លោកគ្រូ/អ្នកគ្រូ ៤.៣៥ % ឆ្លើយថាមានគ្រប់គ្រាន់ ៩៥.៦៥ % ឆ្លើយថាមិនគ្រប់គ្រាន់ ។ ចំណែកឯនាយក/នាយករងវិញ ៦.៦៧ % ឆ្លើយថាមិនគ្រប់គ្រាន់ ហើយ ៩៣.៣៣ % ឆ្លើយថាមិនគ្រប់គ្រាន់ ។ បើគិតជាមធ្យម ២១.០៦% នៃអ្នកចូលរួមផ្តល់ចម្លើយថាសម្ភារឧបទេសដែលបម្រើឱ្យការបង្រៀន និងរៀនគឺមានគ្រប់គ្រាន់ ប៉ុន្តែ ៧៨.៦៦% ឆ្លើយថាមិនគ្រប់គ្រាន់ទេ ។ កង្វះសម្ភារឧបទេសក្នុងដំណើរការបង្រៀន និងរៀននៅតាមសាលាគោលដៅទាំងអស់ ត្រូវបានអ្នកចូលរួមផ្តល់ហេតុផលដូចតទៅ៖ ១) នាយក/នាយករងៈ នាយក/នាយករង ២៦.៦៦% ពន្យល់ថា «*មកពីក្រសួងមិនបានផ្តល់ឱ្យ*» ។ នាយក/នាយករង ២០% មានប្រសាសន៍ថា «*ខ្វះកន្លែងរៀបចំទុកដាក់ គ្មានអគ្គិសនីក្នុងថ្នាក់*» ។ នាយក/នាយករង ៦.៦៦% លើកឡើងថា «*មកពីសាលាគាត់ជាសាលាកើតថ្មី*» ។ ចំណែកឯនាយក/នាយករង ៦.៦៦% ទៀតឆ្លើយថា «*ដោយសារខ្វះថវិកា*» ។ ២) គ្រូបង្រៀនភាសាអង់គ្លេសៈ គ្រូបង្រៀនចំនួន ៣០.៤៣% ឆ្លើយដូចគ្នាទៅនឹងនាយក/នាយករងដែរគឺ «*មិនបានទទួលពីក្រសួងគ្មាន អគ្គិសនី និងខ្វះថវិកា* » ។ ចំណែកឯគ្រូបង្រៀន ១៣.០៤% លើកហេតុផលថា «*មកពីសាលានៅជនបទ*» ។ ហើយ ៨.៦៩% ទៀតថា «*គ្មានអ្នកជួយឧបត្ថម្ភ និងគ្មានពេលវេលាផលិត*» ។ ចំណែកឯសិស្សវិញ សិស្សចំនួន ៤.៧៤% ឆ្លើយថា «*មកពីសាលាខ្វះថវិកា*» ។ សិស្សចំនួន ១.៧២% ថា«*មិនដែលឃើញគ្រូប្រើ*» ។ ហើយសិស្សចំនួន ១.០៧% ផ្សេងទៀតថា «*មកពីក្រសួងមិនផ្តល់ឱ្យ*» ។

សរុបសេចក្ដីមក សម្ភារឧបទេសដែលជាផ្នែកមួយដ៏សំខាន់ក្នុងដំណើរការបង្រៀន និង រៀនគឺនៅមានការខ្វះខាតច្រើន ដែលមូលហេតុចម្បងគឺសាលាមិនបានទទួលពីក្រសួង សាលាខ្វះថវិកាទិញ គ្មានអ្នកជួយឧបត្ថម្ភពីខាងក្រៅ និងគ្រូគ្មានពេលវេលាគ្រប់គ្រាន់ដើម្បីផលិត ។

*៤.១.២.២.៥ ការគ្រប់គ្រងបុគ្គលិក*

*៤.១.២.២.៥.១ ការពិនិត្យតាមដាន និងវាយតម្លៃគ្រូបង្រៀនភាសាអង់គ្លេស*

ពាក់ព័ន្ធនឹងការងារគ្រប់គ្រងបុគ្គលិក អ្នកស្រាវជ្រាវបានប្រើសំណួរ ១ សួរដល់សិស្ស ហើយបន្ថែមពីលើសំណួរនេះ អ្នកស្រាវជ្រាវក៏បានធ្វើការសម្ភាសដាច់ដោយឡែកជាមួយនាយក/នាយករងសាលាទាំង ១៥ លើចំណុចសំខាន់ៗចំនួន ៥ ដើម្បីធ្វើការផ្ទៀងផ្ទាត់គ្នា គឺទី១ អង្គការដែលជួយផ្នែកភាសាអង់គ្លេស ទី២ បញ្ហាប្រឈមដទៃទៀតដែលមិនបានលើកឡើងក្នុងកម្រងសំណួរ ទី៣ អវត្តមានគ្រូបង្រៀនភាសាអង់គ្លេស ទី៤ របាយការណ៍អធិការកិច្ចមុខវិជ្ជាភាសាអង់គ្លេស និងទី៥ របាយការណ៍ប្រជុំបច្ចេកទេសមុខវិជ្ជាភាសាអង់គ្លេស ។

**ក្រាហ្វិកទី១៥៖ ការពិនិត្យតាមដាន និងវាយតម្លៃគ្រូបង្រៀនភាសាអង់គ្លេស**




នៅក្នុងកម្រងសំណួរគឺមានតែ ១ សំណួរប៉ុណ្ណោះដែលពាក់ព័ន្ធនឹងការងារគ្រប់គ្រងបុគ្គលិក ។ សំណួរសួរថាតើសាលារបស់ប្អូនចុះតាមដាន និងវាយតម្លៃការបង្រៀនរបស់គ្រូបង្រៀនភាសាអង់គ្លេសរបស់ប្អូនញឹកញាប់ឬទេ? ។ សិស្ស ២២.៤១ % ឆ្លើយថាតាមដាន និងវាយតម្លៃញឹកញាប់ ៦៦.៥៩ % ឆ្លើយថាយូរៗម្ដង និង ១០.៣៤ % ឆ្លើយថាមិនដែល ។ យោងតាមក្រាហ្វិកនេះ ឃើញថាការពិនិត្យតាមដាន និងវាយតម្លៃគ្រូបង្រៀនភាសាអង់គ្លេស នៅមិនទាន់បានល្អនៅឡើយទេ ។ ចំពោះលទ្ធផលនៃការធ្វើសម្ភាសជាមួយនាយក/នាយករងលើចំណុចទាំង ៥ វិញបង្ហាញថា ១) មិនមានសាលាគោលដៅណាមួយមានអង្គការណាមួយជួយផ្នែកភាសាអង់គ្លេសនោះទេ ។ ២) មិនមានសាលាគោលដៅណាមួយលើកឡើងពីបញ្ហាប្រឈមក្រៅពីកម្រងសំណួរទេ គឺពួកគាត់លើកឡើងជុំវិញបញ្ហាខ្វះបណ្ណាល័យ ខ្វះគ្រូឯកទេសភាសាអង់គ្លេស ខ្វះសៀវភៅសិក្សាគោលភាសាអង់គ្លេស ខ្វះសម្ភារឧបទេស និងខ្វះឯកសារស្រាវជ្រាវភាសាអង់គ្លេស ។ ៣) សាលាជាង ៩០% មានបញ្ជីវត្តមានរបស់បុគ្គលិកត្រឹមត្រូវ ដោយមានការចុះ

ហត្ថលេខាតាមម៉ោង និងតាមថ្ងៃ ហើយបូកយោងតាមខែនីមួយៗយ៉ាងច្បាស់លាស់ ។ តាមការពិនិត្យ និងកត់ត្រាគ្រូបង្រៀនដែលអវត្តមានច្រើនបំផុត គិតត្រឹមថ្ងៃដែលអ្នកស្រាវជ្រាវចុះប្រមូលទិន្នន័យទៅតាមសាលាគោលដៅទាំង ១៥ នៅដើមខែកក្កដា ឆ្នាំ២០១៨ គឺមានត្រឹម ៥ ដងប៉ុណ្ណោះ (បូកយោងតាមខែ) ។ ៤) សាលាចំនួន ១៣.៣៣% មានរបាយការណ៍អធិការកិច្ចមុខវិជ្ជាភាសាអង់គ្លេស ។ និង ៥) សាលាចំនួន ៣៣.៣៣% មានរបាយការណ៍ប្រជុំបច្ចេកទេសមុខវិជ្ជាភាសាអង់គ្លេស ។

ដូចនេះ បើផ្ទៀងផ្ទាត់គ្នាជាមួយនឹងលទ្ធផលដែលបានមកពីការសម្ភាសជាមួយនាយក/នាយករងអ្នកស្រាវជ្រាវអាចធ្វើការសន្និដ្ឋានបានថាសាលាភាគច្រើនមិនបានធ្វើការពិនិត្យ និងវាយតម្លៃការបង្រៀនរបស់គ្រូបង្រៀនភាសាអង់គ្លេសទេ ដោយសារមានសាលាតិចតួចបំផុតដែលមានរបាយការណ៍អធិការកិច្ច និងរបាយការណ៍ប្រជុំបច្ចេកទេសប្រចាំខែច្បាស់លាស់ ។ ការដែលគណៈគ្រប់គ្រងសាលាមិនដែលធ្វើការចុះពិនិត្យតាមដាន និងវាយតម្លៃដូច្នេះ វាអាចធ្វើឱ្យគ្រូបង្រៀនមួយចំនួនបំពេញការងារដោយមិនយកចិត្តទុកដាក់ ឬដោយការធ្វេសប្រហែស ដែលជាហេតុអាចធ្វើឱ្យប៉ះពាល់ដល់ប្រសិទ្ធភាពនៃការបង្រៀន និងរៀនផងដែរ ។

# ជំពូកទី៥
# សេចក្ដីសន្និដ្ឋាន និង
# សំណូមពរ

# ជំពូកទី ៥
# សេចក្តីសន្និដ្ឋាន និងសំណូមពរ

## ៥.១ សន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវ និងវិភាគទិន្នន័យលើប្រធានបទ «ឥរិយាបថរបស់សិស្សចំពោះមុខវិជ្ជាភាសាអង់គ្លេសនៅមធ្យមសិក្សាបឋមភូមិ» ករណីសិក្សាខេត្តកំពង់ចាមរួចមក លទ្ធផលបានបង្ហាញថា ចាប់តាំងពីការដាក់មុខវិជ្ជាភាសាអង់គ្លេសឱ្យសិក្សាជាផ្លូវការនៅឆ្នាំ1989 នៅកម្រិតមធ្យមសិក្សា ជារួម សិស្សមានឥរិយាបថវិជ្ជមានកម្រិតខ្ពស់ (M = 3.7; SD = 0.37) ចំពោះមុខវិជ្ជាភាសាអង់គ្លេស ដោយសិស្សមានអារម្មណ៍សប្បាយរីករាយ យល់ច្បាស់ពីតម្រូវការ និងភាពចាំបាច់នៃភាសាអង់គ្លេស និងមានការឱ្យតម្លៃខ្ពស់ទៅលើការសិក្សាភាសាអង់គ្លេស ។ ជាងនេះទៅទៀត សិស្សរៀនភាសាអង់គ្លេសដោយការពេញចិត្ត មិនមែនរៀនដើម្បីឱ្យតែប្រឡងជាប់ ឬដោយសារតែសាលាតម្រូវឱ្យរៀននោះទេ ។ ម៉្យាងទៀតពួកគេក៏មិនសូវមានការបារម្ភ ឬការខ្មាសអៀនច្រើនដែរក្នុងការនិយាយភាសាអង់គ្លេស ។ លទ្ធផលនៃការសិក្សាក៏បានបង្ហាញផងដែរថា រវាងសិស្សប្រុស និងសិស្សស្រីនៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ចាម មិនមានឥរិយាបថខុសគ្នានោះទេចំពោះមុខវិជ្ជាភាសាអង់គ្លេស ដោយមាន p-value = 0.81 > 0.05 ។ ចំណែកឯតាមកម្រិតថ្នាក់វិញ ឥរិយាបថរបស់សិស្សចំពោះមុខវិជ្ជាភាសាអង់គ្លេស ក៏មិនមានភាពខុសគ្នាដែររវាងសិស្សថ្នាក់ទី៧ ទី៨ និងទី៩ ដោយមាន p-value = 0.89 > 0.05 ។ ម៉្យាងវិញទៀត បើគិតតាមតំបន់វិញ លទ្ធផលនៃការស្រាវជ្រាវក៏បានបង្ហាញដែរថា ឥរិយាបថរបស់សិស្សដែលនៅតំបន់ទីប្រជុំជន តំបន់ចន្លោះទីប្រជុំជន និងទីជនបទ និងតំបន់ជនបទ មិនមានភាពខុសគ្នាទេ ដោយមាន p-value = 0.37 > 0.05 ។ សរុបមក ឥរិយាបថរបស់សិស្សចំពោះមុខវិជ្ជាភាសាអង់គ្លេស នៅមធ្យមសិក្សាបឋមភូមិមានលក្ខណៈល្អប្រសើរគួរជាទីមោទនៈក្រៃលែង ។

ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ចំពោះដំណើរការបង្រៀន និងរៀនភាសាអង់គ្លេសនៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ចាម នៅមិនទាន់ប្រព្រឹត្តទៅដោយរលូននៅឡើយទេ ។ ផ្អែកលើលទ្ធផលនៃការសិក្សាស្រាវជ្រាវបានបង្ហាញថា អ្នកចូលរួមភាគច្រើន (84.64%) យល់ឃើញថាការខ្វះសៀវភៅសិក្សាគោលជាបញ្ហាចម្បងមួយក្នុងដំណើរការបង្រៀន និងរៀនភាសាអង់គ្លេស ។ រីឯការប្រើប្រាស់គ្រូមិនមែនឯកទេសភាសាអង់គ្លេស (59.42%) ឱ្យបង្រៀនភាសាអង់គ្លេសក៏នៅមានច្រើន ដែលប្រការនេះអាចជះឥទ្ធិពលដល់ការផ្ទេរចំណេះដឹងពីគ្រូទៅសិស្សផងដែរ ព្រោះចំណេះដឹង និងវិធីសាស្ត្របង្រៀនរបស់ពួកគាត់លើមុខវិជ្ជានេះនៅមិនទាន់បានល្អនៅឡើយទេ ។ បន្ថែមពីលើនេះទៀត លទ្ធផលនៃការសិក្សាស្រាវជ្រាវក៏បានបង្ហាញផងដែរថាអ្នកចូលរួមច្រើនជាង 70% យល់ឃើញថាកង្វះសម្ភារឧបទេស (78.66%) និងឯកសារស្រាវជ្រាវ (72.26%) ដើម្បីពង្រឹងសមត្ថភាពទាំងគ្រូទាំងសិស្ស ក៏រួមចំណែកមួយផ្នែកក្នុងការធ្វើឱ្យសិស្សមិនទាន់អាចទទួលបាននូវចំណេះដឹងភាសាអង់គ្លេសពេញលេញផងដែរ ។

សរុបសេចក្តីមក សិស្សមានឥរិយាបថល្អប្រសើរហើយចំពោះមុខវិជ្ជាភាសាអង់គ្លេស ក៏ប៉ុន្តែត្រឹមតែមានឥរិយាបថល្អប្រសើរ មិនទាន់គ្រប់គ្រាន់នៅឡើយទេ ។ បញ្ហាប្រឈមមួយចំនួនដែលមានដូចជា

កង្វះសៀវភៅសិក្សាគោល ការប្រើប្រាស់គ្រូខុសឯកទេស ចំណេះដឹង និងវិធីសាស្ត្របង្រៀនរបស់គ្រូបង្រៀនលើមុខវិជ្ជាភាសាអង់គ្លេសនៅមិនទាន់បានល្អ រួមទាំងកង្វះឯកសារស្រាវជ្រាវផ្សេងៗ និងសម្ភារឧបទេសដែលបម្រើឱ្យការបង្រៀន និងរៀនភាសាអង់គ្លេស ជាកត្តាជះឥទ្ធិពលមិនល្អដល់ការសិក្សាក្រេបយកចំណេះដឹងភាសាអង់គ្លេសរបស់សិស្សនៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ចាម ។

## ៥.២ សំណូមពរ

ដើម្បីរួមចំណែកក្នុងការលើកស្ទួយគុណភាព និងប្រសិទ្ធភាពនៃការបង្រៀន និងរៀនមុខវិជ្ជាភាសាអង់គ្លេស ក៏ដូចជាការចូលរួមមួយផ្នែកក្នុងការលើកកម្ពស់គុណភាពអប់រំនៅកម្ពុជាទាំងមូល អ្នកសិក្សាសូមលើកនូវសំណូមពរមួយចំនួនជូនដល់សាលា ក្រសួងអប់រំ យុវជន និងកីឡា អ្នកពាក់ព័ន្ធនានា ក៏ដូចជាអ្នកសិក្សាស្រាវជ្រាវក្រោយៗ ដើម្បីពិនិត្យ កែលម្អ និងដោះស្រាយទៅតាមស្ថានភាព និងលទ្ធភាពជាក់ស្តែងដូចតទៅៈ

*១. សាលា*

- ពង្រឹងការពិនិត្យតាមដាន និងវាយតម្លៃគ្រូឱ្យបានញឹកញាប់ និងមានផែនការច្បាស់លាស់
- ពង្រឹងការងារប្រជុំបច្ចេកទេសប្រចាំខែឱ្យមានដំណើរ

*២. ក្រសួងអប់រំ យុវជន និងកីឡា*

- ផ្តល់សៀវភៅសិក្សាគោលឱ្យគ្រប់ចំនួនតាមតម្រូវការសាលា
- ផ្តល់សម្ភារឧបទេសដែលបម្រើឱ្យការបង្រៀន និងរៀនឱ្យបានគ្រប់គ្រាន់
- ផ្តល់ឯកសារស្រាវជ្រាវផ្សេងៗដើម្បីពង្រឹងចំណេះដឹងភាសាអង់គ្លេសរបស់សិស្ស
- បន្តជ្រើសរើស និងបណ្តុះបណ្តាលគ្រូឯកទេសភាសាអង់គ្លេសបន្ថែមទៀត
- រៀបចំវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពគ្រូឱ្យបានញឹកញាប់
- ពិនិត្យលទ្ធភាពសាងសង់បណ្ណាល័យបន្ថែម

*៣. អ្នកសិក្សាជំនាន់ក្រោយ*

ដោយសារតែការសិក្សាស្រាវជ្រាវនេះធ្វើឡើងតែនៅក្នុងខេត្តកំពង់ចាម និងនៅក្នុងក្រុង/ស្រុកចំនួន ៦ ប៉ុណ្ណោះ ដូចនេះវាមានលក្ខណៈតូចចង្អៀតនៅឡើយ ។ ដូច្នេះ អ្នកសិក្សាក្រោយៗដែលមានបំណងសិក្សាលើប្រធានបទនេះ ឬស្រដៀងគ្នានេះ គួរតែពង្រីកវិសាលភាពនៃការស្រាវជ្រាវឱ្យកាន់តែទូលំទូលាយជាងនេះ ។

# ឯកសារយោង

# ឯកសារយោង


ក្រសួងអប់រំ យុវជន និងកីឡា “សេចក្ដីណែនាំស្ដីពីការអនុវត្តសៀវភៅសិក្សាគោលភាសាអង់គ្លេស English Grade 7-9 និងការប្រើប្រាស់សៀវភៅ English is Fun សម្រាប់ការបង្រៀន និងរៀនភាសាអង់គ្លេសនៅមធ្យមសិក្សាបឋមភូមិ ឆ្នាំ២០១៦”

Aacken, S. V. (1999). What motivates L2 learners in acquisition of kanji using CALL: A case study. *Computer Assisted Language Learning, 12* (2), 113–136

Abd Aziz, M. S. (1994, January). Attitudes towards Learning English: A Survey of UKM Undergraduates. *Akademika*, *44*, 85–99. Retrieved from http://www.ukm.my/penerbit/akademika/jakad_44-05-lock.pdf

Abidin, M. J. Z., Pour-Mohammadi, M., andAlzwari, H. (2012). EFL students’ attitudes towards learning English language: The case of Libyan secondary school students. *Asian social science*, 8(2), 119-134.

Abu-Melhim, A.-R. (2009). Attitudes of Jordanian College Students Towards Learning English as a Foreign Language. *College Student Journal*, *43*(2), 682−94. Retrieved from http://web.ebscohost.com.wf2dnvr1.webfeat.org/ehost/delivery?hid=12&sid=d12a81f7

Ahmad, S. (2015). Attitudes toward English Language Learning among EFL Learners at UMSKAL. *Journal of Education and Practice. Vol. 6, No. 18, 6-16.* Ajzan, I. 1988. *Attitudes, personality and behaviour.* Chicago: Dorsey Press.

Ajzen, I. (2005). *Attitude, personality and behavior* (2nd Ed.). New York: Open University Press.

Al Noursi, O. (2013). Attitude towards Learning English: The case of the UAE Technological High School. *Educational Research*, Vol. 4(1), 21-30.

Al Noursi, O. (2013, January). Attitude Towards Learning English: The Case of the UAE Technological High School. *Educational Research*, *4*(1), 21–30. Retrieved from http://www.interesjournals.org/ER.

Al Samadani, H.& Ibnian. S. (2015). The Relationship between Saudi EFL Students’ Attitudes towards Learning English and their Academic Achievement. *International Journal of Education and Social Science*, Vol. 2, No. 1, 92- 102.

Alkaff, A.A. (2013). Students’ attitudes and perceptions towards learning English. *Arab World English Journal*, *4*(2), 106-121.

Al-Mamun, A., Rahman, M., Rahman, A. R., & Hossaim, A. A. (2012). Students’ attitudes towards English: The case of life science school of Khulna university. *International Review of Social Sciences and Humanities, 3*, 200–209.

Al-Mansour, N. S. (2007**,** January 21). The Effect of Attitude on Foreign Language Acquisition:The learning of Arabic Pronunciation as a Case Study. *Readings: A Bilingual Journal of English Studies***.** Retrieved from http://faculty.ksu.edu.sa/al-mansour/default.aspx

Al-Tamimi, A. & Shuib, M. (2009). Motivation and Attitudes Towards Learning English: A Study of Petroleum Engineering Undergraduates at Hadhramout University Of Sciences and Technology, *GEMA Online Journal of Language Studies*, *9*(2), 29–53. Retrieved from http://www.ukm.my/ppbl/Gema/abstract%20for%20pp%2029_55.pdf

Al-Zahrani, M. (2008). Saudi secondary school male students’ attitudes towards English: An exploratory study. J. King Saudi University, *Language and translation, vol. 20, 25-39.*

Baker, C. (1992). *Attitudes and Language*. Clevedon: Multilingual Matters Ltd.

Brown, H. D. (2000). *Principles of language learning and teaching*. White Plains, NY: Addison Wesley Longman

Brown, H. D. (2001). *Teaching by Principles: An Interactive Approach To language*

*Pedagogy* (2nd ed.). San Francisco Public University.
Burden, P. (2004). An examination of attitude change towards the use of Japanese in a university English ‘conversation’ class. *RELC*, *35*(1), 21-36. http://dx.doi.org/10.1177/003368820403500104
Chamber G. (1999). *Motivating Language Learners*. Clevendon Multilingual Matters Ltd.
Choy, S. C. & Troudi, S. (2006)**.** An investigation into the changes in perceptions of and attitudes towards learning English in a Malaysian college. *International Journal of Teaching and Learning in Higher Education* , *18*(2), 120-130.
Clayton, T. (2007). *Transition, culture, and language in Cambodia*. In A.B.M. Tsui, & J.W. Tollefson (Eds.).Language policy, culture, and identity in Asian contexts, (pp. 95-120). Mahwah, NJ: Lawrence Erlbaum Associates
Crystal, D. (1997). *English as a global lanuage.* Cambridge:CambridgeUniversity Press.
Crystal, D. (2003). *English as a Global Language.* 2nd edition. Cambridge University Press
Despagne, Colette (2010, January 6). The Difficulties of Learning English: Perceptions and Attitudes in Mexico. *Canadian and International Education / Education Canadienneet International*, *39*(2), Article 5, 55–74. Retrieved from http://ir.lib.uwo.ca/cie-eci/vol39/iss2/5
Dörnyei, Z. (2001). *Motivational Strategies in the Language Classroom.* Cambridge: Cambridge University Press
Dornyei, Z. & Shoaib, A. (2005). Affect in lifelong learning: Exploring L2 motivation as a dynamic process. In Nunan, D. & Benson, P. (Eds.) *Learners' stories: Difference and diversity in language learning.* Cambridge University Press: UK
Eshghinejad, S. ( 2016). EFL Students’ Attitudes toward Learning English LAnguage: The Case Study o Kashan University Students. *Cogent Education,* Vol. 3, Issue 1. 1-13.
Fakeye, D. (2010). Students’ personal variables as correlates of academic achievement in English as a second language in Nigeria. *Journal of Social Sciences*, *22*, 205–211.
Feng, R., & Chen, H. (2009). An analysis on the importance of motivation and strategy in postgraduates English acquisition. *English Language Teaching*, *2*, 93–97. Retrieved from http://www.ccsenet.org/journal/index.php/elt/article/viewFile/3700/3301
Gajalakshmi (2013). High School Students’ Attitude towards Learning English Language. *The Case Study of Puducherry region, India*
Gardner, R. (1985). *Social psychology and second language learning. The role of attitudes and motivation*. London:Edward Arnold.
Gardner, R. (1980). “On the validity of affective variables in second language acquisition: Conceptual and statistical considerations.” *Language Learning* 255-270.
Grosjean. 2010. *Bilingual: Life and Reality*. Harvard University Press
Hasman, A. M. (2000). The role of English in 21th century. *English Teaching Forum, 39*(1), 1-5 G. Hogan-Brun and M. Romoniene. (2005). Perspectives on language attitudes and use in Lithuania’s multilingual setting, *Journal of Multilingual and Multicultural Development,* 26(5) 425-441
Igawa, K. (2008). English Language and its Education in Cambodia, a Country in Transition.
J. Borromeo-Samonte. (1981). Attitudes of college students towards English as a second language, *Unpublished Thesis*University of Santo Thomas, Manila, Philippines,
Kara, A. (2009). The Effect of a „Learning Theories‟ Unit on Students‟ Attitudes towards Learning. *Australian Journal of Teacher Education, 34*(3), 100-113.
Karahan, F. 2007. “Language attitudes of Turkish students.” *Journal of Arts and Sciences* 73-87.
